អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 05-Jan-2017, 14:51
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦**

**ម៉ោង ០៩:០០នាទី**

**សវនាការលើកទី៤៥៩**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម យ៉ា សុខន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ៉ង

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆរ័ន្ត

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វលក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡៃ ជុនធី

លោក វ៉ែន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្ល សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម យ៉ា សុខន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ខេល លីសាក់ | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក លីវ សុវណ្ណា | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក គង់ សំអុន | ខ្មែរ |
| លោក សែម អំ (2-TCW-1031) | ខ្មែរ |
| សាក្សី 2-TCW-1036 | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក សែម អ៊ំ** (2-TCW-1031)


សួរបន្តដោយលោក ឌេល លីសាក់ ផ្ដើមពី ........................ ទំព័រ ៤

សួរដោយលោក ពេជ អង្គ ផ្ដើមពី ........................ ទំព័រ ២០

សួរដោយលោក អង់តា ហ្គីសសេ ផ្ដើមពី ........................ ទំព័រ ២៨


**ការសួរសំណួរទៅសាក្សី៖** 2-TCW-1036


សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ........................ ទំព័រ ៣៩

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី ........................ ទំព័រ ៤១

សួរដោយលោក ឌេល លីសាក់ ផ្ដើមពី ........................ ទំព័រ ៧៥

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០០:២២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី សែម អំ បញ្ចប់ ហើយនិងស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-1036 ពាក់ព័ន្ធនឹងអង្គហេតុការបោសសម្អាតផ្ទៃក្នុង។

ក្រឡាបញ្ជីសវនាការកញ្ញា ស៊ីវហ៊ាង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញចូលរួមក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃនេះ។ សូមអញ្ជើញ!

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា មានបានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ដើមបណ្តឹងរដ្ឋប្បវេណីដែលនឹងត្រូវមកផ្តល់សក្ខីកម្មបន្តបញ្ចប់នៅ -- សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបន្តបញ្ចប់នៅថ្ងៃនេះគឺលោក សែម អំ លោកមានវត្តមាននៅបន្ទប់រង់ចាំៗ ការកោះហៅពីអង្គជំនុំជម្រះ។ ហើយសាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបន្តទៀតនៅថ្ងៃនេះមានរហស្សនាម 2-TCW-1036។

សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹងគឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូបគឺ លោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីនឹងធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែកនាព្រឹកនេះ។ សូមអរគុណលោកប្រធាន។

[០៩:០២:១៥]

**ប្រធានអង្គជំនុំ៖**

អរគុណកញ្ញា ស៊ីវហ៊ាង។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះមិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦ នេះ។

មេធាវីការពារក្តីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះ មិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

[០៩:០៣:០៩]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា ថ្ងៃនេះ មានអាការៈឈឺចង្កេះជាប្រចាំ ហើយនិងកាន់តែឈឺខ្លាំងនៅពេលអង្គុយ និងបានផ្តល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។ ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅខាងក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅខាងក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់សវនាការថ្ងៃនេះ។

មុននឹងផ្តល់វេទិកាដល់តំណាងសហព្រះរាជអាជ្ញាក្នុងការតាំងសំណួរបន្តទៅសាក្សី អង្គជំនុំជម្រះមានបំណងស្តាប់សារណាផ្ទាល់របស់ភាគី ពាក់ព័ន្ធនឹងសំណើសុំរបស់លោកមេធាវីការពារក្តី នួន

ជា អនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង សុំឲ្យទទួលយកភស្តុតាងនៅកំណត់ហេតុស្តាប់ចម្លើយចំនួនពីររបស់សាក្សី 2-TCW-1036 ដែលនឹងត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះ។

កាលពីរសៀលថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦ មេធាវីការពារក្តីលោក នួន ជា បានជូនដំណឹងតាមរយៈអ៊ីម៉ែលពីសំណើរបស់ខ្លួន និងស្នើសុំធ្វើសារណាផ្ទាល់មាត់លើបញ្ហានេះ។ ហេតុដូច្នេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាទៅលោកមេធាវីការពារក្តីលោក នួន ជា លើកឡើងពីសំណើសុំរបស់ខ្លួន។ សូមលោកលើកឡើងដោយខ្លីបានហើយ។ សូមអញ្ជើញលោកមេធាវីការពារក្តីលោក នួន ជា!

[០៩:០៥:១៥]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ខ្ញុំនឹងលើកឡើងខ្លីៗ។

ជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម សហការីទាំងអស់គ្នា។ នេះពាក់ព័ន្ធទៅនឹងកំណត់ហេតុស្តាប់ចម្លើយចំនួនពីរបន្ថែមទៀត ដែលនឹងត្រូវយកមកប្រើប្រាស់ជាមួយនឹងសាក្សីដែលជាកំណត់ហេតុឆ្លើយទៅនឹងសហចៅក្រមស៊ើបអង្កេត គឺមាន <F2/4/23.2.2>, F2/4/23.2.1។ ហើយយោងតាមការកំណត់ដាក់ឯកសារគឺថាយើងខ្ញុំអាចស្នើសុំដាក់ទាំងនេះដោយយោងទៅលើចម្លើយចំនួនពីរដែលអង្គជំនុំជម្រះបានទទួលយករួចមកហើយ ដែលខ្ញុំយល់ឃើញថាមានសារៈសំខាន់ណាស់។ អ៊ីចឹងកំណត់ហេតុទាំងពីរនេះគឺជាភស្តុតាងដ៏សំខាន់មួយ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវីការពារលោក នួន ជា។ ជាបន្តសូមអញ្ជើញលោកព្រះរាជអាជ្ញា លោកមានក្នុងការឆ្លើយតបរវាងសំណើនេះ ប្រសិនបើមាន។ សូមធ្វើខ្លីៗបានហើយបាទ។

[០៩:២៦:២៦]

**លោក ឌេល លីសាក់៖**

បាទ ខ្ញុំនឹងឆ្លើយយ៉ាងសង្ខេប។ ខ្ញុំមិនជំទាស់ទៅនឹងសំណើសុំនេះទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

មេធាវីដើមបណ្តឹងរដ្ឋប្បវេណី សូមអញ្ជើញ បើសិនមានបំណងឆ្លើយតបដោយខ្លីៗ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ យើងខ្ញុំមិនមានការជំទាស់អ្វីទេ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោកមេធាវីការពារ លោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ មេធាវីការពារក្តីលោក ខៀវ សំផន ក៏មិនជំទាស់អ្វីដែរ។

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវី។ អង្គជំនុំជម្រះអរគុណចំពោះភាគីដែលបានឆ្លើយតបនឹងសំណើនេះ។ អង្គជំនុំជម្រះនឹងយកមតិយោបល់របស់ភាគីទៅពិនិត្យពិចារណា និងសម្រេចលើបញ្ហានេះក្នុងពេលឆាប់ៗ។

ជាបន្ត បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការ អញ្ជើញលោក សែម អំ ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

ជាបន្ត សូមអញ្ជើញលោកព្រះរាជអាជ្ញាបន្តសំណួរលើសាក្សីរូបនេះ។

**លោក ឌេល លីសាក់៖**

អរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក ឌេល លីសាក់៖**

**ស៖** អរុណសួស្តីលោកសាក្សី ខ្ញុំចង់បង្ហាញលោកអំពីអំឡុងពេលក្រោយការចាប់ខ្លួន អឿន ដែលនៅពេលនោះ លោកត្រូវបានគេបញ្ជូនទៅឲ្យធ្វើស្រែនៅកប់ស្រូវ ហើយក្រោយមក គេឲ្យទៅបឹងបាយ៉ាប។ ក្រោយពីការចាប់ខ្លួន អឿន ហើយនិងមេកង -- ថ្នាក់ដឹកនាំកងពលដទៃទៀត តើមានយុទ្ធជនធម្មតាពីវរៈរបស់លោក និងកងពលរបស់លោកហ្នឹង មានបាត់ខ្លួនដែរឬទេ?

**លោក សែម អំ៖**

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ។ កាលដែលខ្ញុំនៅកប់ស្រូវ មិនសូវមានបាត់ទេ។ នៅបឹងបាយ៉ាបបានបាត់ខ្លួនច្រើន ឲ្យតែឃើញឡានឃ្លុបទៅ ដឹងគេយកទៅណាទេ ឡានឃ្លុបទៅមួយៗភ័យហើយ ដកមួយពីរៗ បាត់ដាក់ឡានបាត់ទៅ មិនដឹងគេយកទៅណា ខ្ញុំអត់ដឹងដែរ គិតតែនាំគ្នាភ័យទាំងអស់តែគ្នា ខ្លាចជំនាន់នោះ។

[០៩:១០:០០]

**ស៖** តើលោកមានធ្លាប់ដែលបានឃើញគេនាំមនុស្សយកចេញទៅបាត់នោះដែរទេ?

**ឆ៖** ខ្ញុំធ្លាប់ឃើញគេចាប់ដាក់ឡាន ហើយចុះកន្លែងនោះ វានៅ រោងនៅក្បែរៗគ្នា។ ឃើញគេចាប់ដាក់ឡានទៅ ក៏អត់ឃើញមើលគេដែរ ខ្លាច។ ខ្លាចដល់ខ្លួនឯង បាទ។

**ស៖** នៅពេលដែលលោកនៅឈរជើងនៅឯបឹងបាយ៉ាប តើការចាប់ខ្លួននេះ វាញឹកញាប់ប៉ុនណាដែរ?

**ឆ៖** យូរៗម្តង យូរៗម្តង អត់រាល់ថ្ងៃទេ ប្រហែលបួនដប់ថ្ងៃ កន្លះខែម្តងទៅ បាទ។

**ស៖** តើលោកអាចប៉ាន់ប្រមាណពីចំនួនប្រជាជន ឬក៏ភាគរយនៃចំនួនយុទ្ធជននៅក្នុងវរៈរបស់លោក ដែលត្រូវបានគេចាប់ខ្លួន ឬក៏បាត់ខ្លួននោះ បានដែរឬទេ?

**ឆ៖** កាលចំនួនកងទ័ពពីមុន វាមានចំនួន៥០០នាក់ជាង តែមិនដឹងគេដកទៅណាខ្លះទេ បាត់ចេះតែបាត់ម្តងមួយពីរ ទៅគេដកទៅរៀនខ្លះអីខ្លះទៅ នៅសល់៣០០នាក់ បាទ។

**ស៖** ចុះចំពោះប្រពន្ធ កូនៗរបស់ថ្នាក់ដឹកនាំកងពល ថ្នាក់ដឹកនាំវរសេនាធំ <វរសេនាតូច>តើមានអ្វីកើតឡើងទៅដល់ប្រពន្ធកូន សមាជិកគ្រួសាររបស់ថ្នាក់ដឹកនាំទាំងនោះ?

**ឆ៖** បាទ ប្រពន្ធកូនអ្នកធំៗ គេធ្វើកន្លែងឲ្យនៅម៉ាដុប នៅកន្លែងច្រាំងចំរេះ អាហ្នឹង ខ្ញុំឃើញផ្ទាល់ភ្នែកខ្ញុំ បានទៅលេងម្តងដែរ។ គេនៅសុទ្ធ -- អាខ្លះកូនមួយ អាខ្លះអត់មានកូន ខ្លះកូនពីរ។ គេឲ្យនៅជុំគ្នា។ តែដឹងគេយកទៅណាទៀត ខ្ញុំអត់ដឹង។

[០៩:១២:៤៤]

**ស៖** មូលហេតុដែលខ្ញុំសួរលោកអំពីបញ្ហានេះ ដោយសារថា នៅកំណត់ត្រាស-២១ ពីមន្ទីរសន្តិសុខនោះ គឺថាគេថាបានកត់ត្រាពីចំនួនប្រពន្ធកូន សាច់ញាតិ របស់ថ្នាក់ដឹកនាំដែលត្រូវបានចាប់ខ្លួន និងបញ្ជូនទៅស-២១។ ឧទាហរណ៍ដូចជា នៅថ្ងៃទី៣១ ធ្នូ ១៩៧៦ គឺប្រពន្ធៗរបស់ថ្នាក់ដឹកនាំកងពល៣១០ហ្នឹង គឺថាត្រូវបានគេចាប់ខ្លួនចំនួនប្រាំបីនាក់ <ហើយបញ្ជូនទៅ ស-២១>។ នេះគឺមាន គឺមានលេខ៥១០, <៥១១,> ៥១៣ ដល់៥១៧ ហើយនិងលេខ<៨៦៦>។ នៅបញ្ជីអ្នកទោសរបស់សហចៅក្រមស៊ើបអង្កេត ពាក់ព័ន្ធទៅនឹងលេខាកងពល៣១០ ឈ្មោះ អឿន នេះ ប្រពន្ធរបស់គាត់ឈ្មោះ <ព្រុំ ញ៉ូ> ហៅ <វៀន> នេះ ក៏ត្រូវបានបញ្ជូនទៅស-២១ នៅថ្ងៃទី២៦ ឬ២៧ កុម្ភៈ ៧៧។ គឺគាត់មានលេខទី៦៩៦១ នៅបញ្ជីសហក្រមស៊ើបអង្កេត។ ឪពុករបស់ អឿន អាយុ៦៤ឆ្នាំ ឈ្មោះ <ស្បូវ កេត> នោះ ក៏

ត្រូវបានបញ្ជូនទៅស-២១ នៅយប់ថ្ងៃទី<៩> ខែមីនា <១៩៧៧ ត្រូវបានគេសម្លាប់មួយ>ខែក្រោយមក គឺ<ថ្ងៃទី៤ ខែមេសា។> គាត់មានលេខ២៥៤២ នៅបញ្ជីសហាថៅក្រមស៊ើបអង្កេត ហើយនិងជីដូនមួយស្រីម្នាក់ អាយុ១៤ឆ្នាំ ក៏ត្រូវបានបញ្ជូនទៅស-២១ <នៅខែវិច្ឆិកា>។ គឺគាត់មានលេខ<៦៧៧០>។ ហើយប្រពន្ធរបស់<អនុ>លេខាឈ្មោះ រឿង ក៏ត្រូវ<ចាប់ខ្លួន>បញ្ជូនទៅស-២១ នៅ<ថ្ងៃទី៩> ខែមីនា ៧៧ ហើយនិងសម្លាប់ចោលពីរសប្តាហ៍ក្រោយ។ គឺគាត់មានលេខ២៥៤៣។ តើការរៀបរាប់អំពីឈ្មោះមនុស្សទាំងអស់នេះ<ធ្វើឲ្យលោកនឹកឃើញឡើងវិញទេ> លោកសាក្សី? <តើ>លោកមានចាំថា ប្រពន្ធនិងកូន<និងសាច់ញាតិ>របស់ថ្នាក់ដឹកនាំកងពល<៣១០>ហ្នឹងត្រូវបានចាប់ខ្លួន ហើយបាត់ខ្លួនដែរឬទេ?

**ផ៖** បាទ នៅរឿងនោះ ខ្ញុំអត់បានដឹងទេ អត់ដឹង។ អត់ដឹងគេចាប់ប្រពន្ធ ចាប់កូននោះ កាលពីថ្ងៃណា គឺអត់បានដឹង។

[០៩:១៥:៣២]

**ស៖** មិនថ្វីទេ ឥឡូវខ្ញុំចូលទៅសួរសំណួរពីរបីសំណួរ ពាក់ព័ន្ធទៅនឹងការចោទប្រកាន់ថា មានផែនការធ្វើរដ្ឋប្រហារ។ លោកបានឆ្លើយថា លោកមានការដឹងតិចតួចអំពីបញ្ហានេះ។ អ៊ីចឹងខ្ញុំសូមសួរសំណួរពាក់ព័ន្ធទៅនឹងបញ្ហានេះ។ ដំបូង គឺអ្វីដែលមេធាវីការពារក្តីលើកឡើងថា ជាឯកសារសម្ងាត់ លោកបានផ្តល់សក្ខីកម្មថា នីរសាររបស់ អឿន ប្រាប់លោកអំពីបញ្ហានេះ។ តើនីរសាររបស់ អឿន ដែលប្រាប់លោកអំពីឯកសារសម្ងាត់នេះ នីរសារនោះឈ្មោះអ្វីដែរ?

**ផ៖** បាទ ខ្ញុំអត់ចាំទេ ភ្លេចអស់បាត់ហើយ មិនដឹងអី ឈ្មោះអីទេ ខ្ញុំភ្លេចបាត់ទៅហើយ អត់ចាំផង។

**ស៖** នៅពេលនីរសាររបស់ អឿន ប្រាប់លោកអំពីឯកសារនេះ តើគាត់មានបាននិយាយថា ឯកសារដែលគាត់បានឃើញនេះ អាចជាចម្លើយសារភាពរបស់អ្នកទោស ដែលសារភាពអំពីផែនការធ្វើរដ្ឋប្រហារនេះដែរឬទេ?

**ផ៖** អត់បានឃើញ អត់បានដឹងទេ ព្រោះខ្ញុំឮគេ នីរសារនិយាយប្រាប់តែប៉ុណ្ណោះឯង អត់បានឃើញ ហើយខ្ញុំក៏អត់បានអានឯកសារនោះដែរ។ បើគេនិយាយ និយាយប្រាប់មែន។ ការធ្វើរដ្ឋប្រហារ ប៉ុន្តែខ្ញុំបានដឹង ដែលដូចថា រៀបខោ រៀបអាវ រៀបស្បែកជើងនោះដឹង ដឹងថាគេធ្វើរដ្ឋប្រហារ គេផ្ទុះកាំភ្លើងបានកាន់កាប់ទៅ គេនឹងស្លៀកពាក់ខោអាវនឹងទៅ។ ខ្ញុំដឹងអានោះខ្ញុំដឹង ល្បៀងៗ ដែលគេមិនរាល់

ថ្ងៃទេ យូរៗម្តង។ ខ្ញុំបានឃើញគេរៀបមែន រៀបខោ រៀបអាវ រៀបស្បែកជើង នោះរៀបមែន។ មួយកងៗ មួយក្រុម គេរៀបតាមក្រុម។ មួយក្រុមមាន១០កំប្លេ ហើយកងខ្ញុំ កងកាំភ្លើងធំ ១០កំប្លេ កងកាន់ខូសេត ផ្សេងទៅ កងកាន់ ដេកា៨២ ផ្សេង កងកាំភ្លើងត្បាល់៨០។ បាទ ប៉ុណ្ណោះឯង ខ្ញុំឃើញគេរៀបដាក់ម៉ឺៗបណ្តោយ ដែលដល់ពេលគេចាប់ តាអឿន បាត់ទៅ ក៏រឿងនោះក៏ស្ងាត់បាត់អស់ទៅ មិនដឹងទៅណាទៅណីវិញ ខ្ញុំអត់សូវដឹងដែរបាទ។

[០៩:១៨:២០]

**ស៖** ខ្ញុំនឹងសួរអំពីឯកសណ្ឋានកងទ័ពនេះនៅពេលក្រោយ។ ឥឡូវនេះ ខ្ញុំសួរតែអំពីបញ្ហា ឯកសារដែលនីរសាររបស់ អឿន <ប្រាប់លោកនោះ>។ តើនីរសាររបស់ អឿន នេះមានពន្យល់<ទេ>ថា <ទាហាន>អាមេរិកនេះ នឹងមកជួយអន្តរាគមន៍ក្នុងរយៈពេល ២៤ម៉ោង<ដោយរបៀបណា?> តើគាត់មានពន្យល់អ្វីបន្ថែមអំពីអន្តរាគមន៍របស់អាមេរិកនេះទេ?

**ឆ៖** គាត់អត់មានពន្យល់អីខ្ញុំទេ គ្រាន់តែគាត់និយាយមួយភ្លែតទៅក៏ កាលនោះ គឺមិនដែលបានជួបជុំគ្នា និងឈរលេង អង្គុយលេងព្រោកប្រាជ្ញគ្នាទេ។ ពេលមេៗចូលទៅប្រជុំក៏និយាយមួយម៉ាត់ៗប៉ុណ្ណោះឯងទៅក៏ ខ្ញុំលួចចាំបានទៅ ព្រោះកាលនោះ មេៗគេចូលប្រជុំ ពួកនីរសារនៅជុំគ្នា និយាយគ្នាលេងទៅ ឈរលេងទៅ ពីនេះពីនោះ ជួនកាលក៏ឈរទៅ អាខ្លះគេជិះម៉ូតូទៅណាទៅណី។ ពេលណា មេគេប្រជុំរួច ក៏គេហៅមកវិញតែប៉ុណ្ណោះឯង។ ដល់ឲ្យនៅនិយាយរឿងម៉េចៗ គឺមិនដែលដឹងទេ ព្រោះខ្ញុំនិយាយជារឿងពិត ខ្ញុំមិននិយាយថា ភូតកុហក ការភរកុហកគេមិនការពិត គឺមិនអាចនិយាយទៅបានទេបាទ។

**ស៖** ត្រឹមត្រូវដែរឬទេ បើសិនណា ខ្ញុំថា អ្វីដែល ពាក្យសម្តីដែលនីរសាររបស់ អឿន ប្រាប់លោកហ្នឹង គឺគ្រាន់តែជាការនិយាយលេង ឬពាក្យចចាមអារ៉ាមទេ អាចថាអ៊ីចឹងបានទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលសាក្សីៗ កុំទាន់អាលទាន់ឆ្លើយ! អញ្ជើញលោកមេធាវីការពារលោក នួន ជា!

[០៩:២០:២០]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់ទៅនឹងសំណួរនាំមុខ ហើយសំណួរដែលផ្តល់តម្រុយចម្លើយទៅឲ្យសាក្សីបែបនេះ។ ដំបូង គឺថាមានភស្តុតាងទាំងភស្តុតាងមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ក៏ដូចជាខ្សែអាត់សំឡេង

ផ្ទាល់ផងដែរ។ សាក្សីបានផ្តល់ចម្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជាថាអ៊ីចេះ “<ឯកសារ>ដែល<> មិនមានហត្ថលេខានោះទេ” <ដូច្នេះគាត់និយាយលម្អិតហើយ>។ អ៊ីចឹង<ពេលនេះមកព្យាយាមបំបាត់ភស្តុតាងនោះ ដោយ>ការសួរ<នាំមុខគាត់>ថា <នេះ>ជាពាក្យចចាមអារ៉ាម ឬយ៉ាងណានោះ គឺថាជាការសួរនាំមុខហើយ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<លោកមេធាវី ខ្ញុំគិតថា យើងមានការកត់សម្គាល់ទាំងអស់ ដែលគាត់បានកែប្រែភស្តុតាងរបស់គាត់។> គឺថា យើងបានអានពីម្សិលមិញហើយ អំពី<អ្វីដែលលោកបានសួរនាំមុខនោះ ប៉ុន្តែ --> ដូច្នេះយើងមានការយល់ឃើញ<ផ្សេងគ្នា>អំពីព្រឹត្តិការណ៍តែមួយ <អំពីអ្វីដែលកើតឡើង>។ ឥឡូវនេះសាក្សីទៅជាឆ្លើយផ្សេងទៅវិញ ម្សិលមិញឆ្លើយថាបានអាន ឥឡូវថាអត់បានអានទេ។ <ពិតណាស់ថាយើងត្រូវគិតនៅក្នុងចិត្តយើងផ្ទាល់ចំពោះអ្វីដែលគួរជឿ និងអ្វីដែលមិនគួរជឿ។> ដូច្នេះ <ខ្ញុំគិតថាលោកមិនអាច>ជំទាស់សហព្រះរាជអាជ្ញា<មិនឲ្យសួរសំណួរ>នោះ<បាន>ទេ។ បើសិនណាជា<មិន>បានអាន<ផង តើធ្វើម៉េចទើបអាចដឹងបាន?>

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ខ្ញុំសូមរៀបចំឃ្លាខ្ញុំឡើងវិញ។ ការសន្ទនាដែលលោកនិយាយគ្នាជាមួយនឹង<នីរសាររបស់> អឿន ពេលដែលនិយាយគ្នាទៅ លោកយល់ឃើញថា ពាក្យសម្តីរបស់<គាត់>ហ្នឹងជាពាក្យសម្តីធ្ងន់ធ្ងរហ្មត់ចត់មែនទែន ឬគ្រាន់តែជាការនិយាយលេងទេ?

**លោក សែម អំ៖**

**ឆ៖** ហ្នឹងនីរសារនោះ និយាយមិនពិតប្រាកដទេ និយាយៗខាងក្រៅអង្គប្រជុំនោះគឺ ដូចតែនិយាយលេង និយាយប្រាប់ឯង ប្រាប់អញ ឲ្យបានដឹងប៉ុណ្ណោះទេ បើថានិយាយឲ្យប្រាកដមានឯកសារភស្តុតាងអ្វីមួយ គឺអត់ អត់មាន។ ព្រោះពីម្សិលមិញខ្ញុំឆ្លើយក៏អត់មានបានអានឯណា ខ្ញុំអត់បានអានទេ គ្រាន់តែបានដឹង។

[០៩:២២:៣០]

**ស៖** ឥឡូវខ្ញុំចូលទៅសួរអំពីឯកសណ្ឋាន <ស្បែកជើងកង់ឡាន> និងអាវុធដែលលោកបានឃើញ ។ បើខ្ញុំយល់មិនច្រឡំទេ សក្ខីកម្មរបស់លោកពីម្សិលមិញនោះ គឺថាលោកឆ្លើយថាលោកបានឃើញនៅមន្ទីរឃោសនាការ ឬក៏ឃើញនៅផ្ទះមួយទល់មុខទៅនឹងក្រសួងឃោសនាការ ត្រឹមត្រូវដែរឬទេ?

01375059



**ឆ៖** បាទ ត្រឹមត្រូវ។ ផ្ទះមួយបណ្ដោយនៅទល់មុខកន្លែងឃោសនាការ កន្លែងហ្នឹងហើយកន្លែងៗគេដាក់អាវុធ ដាក់ខោអាវ នៅកន្លែងនោះឯង។

**ស៖** ហើយតើផ្ទះនេះគឺជាផ្ទះមួយដែលត្រូវបានកងពល៣១០ ប្រើប្រាស់ហ្នឹងឬ ហើយបើសិនជាប្រើប្រាស់ តើកងពល៣១០ ប្រើប្រាស់ផ្ទះនេះសម្រាប់ធ្វើអ្វី?

**ឆ៖** ផ្ទះនោះគឺសម្រាប់គ្រាន់ដាក់សម្ភារៈ។ មុនដំបូងគឺនៅនោះឯង នៅ -- គេប្រមូលកាំភ្លើងប្រមូលអីមកដាក់កន្លែងនោះ គំនរ តាំងពីកាំភ្លើងខ្លី ខោអាវប្រដាប់ប្រដាអី គេដាក់នៅកន្លែងនោះឯង។ ដល់ពេលគេរៀបចំ ក៏គេរៀបចំកន្លែងនោះ មានគេអ្នកយាមអ្នកអី ការពារកន្លែងឃ្លាំង គេដាក់ធ្វើជាឃ្លាំង ផ្ទះនោះបាទ។

**ស៖** តើមានមូលហេតុអី ដែលលោកបានទៅដល់ឯឃ្លាំងរបស់កងពល៣១០នោះ?

**ឆ៖** ឃ្លាំងនោះមិនមែនកន្លែងឃ្លាំងកងពលទេ កន្លែងឃ្លាំងវរៈ១៣។ តែរឿងកន្លែងឃ្លាំងកងពល ខ្ញុំអត់ដែលបានបៀតបតទេ អត់ដែលឃើញ។ អានោះគឺជាកន្លែងវរៈៗ វរសេនាធំ១៣នោះឯងកន្លែងឃ្លាំងនោះបាទ។

**ស៖** សូមអរគុណ។ តើ អ៊ីចឹងតើមូលហេតុអីបានជាលោកបានទៅឯឃ្លាំងរបស់វរសេនាធំលេខ១៣ នោះ?

[០៩:២៤:៥៥]

**ឆ៖** កាលណោះ គេប្រើខ្ញុំឱ្យយកស្អីឱ្យគេទេ ខ្ញុំភ្លេចទៅយូរណាស់ហើយ។ ខ្ញុំទៅក៏ឃើញគេរៀបចំ ក៏ខ្ញុំឈរមើលគេមួយសន្ទុះ ឈរមើលគេនៅឯណោះឯង ក៏ខ្ញុំចុះមកវិញ។

**ស៖** តើគេចាត់តាំងឱ្យលោកទៅយករបស់របរហ្នឹង នៅឃ្លាំងរបស់វរៈ១៣ហ្នឹងញឹកញាប់ប៉ុន្មានដែរ?

**ឆ៖** បាទ ខ្ញុំបានឃើញតែម្ដងនោះឯង អានេះខ្ញុំនិយាយត្រង់ ខ្ញុំឃើញតែម្ដងហ្នឹងឯង ក៏ខ្ញុំគេឱ្យទៅនៅកប់ស្រូវ ខ្ញុំអត់ដែលបានមកទៀតទេ។ ហើយទ័ពមួយសានោះ គ្មានពេលបានដើរទេ នៅវាលកប់ស្រូវនោះ គឺនៅតែកប់ស្រូវ គ្មានពេលចេញដើរលេងទៅណាបាន ព្រឹកម៉ោងប្រាំមួយ ចាប់ផ្ដើមធ្វើការដល់មួយដណ្ដប់ ពីរដណ្ដប់ បានឡើងហូបបាយ។ ហូបបាយរួច គេអត់ឱ្យសម្រាកទេ គេឱ្យដើរជីកកណ្ដុរទៀត កណ្ដុរកាត់កន្ទុយឱ្យគេ។ បើអ្នកណារកមិនបានកណ្ដុរមួយ ១២ គឺឱ្យរកឱ្យបាន អត់មានបានពេលសម្រាកទេ។ អត់មានពេលបានដើរលេងអី បានដើរទៅកន្លែងចាស់ៗទេបាទ អត់។

**ស៖** ឥឡូវយើងផ្ដោតតែទៅលើឃ្លាំងសម្ភារៈរបស់វរៈនេះសិនបានហើយ។ គឺខ្ញុំសូម ខ្ញុំនឹងសួរឲ្យបានលឿនបន្តិចអំពីបញ្ហានេះ។ តើស្បែកជើង ឯកសណ្ឋាន និងអាវុធនៅក្នុងឃ្លាំងហ្នឹង<គេដាក់នៅកន្លែងណា>? តើគេដាក់ទុកនៅ<កន្លែងកណ្ដាលវាល? តើគេ>ដាក់ទុកនៅកន្លែងណា?

[០៩:២៧:០៨]

**ឆ៖** បាទ គេដាក់បន្ទប់ ដូចថាមួយបន្ទប់គេដាក់ មួយបន្ទប់គេរៀបមួយដុបៗអ៊ីចេះ ដាក់មួយដុបៗបាទ ស្បែកជើងមួយដុបទៅ ខោអាវគេចងជាបាច់ មួយដុំៗ ខោមួយដុំ អាវមួយដុំ។ ចុះមួយក្រុមវាតែ១២នាក់ទេ ១២នាក់ គេដាក់ខោ១២ទៅ អាវ១២ទៅ ដាក់មួយដុបទៅ មួយក្រុមទៅ។ ដាក់មួយក្រុមហ្នឹងគេដាក់លេខ គេដាក់កត់ជាលេខ ដាក់អក្សរថា នេះក្រុមនេះ នោះក្រុមនោះ វរសេនាតូច កងតូចនេះកងតូចនោះ ប៉ុណ្ណោះឯងទេបាទ។

**ស៖** បើខ្ញុំយល់មិនច្រឡំទេ របស់ទាំងអស់នេះគេដាក់នៅ<ក្នុង>បន្ទប់<ដោយគ្មានបិទបាំងអ្វីទេ?> មានន័យថាលោក<មិនបានទៅរុករកនៅកន្លែង>សម្ងាត់ <ឬកន្លែង>លាក់<បាំង ដើម្បីរកមើលឯកសណ្ឋាន និងអាវុធទាំងអស់នេះ>ទេ <តើ>មែនទេ?

**ឆ៖** បាទ នៅក្នុងបន្ទប់ ប៉ុនគេបើកទ្វារទៅ ហើយគេបើកទ្វាររៀបទៅ មួយដុបៗទៅខ្ញុំឃើញគេរៀប។ តែគេដាក់ក្នុងបន្ទប់ ដល់គេរៀបរួចទៅគេបិទបន្ទប់វិញភ្លឹបវិញបាត់ទៅ អត់មានពីណាដឹងទេ អត់ឲ្យណាដឹង ឃើញ ហើយកូនទាហានក៏គេមិនប្រាប់ថាកន្លែងនេះ កន្លែងនោះខោអាវដែរ អត់។ ខ្ញុំមានប៉ុណ្ណេះ។

[០៩:២៨:៥៦]

**ស៖** នៅពេលដែលលោកឃើញអ្នកដែលរៀបចំរបស់របរទាំងអស់ហ្នឹង អីវ៉ាន់ទាំងអស់ហ្នឹង តើពួកគេមានប្រាប់លោកថាឯកសណ្ឋាននិងរបស់របរទាំងអស់ហ្នឹង ទុកសម្រាប់ប្រើប្រាស់អ្វីដែរទេ?

**ឆ៖** គេប្រាប់ថាឯកសណ្ឋាននេះទុកសម្រាប់កងទ័ព។ កងទ័ព ខ្ញុំសង្ស័យថាកងទ័ព យើងលេងពាក់តែខោអាវមកពីចិន ហើយនិងខោអាវខ្មៅ ស្បែកជើងកង់ឡាន ដល់នេះវាគេឲ្យពាក់ស្បែកជើងគេទុករៀបចំស្បែកជើង អាស្បែកជើងទាហាន លន់ នល់ បានខ្ញុំឃើញរៀបអ៊ីចុះឯងមែនបាទ។

**ស៖** តើលោកមានបានសួរទៅអ្នករៀបចំរបស់របរហ្នឹង<ទេ>ថា <ហេតុអ្វី>បាន<ជាគេមាន>ឯកសណ្ឋានទាំងអស់ហ្នឹង<>?

**ឆ៖** ខ្ញុំបាទអត់បានសួរគេទេ ប៉ុន្តែឯកសណ្ឋាននោះ ប្រហែលជាគេរំដោះបានក៏គេទុក។ បើ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

តាមខ្ញុំនឹកឃើញ ខ្ញុំយល់ដឹងថា ឯកសណ្ឋានអស់ទាំងនោះដែលគេវើបាន ឬក៏គេដេរថ្មីម៉េចមិនដឹងទេ ក្រណាត់អត់ស្អាតទេ ក្រណាត់មិនមែនមកពីសហរដ្ឋអាមេរិកទេ ក្រណាត់គ្រើមៗ ទាំងខោក្រឡារាង មិនសូវជាអាធំៗដូចខោអាវប៉ារ៉ាសុញថ្ងៃទេ ក្រឡាល្អិតៗ ប៉ុនពីរធ្លាប់ ហើយសាច់គ្រើមៗ។ កាលនោះគឺមាន គេធ្វើកើតតើ គេឃើញគេធ្វើខោអាវគគីរ ខោអាវអី ខ្ញុំបើកលេខពាក់ដែរ បាទ។

[០៩:៣០:៥៤]

**ស៖** ខ្ញុំចូលទៅសួរចម្លើយរបស់លោកដែលលោកបានឆ្លើយជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកប្រធាននេះ គឺឯកសារ E3/7523, ERN ភាសាខ្មែរ 00061163, អង់គ្លេស 00875574, បារាំង 00884233។ លោកបានរៀបរាប់អំពីការដែលលោកបានឃើញឯកសណ្ឋានទាំងអស់នោះ លោកបាននិយាយដូចតទៅ សូមដកស្រង់៖ "ទើបតែក្រោយមកទេដែលខ្ញុំបានដឹងថាមានផែនការក្បត់" បញ្ចប់ការដកស្រង់។ តើហេតុអ្វីបានជាលោកឆ្លើយថា ទើបតែក្រោយមកទេដែលលោក<>បានដឹងថាមានផែនការក្បត់នោះ មានផែនការធ្វើរដ្ឋប្រហារនោះ?

**ឆ៖** បាទ ទើបតែក្រោយនោះបានខ្ញុំដឹងប្រាកដ ដោយសារគេចាប់មេៗទៅ គេថាពួកក្បត់ បានខ្ញុំដឹងត្រឹមនោះឯង ថាគេក្បត់ប្រាកដមែនទែនបាទ។ បានចាប់មេៗអស់ទៅហើយ គេថា សួរគេថាៗក្បត់។ ខ្ញុំថាតាមគេទៅ ដឹងក្បត់យ៉ាងម៉េច។

**ស៖** តើត្រឹមត្រូវដែរឬទេ នៅពេលដែលលោកឃើញឯកសណ្ឋាន <ស្បែកជើងកវែង>ជាមួយនឹងអាវុធហ្នឹង លោកមិនបានដឹងអំពីផែនការក្បត់នោះទេ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** ខ្ញុំសូមចូលទៅដល់ប្រធានបទមួយទៀត។ ពាក់ព័ន្ធទៅនឹងសំណួរអំពីលោក ខៀវ សំផន។ នៅមុន១៧ មេសា ឆ្នាំ៧៥ ឬក៏ក្រោយថ្ងៃហ្នឹង តើលោកធ្លាប់បានឃើញលោក ខៀវ សំផន នៅមុនថ្ងៃ ១៧ មេសា ឆ្នាំ៧៥ ឬក្រោយពេល -- ក្រោយថ្ងៃនោះដែរឬទេ បើសិនជាបានឃើញ សូមជម្រាបតុលាការ<ពីកាលៈទេសៈដែលលោកបានឃើញនោះ>?

**ឆ៖** បាទ ពីមុន៧៥ ពី៧២ ខ្ញុំឃើញ -- ខ្ញុំទៅយាមនៅ ខ្ញុំធ្វើឈ្លបៗគេហៅខ្ញុំទៅយាមការពារនៅភូមិតាមុំ កន្លែងរោងសិល្បៈគេ ក៏គាត់បានប្រជុំលើកឡើង គេធ្វើមីទិ្ទងមួយៗនៅនឹងភូមិតាមុំនោះឯង កាលនោះក៏ខ្ញុំធ្វើឈ្លបបានយាម យាមក៏គាត់បានអំពាវនាវឲ្យបងប្អូនក្រោកឈរឡើងតស៊ូដើម្បីធ្វើបដិវត្តន៍ការពារប្រទេសជាតិទាំងអស់គ្នា។ យើងខ្ញុំទាំងអស់គ្នាក៏ខំប្រឹងការពារ លះបង់ផង គេជំរុញ គេមិនឲ្យ

នៅទេ គេឱ្យមកធ្វើបដិវត្តន៍។ ក្រោយនោះមក ក៏ខ្ញុំ -- បងឈីៗ គាត់ខាងអាវុធឃោសនាអី ខ្ញុំក៏មិនស្គាល់ដែរ។ គាត់ថាបងៗមកពីថ្នាក់លើចូលមកធ្វើសន្និបាត ប្រជុំនោះឯង។ លេងពាក់ខោអាវខ្មៅៗ តែខ្ញុំមិនបាននៅបៀតដែរ ខ្ញុំឈ្លប ខ្ញុំយាមនៅឆ្ងាយ។ គេឱ្យខ្ញុំយាម បាទ។

[០៩:៣៥:២៦]

**សៈ** ពាក់ព័ន្ធនឹងការប្រជុំនៅភូមិតាមុំ លោកបានឡើងថា គាត់អំពាវនាវឱ្យប្រជាជនចូលរួមបដិវត្តន៍។ គាត់ហ្នឹង គឺជាអ្នកណាដែរ លោក? លោកអាចបញ្ជាក់បានទេ?

**ឆៈ** បាទ ខ្ញុំ កាលនោះ ឯអាវុធឃោសនាគេប្រាប់ថា ហ៊ូ យន់, ហ៊ូ នឹម ដែលកាលនោះ ពីរពីរនាក់ទេ។ ហើយនេះខ្ញុំ ក៏អត់ដឹងថា ហ៊ូ យន់, ហ៊ូ នឹម ទេ ព្រោះខ្ញុំមិនស្គាល់ដែរ នៅប្រជាជន ខ្ញុំនៅក្មេងដែរ គេឱ្យយាម ចេះតែយាម។ យាមហ្នឹង យាមការពារណ៎ា មិនឱ្យអ្នកណាទៅបៀតទេ។ កាលនោះ ស្លៀកពាក់ខ្មៅៗ ព្រួញទាំងបាច់ៗយាម។ មិនឱ្យអ្នកណាចូលបៀតបានទេ បាទ។ អានោះ ខ្ញុំយាមមែន នៅតាមុំ បាទ ភូមិតាមុំ។

**សៈ** តើ ខៀវ សំផន មានចូលរួមប្រជុំនោះដែរឬទេ? ហើយគាត់មានបានឡើងថ្លែងសុន្ទរកថាដែរឬទេ?

**ឆៈ** មានតែម្នាក់ទេ ឡើងថ្លែងសុន្ទរកថានោះ ប្រហែលជាមិនដឹងទេ បងណាមួយទេ អត់ចំណាំមុខច្បាស់ដែរ បាទ។

**សៈ** ខ្ញុំសូមអាននៅក្នុងកំណត់ហេតុ <ដែលលោកបានឆ្លើយជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត> លេខ E3/5149, ERN ជាភាសាខ្មែរ 00170634, អង់គ្លេស 00205044 ដល់ 45, បារាំងមានលេខ 00524399។ នេះជាអ្វីដែលលោកបានជម្រាបការិយាល័យសហចៅក្រមស៊ើបអង្កេត។ ខ្ញុំសូមដកស្រង់ចេញពីកំណត់ហេតុហ្នឹង "នៅមុនឆ្នាំ៧៥ ខ្ញុំបានឃើញ ខៀវ សំផន, ហ៊ូ នឹម ហើយនិង ហ៊ូ យន់ មកប្រជុំជាមួយនឹងប្រជាជននៅភូមិតាមុំ នៅជិតភូមិខ្ញុំ។ នៅពេលនោះ គាត់អំពាវនាវឱ្យប្រជាជនចូលបដិវត្តន៍។" បញ្ចប់ការដកស្រង់។ តើលោកនឹកឃើញទេ លោកសាក្សី? តើលោក ខៀវ សំផន នៅពេលនោះ បានចូលរួមប្រជុំជាមួយនឹង ហ៊ូ នឹម, ហ៊ូ យន់ ហើយក៏បានថ្លែងសុន្ទរកថាផងដែរ។ តើអ៊ីចឹងដែរឬទេ?

[០៩:៣៨:២៣]

**ឆៈ** បាទ ខ្ញុំបានឃើញថ្លែងអ៊ីចុះឯង មែន។ ប៉ុន្តែដូចខ្ញុំបានជម្រាបជូនហើយ ខ្ញុំនៅឆ្ងាយ ខ្ញុំនៅ

យាម។ ខ្ញុំឮតាមគេខាងអាវុធឃោសនាការគេប្រាប់ខ្ញុំថា ហ៊ូ យន់, ហ៊ូ នឹម, ខៀវ សំផន លោកអំពាវនាវឲ្យយើងធ្វើបដិវត្តន៍ ដើម្បីការពារប្រទេសជាតិទាំងអស់គ្នា។ លះបង់កូនចៅ លះបង់អាយុជីវិតដើម្បីប្រទេសជាតិ បាទ។ ទៅគាត់អំពាវនាវមែន ឲ្យពួកយើងចូលធ្វើបដិវត្តន៍។

**ស៖** កិច្ចប្រជុំនោះ លោកសាក្សី តើលោករួមជាមួយនឹងអ្នកភូមិត្រូវបានគេបង្ខំឲ្យចូលរួមនឹងខ្មែរក្រហមដែរឬទេ?

**ឆ៖** ក្រោយមក អាវុធឃោសនាគេចាប់បង្ខំហ្នឹងឯង បាទ។ ប្រជាជនមួយសានោះ ស្រេចគេបង្ខំខ្លះ អីខ្លះ នោះឯងបានចូល។ តែដូចខ្ញុំ មិនពិបាកអ្នកណាបង្ខំទេ ខ្ញុំមកត្រៀម ក៏ខ្ញុំចូលបណ្ដោយ។ ទៅក្រោយពិបាកដែរ ធ្វើខុសបន្តិច គេទិតៀនអីចេះមួយ អីចុះពីរ។ ប្រុងតែធ្វើដែរ ក៏ខ្ញុំចូលឲ្យហើយទៅបាទ។ មកគ្មានអ្នកណានៅទេ មានតែអ្នកពិការ ហើយអ្នកពុតត្បុតខ្លាំង អ្នកត្រចៀកក្រាស់ ដែលគេថាហើយមិនឈឺ អានោះពុតគេចបានរួច បើថាអ្នកត្រចៀកស្ដើង គ្មានអ្នកណាទ្រាំបានទេ ត្រូវតែមក ត្រូវតែចេញតស៊ូទាំងអស់គ្នា មានតែមុននិងក្រោយទេ បាទ។

**ស៖** លោកបានលើកឡើងខុសពីកំណត់ហេតុសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាបន្តិច។ ខ្ញុំសូមសួរបញ្ជាក់លោក នៅក្នុងឯកសារ E3/7523, ខ្មែរ ERN 00061141, <អង់គ្លេស>គឺ <00875546> ដល់47, បារាំង 00884211។ នេះជាអ្វីដែលលោកបានលើកឡើងនៅពេលនោះ <សំណួរ៖> “តើខ្មែរក្រហមអូសទាញលោក ឲ្យចូលសមរភូមិយ៉ាងដូចម្ដេចទៅ? លោកបានឆ្លើយថា ពួកគេបង្ខំយើង ហើយនៅពេលនោះ ពួកគេបង្ខំយើងឲ្យចូលរួម។ គ្មានអ្នកណាអាចនៅផ្ទះបាននោះទេ។ គ្មានអ្នកណាចង់ទៅនោះឡើយ។ មានមនុស្សមួយចំនួនតែប៉ុណ្ណោះអាចនៅក្នុងភូមិបាន ដោយសារតែគេបង្ខំអ្នកភូមិទាំងអស់ឲ្យចូលសមរភូមិ”។ បញ្ចប់ការដកស្រង់។ តើនរណាគេដែរ ជាអ្នកបង្ខំឲ្យអ្នកភូមិចូលសមរភូមិជាមួយនឹងកងទ័ពនាពេលនោះ?

[០៩:៤១:៥៤]

**ឆ៖** បាទ នៅពេលនោះ គឺមានពួក គេហៅថា អាវុធឃោសនាៗ គេដែលគេអាចជំរុញយើងឲ្យចូលធ្វើបដិវត្តន៍ គឺមានតែពួកអាវុធឃោសនាទេដែលអាចជំរុញពួកយើង បាទ។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំសូមសួរសំណួរពីរបីសំណួរពាក់ព័ន្ធទៅនឹងពេលដែលលោកនៅសមរភូមិភូមិភាគបូព៌ា។ ក្នុងពេលដែលលោកនៅខាងបូព៌ា តើលោកធ្លាប់បានឃើញការចាប់ខ្លួន ឬក៏ការកាប់សម្លាប់កម្មាភិបាលនៅភូមិភាគបូព៌ាដែរឬទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ ខ្ញុំបានឃើញ។ កាលនោះ ខ្ញុំនៅត្រពាំងផ្លុង ខ្ញុំអស់ថ្មតេអូៗ ខ្ញុំជិះម៉ូតូពីរនាក់ ពីរនាក់ មិត្តភក្តិ មិត្តភក្តិនោះកូនក្មេងទេ ខ្ញុំបបួលគាត់ជូនទៅ។ ជូនទៅដល់មន្ទីរឡផ្សូង មន្ទីរកងពលៗនោះ ក៏ខ្ញុំនៅតែអាកន្លែងអង់តែនធំ អង់តែនតេអូធំគេ អង់តែនឡាន -- សុំទោសខះកហើយ -- បាទ ឃើញគេដឹកទាហានបូព៌ា ចំណាស់ៗ ខ្លះវ័យចំណាស់ប្រហែលខ្ញុំ ខ្លះក្មេង ដឹកមកបីឡានៗ ហើយក៏ខ្ញុំ សួរ ណាំ នៅក្នុងកន្លែងតេអូ។ ថា ណាំ ឡាននោះគេដឹកពួកណា មកពីណា? ថា ហ៊ឺ ! គេដឹកពួកក្បត់។ មួយសន្ទុះក៏ឃើញគេហែកក្រមាៗ ហែក។ កាលនោះ ខ្ញុំហៅកន្សែង ខ្ញុំហែកកន្សែង រុំមុខគេចង។ ខ្ញុំឈរពីលើឡានពីលើឡាន អាតេអូហ្នឹងទៅ។ ក៏ ណាំ គាត់ថា អ្អែងទៅតិចទៅ! ខ្ញុំញ័រ ខ្ញុំអត់ហ៊ានទៅ។ ខ្ញុំថា អ្អ៊ែ! ខ្ញុំអត់ទៅទេ។ ភារកិច្ចខ្ញុំនៅសមរភូមិទេ។ ក៏គេថា អើអ្អែងមិនទៅ អ្អែងនៅចាំតេអូ? ខ្ញុំទៅ។ ទៅ ខ្ញុំអើតពីលើឡានទៅ ឃើញគេអូសរុញ រុញយកទៅក្រោយកន្លែង ខាងត្បូងមន្ទីរនោះឯង។ រុញទៅៗ ឮភឺសភូស អេះ! អុះ! យី! យុះ! មួយសន្ទុះ ប្រហែលជាមួយម៉ោង បាន ណាំ នោះគាត់មក។ មកខ្ញុំថា ណាំ ឯងមើលតេអូទៅ ខ្ញុំទៅកន្លែង អត់មានអ្នកណានៅកន្លែងទេ។ ក៏ថានោះថ្មតេអូយកទៅ។ ខ្ញុំបើកថ្មតេអូ ក៏ខ្ញុំមកកន្លែងខ្ញុំវិញ។ បាទ ប៉ុណ្ណោះឯង។

[០៩:៤៥:១៣]

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការយកទឹកជូនទៅសាក្សី គាត់ស្រេកទឹក។

*(មន្ត្រីតុលាការយកទឹកជូនសាក្សី)*

សូមអញ្ជើញលោកព្រះរាជអាជ្ញាបន្តសំណួរ។

**សួរដោយលោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**ស៖** លោកសាក្សី តើលោកបានឃើញ ឬក៏ធ្លាប់បានឮមានអ្វីកើតឡើងចំពោះទាហានដែលនៅខាងបូព៌ា ហើយគេដឹកតាមឡាន បីឡាន <ហើយដែលត្រូវគេយកចេញពីឡាន>នៅថ្ងៃនោះៗ?

**ឆ៖** បាទ ខ្ញុំឃើញអ៊ីចឹងមែន ខ្ញុំឃើញគេដឹកបីឡានចូលទៅក្នុងកន្លែង ៗនោះកន្លែងមន្ទីរកងពល ប៉ុន្តែកន្លែងគេ អាកន្លែងសហករណ៍គេ កន្លែងកងពលនោះទៅនៅ។ មានផ្ទះមួយធំ ផ្ទះមួយតែរោងទេ រោងបាយ គេដឹកចូលទៅក្នុងរោងអ៊ីចឹងទៅ គេប្រជុំមួយសន្ទុះ ប្រជុំអង្គុយតម្រៀបគ្នាអ៊ីចេះទៅក៏ ដល់គេហែកក្រមាចង គេអ្នកភ្លង់ៗទៅ អាអ្នកចងៗទៅ អាអ្នកបណ្តើរក៏បណ្តើរទៅ បណ្តើរយកទៅក្រោយ

កន្លែងមន្ទីរនោះទៅ ខ្ញុំដឹងតែប៉ុណ្ណោះឯង។ អាន៎ុងខ្ញុំឃើញប្រាកដនោះឯង បើខ្ញុំនិយាយមិនពិតសូមឱ្យរលាយទៅបាទ ព្រោះខ្ញុំឃើញប្រាកដមែន។

[០៩:៤៧:០៤]

**ប្រធានអង្គជំនុំ៖**

លោកមេធាវីការពារលោក ខៀវ សំផន។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំងើបឡើងនៅពេលនេះ ពីព្រោះខ្ញុំគិតថា យើងជិតខិតជិតទៅដល់អង្គហេតុដែលមិនស្ថិតនៅក្នុងសេចក្ដីសម្រេចនៃដីកាបំបែកនីតិវិធីហើយលោកប្រធាន។ ដូច្នេះ ខ្ញុំសូមជំទាស់នូវការសួរសំណួរទៅលើចំណុចនេះដោយសហព្រះរាជអាជ្ញា។ ប្រសិនបើសហព្រះរាជអាជ្ញាជំទាស់ ទៅនឹងការជំទាស់របស់ខ្ញុំហ្នឹង គាត់ត្រូវតែបញ្ជាក់ឱ្យបានច្បាស់ថា តើផ្នែកនៃដីកាបំបែកនីតិវិធីណាដែលពាក់ព័ន្ធនឹងហេតុការណ៍<នៅភូមិភាគបូព៌ា>ដែលគាត់បានសួរនេះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារលោក នួន ជា!

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាន ខ្ញុំក៏ចង់ក្រោកឈរដែរ ខ្ញុំចង់ក្រោកឈរដែរ ខ្ញុំឯកភាពជាមួយនឹងមេធាវីខៀវ សំផន។ <ជាការពិតហើយ ការបោសសម្អាត>កម្មាភិបាលខាងបូព៌ាគឺជាផ្នែកមួយនៃ<បទ>បញ្ហា<ធ្ងន់ធ្ងរ>។ តាមខ្ញុំយល់ទាហាននៅភូមិភាគបូព៌ានោះគឺថា ជាប់នៅមន្ទីរឃុំឃាំង<បី> រួមទាំងស-២១ ផងដែរ។ <ការប្រហារជីវិត ក៏ដូច>ជាឧក្រិដ្ឋកម្មសង្គ្រាម<>មិនមែនជា<ផ្នែកនៃបទបញ្ហាធ្ងន់ធ្ងរ ឬក៏មិន>ស្ថិតនៅក្នុងវិសាលភាពនៃ<ការ>ជំនុំជម្រះនៅពេលនោះទេ។ ដូច្នេះហើយសំណួរនីមួយៗពាក់ព័ន្ធនឹងបញ្ហានេះគួរតែហាមឃាត់។

[០៩:៤៨:៤៤]

**លោក ឌេល លីសាក់៖**

ខ្ញុំមិនទាន់បានសួរសំណួរផងលោកប្រធាន ហើយគាត់ជំទាស់ទៅនឹងសំណួរដែលខ្ញុំមិនទាន់នឹងសួរបន្ទាប់ផង។ ដូចដែលមេធាវីបានលើកឡើងហើយ ការបោសសម្អាតនៅភូមិភាគបូព៌ា គឺជាផ្នែកនៃអង្គហេតុ អ្នកដែលត្រូវបានគេ<ចាប់ខ្លួននៅអំឡុងពេល>បោសសម្អាតត្រូវបញ្ជូនទៅស-២១ ហើយអ្នក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

ផ្សេងទៀតនោះត្រូវបានគេបោសសម្អាតចាប់ខ្លួន ឬក៏សម្លាប់ចោលនៅភូមិភាគបូព៌ា។ ដូច្នេះ វាជាក្រុមមនុស្សតែមួយធ្វើប្រតិបត្តិការ<ទាំងអស់នេះ។ យើងមានសិទ្ធិក្នុង>ការស្រាវជ្រាវស្វែងរក <មូលដ្ឋាននៃ>ការបោសសម្អាត<នេះ>។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតសួរសំណួរបន្ទាប់ ហើយប្រសិនជាខ្ញុំសួរសំណួរបន្ទាប់នេះ នឹងបាន លោកប្រធាននឹងបានឮថា តើអ្នកណាជាអ្នក<>ចូលរួមធ្វើការបោសសម្អាត<នៅភូមិភាគបូព៌ា>។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សីការចាប់ខ្លួនមនុស្សដែលលោកបានឃើញ តើលោកបានដឹងទេ តើនរណាគេដែរជាអ្នកធ្វើការចាប់ខ្លួន<-->

**ប្រធានអង្គជំនុំ៖**

បដិសេធការជំទាស់ សូមលោកព្រះរាជអាជ្ញាបន្តសំណួរ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមអរគុណលោកប្រធាន សូមអធ្យាស្រ័យ។ តើលោកសាក្សី លោកដឹងទេ តើនរណាគេដែរជាអ្នកធ្វើការចាប់ខ្លួនទាហាននៅភូមិភាគបូព៌ា?

**ឆ៖** បាទ ដែលខ្ញុំបានដឹងគឺ កងបោសសម្អាត គេហៅថាកងបោសសម្អាត នៅខាងក្រោយ គឺកងទ័ពឧត្តរលាយជាមួយពួកនិរតីទាំងអស់ គ្រាន់ពួកនិរតីគេអ្នកក្តាប់ ខាងឧត្តរអត់មានក្តាប់ទេ សុទ្ធតែយុទ្ធជនដែលគេធ្វើការបោសសម្អាតនោះមួយកង។ មួយកងហ្នឹងគេដើរបោសសម្អាតតាមភូមិតាមអី គឺខ្ញុំគឺនៅសមរភូមិ គឺអត់មានកងបោសសម្អាតនឹងគេទេនៅខ្សែត្រៀមខាងមុខ តែចៃដន្យដែលខ្ញុំបានឃើញនោះ ខ្ញុំទៅយកថ្នូតេអូទេ។ ដែលខ្ញុំទៅយកថ្នូតេអូ ក៏ចៃដន្យ ក៏ខ្ញុំបានជួបគេតែមួយដងប៉ុណ្ណោះឯងបាទ។

[០៩:៥១:១៤]

**ស៖** តើលោកដឹងថាជាកងពិសេសដោយរបៀបណា? ហើយកងពិសេសនេះគេមកពីណាដែរ?

**ឆ៖** បាទ កងពិសេសនោះ នៅខាងកងពល៣១០នោះឯងបាទ។ កងពលគេក្តាប់ថ្មី ៣១០ចាស់នោះឯងបាទ។

**ស៖** តើប្រជាជននិងកម្មាភិបាលនេះ មកពីនិរតីតែភូមិភាគនិរតីតែមួយទេ ឬក៏មកពីកន្លែងផ្សេងទៀតដែរ?

**ឆ៖** បាទ អ្នកក្តាប់នោះ គឺមានតែមកតែពីនិរតីទេ អត់មានឧត្តរអត់មានក្តាប់ទេ។ ខាងបូព៌ា ក៏

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អត់មានដែរ មានតែខាងនិរតី ប្រធាន តាំងពីប្រធានកងធំ ប្រធានវរៈ ប្រធានកងពលរហូត ខាងឧត្តរ សុទ្ធតែយុទ្ធជន បាទអត់មានកម្មាភិបាលនឹងគេទេ។ បើកម្មាភិបាលគេចាប់យកទៅអស់ហើយ អត់មាន នៅទេ នៅសុទ្ធតែយុទ្ធជន បាទ។ អាហ្នឹងខ្ញុំដឹងតែប៉ុណ្ណោះហើយបាទ។

**ស៖** ខ្ញុំសួរលោកមុនហ្នឹងបន្តិច ថាតើមានអ្វីកើតឡើងចំពោះប្រពន្ធកម្មាភិបាល និងអ្នកដែលនៅក្នុងកងពល៣១០? តើលោកដឹងទេប្រពន្ធរបស់អ្នកនៅខាងបូព៌ាដែលគេបានចាប់ខ្លួន ហើយ<ចោទថាក្បត់>នោះ ជួបជោគវាសនាអ្វីដែរ?

[០៩:៥៣:០៨]

**ឆ៖** អារឿងប្រពន្ធកូនខាងបូព៌ាដែលគេចាប់បោសសម្អាតនោះ ខ្ញុំមិនដែលបានឃើញទេ ខ្ញុំឃើញតែមួយដងនោះឯង ឃើញតែទាហានបីឡាននោះឯងបាទ។ បើខ្ញុំនៅតែមុខ អត់ដែលបានមកក្រោយនេះទេ។ ហើយពីកន្លែងខ្ញុំមកកន្លែង ណាំ នោះ ប្រហែលជាបួនដប់គីឡូ ដើរម៉េចដល់ ខ្ញុំនៅតែក្នុងព្រៃ នៅតែក្នុងព្រៃ បាទ។

**ស៖** ក្នុងពេលដែលលោកនៅខាងបូព៌ា តើលោកធ្លាប់បានឃើញផ្ទាល់ភ្នែកនូវការចាប់ខ្លួនជនជាតិវៀតណាមដែរឬទេ? ប្រសិនបើធ្លាប់បានឃើញផ្ទាល់ភ្នែកនោះ តើលោកឃើញយ៉ាងម៉េចដែរ?

**ឆ៖** បាទ ខ្ញុំបានឃើញខ្លះដែរ ខ្ញុំឃើញពីរបីនាក់ដែរ គេឲ្យខ្ញុំយាម។ អាហ្នឹងគេចាប់មកពីក្នុងគេចូលទៅក្នុង គេចូលអាកងពិសេសគេ គេចូលប្រទេសវៀតណាម ខ្ញុំនៅឯក្រោយ។ ដល់គេចាប់វៀត-ណាមមកពីរបីនាក់អីចេះទៅ គេយកមកដាក់កន្លែងខ្ញុំៗក៏ជីកកន្លុក ជីកអីឲ្យវៀតណាមនេះឯងដេកការពារគ្រាប់ផ្លោង។ ដល់យាម គាត់ចេះតែយំៗទៅ ខ្ញុំ--

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសូមអភ័យទោស--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារលោក ខៀវ សំផន!

[០៩:៥៥:០៣]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជាថ្មីម្តងទៀត ខ្ញុំសូមជំទាស់ដោយមូលហេតុដូចខាងដើមអីចឹងដែរ អម្បាញ់មិញដែរ ព្រោះថាការវាយលុករបស់វៀតណាម -- វាយលុករបស់កម្ពុជាប្រជាធិបតេយ្យទៅ

លើវៀតណាមនោះ មិនមាននៅក្នុងវិសាលភាពនោះទេ។ ដូច្នេះ អ្វីដែលទាក់ទងទៅនឹងអង្គហេតុនៃការវាយលុកនេះ ក៏មិនចូលទៅក្នុងវិសាលភាពដែរ។ ដូច្នេះ<ធាតុផ្សំណាមួយពាក់ព័ន្ធនឹងអង្គហេតុនៃការឈ្លានពាននេះ ក៏មិនស្ថិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះនេះដែរ។> ខ្ញុំសូមនិយាយឲ្យមុនឲ្យហើយមុនពេលគាត់ឆ្លើយចម្លើយ ហើយនិងមុនសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ។ ខ្ញុំ<ចង់>សួរ<ពីគំនិតនោះក្នុងការ>និយាយបន្តិចអំពីអង្គហេតុនៅក្រៅវិសាលភាពនោះ។ ខ្ញុំមិន<យល់។ បើអង្គហេតុមិនស្ថិត>នៅក្នុងវិសាលភាព <ហើយបើ>វា<មិនស្ថិតនៅក្នុងផ្នែកនៃការពិភាក្សាដេញដោលដែលអង្គជំនុំជម្រះទទួលយកនោះ យើងមិនគួរធ្វើឲ្យខូចពេលវេលានោះទេ។> អ៊ីចឹង ខ្ញុំសូមជំទាស់ <>។

[០៩:៥៦:០៤]

**លោក ខេល លីសាក់៖**

ការប្រព្រឹត្តទៅលើជនជាតិវៀតណាម ជាផ្នែកមួយនៃរឿងក្ដីរបស់យើង។ ខ្ញុំមិនមែនសួរអំពីការលុកលុយចូលវៀតណាមនោះទេ។ ខ្ញុំគ្រាន់តែសួរថាតើវាកើតឡើងយ៉ាងម៉េចចំពោះប្រជាជនវៀតណាមដែលត្រូវបានចាប់ខ្លួន ហើយដាក់នៅក្នុងមន្ទីរនោះ តែប៉ុណ្ណោះ។ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារលោក ខៀវ សំផន។

**កញ្ញា អង់តា ហ្គីសសេ៖**

ដោយហេតុថា សាក្សីនេះ ទើបតែនិយាយថា ជនជាតិវៀតណាមទាំងអស់ហ្នឹង ទំនងជាត្រូវបានចាប់ខ្លួននៅពេលដែលវាយលុកចូលទៅ -- ខ្មែរក្រហមវាយលុកចូលទៅប្រទេសវៀតណាមនោះ។ អ៊ីចឹងវាក្រៅវិសាលភាពបាត់ទៅហើយ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ព្រោះអីមានទាហានត្រូវបានបញ្ជូនទៅស-២១។ ហេតុដូច្នេះ អង្គជំនុំជម្រះបដិសេធនឹងការជំទាស់។ សូមលោកចៅក្រម ហ្សង់ម៉ាក បន្ថែម។

[០៩:៥៧:០៩]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ ដើម្បីបំភ្លឺ យើងដឹងថាមានអ្នកទោសមួយចំនួន គេបញ្ជូនទៅមន្ទីរស-២១ ហើយគេចោទថាជនជាប់ចោទ -- អ្នកទោសទាំងអស់នោះ គេចាប់បាននៅប្រទេសវៀតណាម។ អ៊ីចឹង គឺថាវាមានអង្គ

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ហេតុពាក់ព័ន្ធគ្នាហើយ បានគេសួរយ៉ាងដូច្នេះនោះ។

**លោក ឌេល លីសាក់៖**

ខ្ញុំសួរបន្ត ហើយបញ្ចប់តែម្តង បន្ទាប់មក ខ្ញុំនឹងផ្តល់វេទិកាទៅដល់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សីលោកបានលើកឡើងថា ប្រជាជនវៀតណាមត្រូវបានគេយកមកកន្លែងលោក ហើយគេចាត់ឲ្យលោកយាម។ តើលោកពិពណ៌នាបានដែរឬទេ កន្លែងនុ៎ង ជាកន្លែងណាដែរ ដែលគេឃុំជនជាតិវៀតណាម ហើយលោកបានទៅយាមនៅកន្លែងនោះ។ តើកន្លែងហ្នឹងជាកន្លែងអ្វីដែរ? នៅកន្លែងណាដែរ?

**លោក សែម អ៊ំ៖**

**ឆ៖** បាទ កន្លែងនោះ គឺជាកន្លែងខ្សែត្រៀមទេ អត់មានកន្លែងធំដុំទេ កន្លែងប្រយុទ្ធគ្នា។ ដល់គេចាប់មកពីក្នុងមក គេដាក់កន្លែងខ្សែត្រៀមហ្នឹងឯង។ ដាក់កន្លែងខ្សែត្រៀមមួយយប់ រួចទៅ គេបញ្ជូនមកក្រោយ ខ្ញុំសួរថាគេយកទៅណា? គេយកទៅសម្លាសនៅក្រោយ។ តែក្នុងការសម្លាប់នោះ អត់ដែលឃើញមានទេ ឃើញតែគេបញ្ជូនមកក្រោយ។ គេយកមកសម្លាសតាមវិទ្យុ។ កាលនោះ ខ្ញុំលួចស្តាប់វិទ្យុឮគេសម្លាសមែន។ សម្លាសនៅតាមវិទ្យុ តែដឹងគេសម្លាសកន្លែងណា ខ្ញុំមិនដឹងទេ។

**ស៖** តើលោកដឹងថា មានអ្វីកើតឡើងចំពោះអ្នកទាំងអស់ហ្នឹង ក្រោយពេលដែលគេឃុំនៅមន្ទីរកន្លែងដែលលោកយាមហ្នឹង?

**ឆ៖** កាលកន្លែងគេយាម -- ឲ្យខ្ញុំយាមនោះ ដូចថា គេទុកផ្ញើនឹងខ្ញុំម៉ាយប់អី ទម្រាំគេមានពេលចេញមកក្រោយ គេនាំមកក្រោយទៀត។ ទុកមួយយប់ទៅ ខ្ញុំដឹកត្រង់សេ ដឹកឲ្យគាត់សម្រាកមួយយប់ទៅ ព្រឹកឡើងគេនាំពួកជនជាតិវៀតណាមហ្នឹងឯងមកក្រោយ។ ខ្ញុំសួរថាគេយកទៅណា? គេយកទៅសម្លាសបាទ តែរឿងគេសម្លាប់អី ខ្ញុំអត់ដែលបានឃើញទេបាទ។ នេះគឺនិយាយជាការពិត និយាយឲ្យត្រឹមត្រូវ កុំនិយាយ--

[០៩:៥៩:៣៩]

**ស៖** ដើម្បីឲ្យខ្ញុំ យើងទាំងអស់គ្នាយល់ច្បាស់។ តើអ្នកទាំងអស់នោះជាទាហាន ឬក៏ជាជនស៊ីវិល?

**ឆ៖** អ្នកទាំងអស់នោះ អត់មានទាហានទេ គឺប្រជាជន។ ប្រជាជន តាមខ្ញុំសួរអ្នកនាំមកថា គាត់មកកាប់ឈើ ដឹកឧស ឬក៏មករើសកស្រូវ។ គេដេញចាប់ប្រជាជនទេ អត់មានទាហានទេ។

**លោក ខេល លីសាក់៖**

សូមអរគុណ ដែលលោកបានចំណាយពេលវេលាឆ្លើយជូនខ្ញុំ លោកសាក្សី។

លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកព្រះរាជអាជ្ញា។ សូមអញ្ជើញលោកមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះសូមរំឭកដល់លោកមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី ក្រុមរបស់លោកមានតែពីរវគ្គទេ។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន ខ្ញុំគិតថា ខ្ញុំក៏មិនត្រូវការពេលវេលាច្រើនដែរ។ ខ្ញុំនឹងមានសំណួរតិចតួចទេ។ បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ភាគី ហើយសូមជម្រាបសួរទៅដល់លោកសាក្សី ខ្ញុំបាទឈ្មោះ ពេជ អង្គ ជាមេធាវី ជាមួយនឹងលោកស្រី ម៉ារី ហ្គីរ៉ូដ៍ តំណាងឲ្យក្រុមរួមនៃដើមបណ្ដឹងរដ្ឋប្បវេណី ដែលជាជនរងគ្រោះ។ ខ្ញុំមានសំណួរមួយចំនួនសម្រាប់សួរលោកសាក្សី។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោក ពេជ អង្គ៖**

**ស៖** នៅម្សិលមិញនេះ នៅវេលាម៉ោង ០៣:២៧នាទី លោកបាននិយាយថា មេរបស់លោកម្នាក់ ឈ្មោះ ហ៊ុន គាត់ធ្លាប់ទៅណានាំលោកទៅជាមួយ ក៏ប៉ុន្តែនៅពេលដែលគាត់រៀបការហើយគាត់ - -លោកឃ្លាតពីគាត់ មិនសូវបាននៅជិតគាត់ទេ។ ដូច្នេះ ខ្ញុំចាប់អារម្មណ៍រឿងបញ្ហាដែលលោកនិយាយថា គាត់រៀបការ។ អ៊ីចឹងលោកអាចបញ្ជាក់បានទេ គាត់រៀបការនៅឆ្នាំណា?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ។ សូមអញ្ជើញលោកមេធាវី ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំ តាមខ្ញុំស្ដាប់សាក្សីដែលបានបញ្ជាក់ មិនមែនឈ្មោះ ហ៊ុន ទេ ជាមេរបស់គាត់ គឺឈ្មោះ ហុន។ ដូច្នេះ សូមអាចកែសម្រួលចំណុចនេះ។ បាទ សូមអរគុណ។

[១០:០២:១៦]

**សួរដោយលោក ពេជ អង្គ៖**

**ស៖** បាទ គឺឈ្មោះ ហុន ហ្នឹងឯង។ លោកអាចបញ្ជាក់អំពីឈ្មោះហ្នឹងបានទេ ហើយគាត់រៀបការនៅឆ្នាំណាដែរ?

**លោក សែម អ៊៖**

**ឆ៖** បាទ ឈ្មោះ ហុន គាត់រៀបការនៅឆ្នាំ១៩៧៥ តែគាត់ការ កន្លែងគាត់ការហ្នឹង អត់ដឹងគាត់ការនៅឯណាផង ខ្ញុំអត់ដឹង។ ខ្ញុំឃើញគាត់នាំមក។ គាត់នៅផ្សេងទេដឹង ជាមួយខ្ញុំគឺជាប់ ដេកបន្ទប់មួយជាមួយគ្នា។ ដល់គាត់ការប្រពន្ធរួចគាត់បែកពីខ្ញុំ ខ្ញុំបែកពីគាត់។ បែកពីគាត់ទៅខ្ញុំ -- គាត់ឱ្យខ្ញុំនៅមួយក្រុមនៅគល់ស្ពានជ្រោយចង្វាហ្នឹងឯង។ ខ្ញុំនៅមួយក្រុម បានប្រហែលជា នៅស្ពានជ្រោយចង្វាហ្នឹងអត់មានទាហាន មានអីទេ ស្ងាត់ដូច--

**ស៖** បាទ ខ្ញុំសូមកាត់ប្រសាសន៍លោកតែម្តងទៅ។ ខ្ញុំសួរមានលក្ខណៈជាទូទៅបន្តិច លោកមានដឹងទេ នៅកន្លែងទាហានរបស់លោកមានការរៀបការទេ? ឬក៏ការប្តេជ្ញាចិត្តទេនៅពី៧៥ ដល់ ៧៩?

**ឆ៖** កាលនោះអត់មានទេ មានតែកម្មាភិបាល ហើយនិងកម្មាភិបាល និងអ្នកពិការ។ អ្នកពិការពិការភាព ពិការដៃ ពិការជើង បានអាចរៀបការបាន ហើយនិងកម្មាភិបាលគេ បានអាចរៀបការបាន។ បើយុទ្ធជន ដូចខ្ញុំ ដូចគេនេះ អត់មានបានទេ។

**ស៖** លោកមានបានដឹងអំពីការរៀបការនោះនៅពេលណាដែរទេ ការរៀបការកម្មាភិបាល ឬក៏អ្នកយុវជនពិការដែលលោកមានប្រសាសន៍អម្បាញ់មិញ?

**ឆ៖** បាទ ការរៀបការនោះ ឆ្នាំ៧៥ បានរំដោះ រំដោះប្រហែលជាមួយខែ ពីរខែបានគេរៀបការកម្មាភិបាលនិងយុទ្ធជនពិការហ្នឹងឯង។ តែមិនដឹងគេរៀបការកន្លែងណានោះ អត់ដឹងទេ។ ប៉ុន្តែឮថាស្វាយទាប។ គ្រួសារប្រពន្ធ បងហុន នោះគាត់ឈ្មោះ បងរី ១ នៅព្រៃកប្រសព្វ ឈ្មោះរី១។ កាលរៀបការ១នៅស្វាយទាប។ ប៉ុន្តែយុទ្ធជនពិការនោះមិនមែនរៀបជាមួយកម្មាភិបាលទេ រៀបដោយឡែក១អ្នកណាដែលពិការ គេអាចទុកចិត្តទៅគេរៀបឱ្យប្អូនប្រាំគូទៅ មិនមែនជាកងពលខ្ញុំទាំងអស់ទេ គឺមានកងគេខ្លះ ផ្សេង១ទៀត គេរៀបការ មិនមែនជាកងពលខ្ញុំតែប៉ុណ្ណោះទេ។ កងពលខ្ញុំឃើញ ខ្ញុំឃើញគេឈ្មោះ គាម មួយទេដែលពិការ គាត់ពិការជើង គេរៀបការឱ្យប៉ុណ្ណោះឯង។

[១០:០៥:៣៨]

**ស៖** បាទ អរគុណ។ ចំពោះករណីឈ្មោះ គាម ដែលពិការជើងហ្នឹង លោកមានដឹងទេ គាត់

01375072



ហើយនិងប្រពន្ធគាត់ដែលគេរៀបការឲ្យគាត់មានធ្លាប់ស្គាល់គ្នាពីមុនទេ? មុនដែលគេរៀបការឲ្យគាត់ហ្នឹង?

**ឆ៖** បាទ គាត់រៀបការរួច គាត់ឲ្យមកនៅក្នុងក្រុមជាមួយខ្ញុំ នៅស្ពានជ្រោយចង្វាឯង តែខ្ញុំតែងប្រជុំជីវភាពជាមួយគាត់ដែរ គាត់តែងនិយាយថា ប្រពន្ធអញអត់ដែលស្គាល់គ្នាទេ គេចេះតែចាប់បង្ខំរៀបការ ប្រពន្ធគាត់អត់ស្អាតដែរ ក៏គាត់ចេះតែយកហើយ។ ប៉ុន្តែគាត់អត់មានជំទាស់គ្នា ឈ្លោះគ្នាអីទេ គាត់ស្រឡាញ់គ្នារហូតដែលខ្ញុំបែកពីគាត់ទៅ ក៏គាត់នៅនឹងជ្រោយចង្វាហ្នឹងឯង ប៉ុន្តែមិនដឹងពីក្រោយមកដឹងគាត់ទៅណាទៅណីទៀត អត់ដឹងដែរ ព្រោះអត់ដែលបានជួបគ្នាក្រោយនោះមក គឺដាច់ម៉ាត់ខ្សែសង្វាក់គ្នា ឈប់បៀតគ្នាបានហើយបាទ គេដោយគេ ខ្ញុំដោយខ្ញុំ។ បាទ ប៉ុណ្ណោះឯង។

**ស៖** តើលោកអាចបញ្ជាក់បានទេ អម្បាញ់មិញលោកនិយាយអំពីការរៀបការជនពិការហ្នឹងនៅស្វាយទាប។ ស្វាយទាបហ្នឹងស្ថិតនៅកន្លែងណាដែរ? ខេត្តណា? ស្រុកណាដែរលោក?

[១០:០៧:១២]

**ឆ៖** ស្វាយទាបគឺខេត្តកំពង់ចាម ស្វាយទាបចំការលើហ្នឹង បាទលោកគ្រូ។

**ស៖** នៅពេលនោះគេមាន ពួកគាត់មាននិយាយទេថា ហេតុអ្វីបានជាគេគាត់រៀបការ ជនពិការហ្នឹង?

**ឆ៖** បាទ ខ្ញុំឮគាត់និយាយថា ឲ្យតែគេអ្នកពិការ គេអាចមានសិទ្ធិរៀបការបាន ហើយនិងកម្មាភិបាលគ្រប់អាយុ។ តែយុទ្ធជន គឺអត់មានរៀបគ្រួសារបានទេ អាយុដល់២០ជាង ២៥ ម្តេអីក៏អត់មានសិទ្ធិបានរៀបការទេ អត់បាន។

**ស៖** គាត់មានបាននិយាយថា នៅពេលដែលថា គាត់មានសិទ្ធិរៀបការហ្នឹង រៀបការដើម្បីធ្វើអ្វីទេ? ហេតុអ្វីបានគេចាប់ឲ្យពួកគាត់រៀបការជាមួយគ្នា? គោលបំណងអ្វីពេលចុងក្រោយ?

**ឆ៖** អារឿងត្រង់ណោះឯង គឺខ្ញុំមិនសូវដឹងដែរ រឿងគោលការណ៍ គោលបំណងរៀបការរបស់គេ តែគេចាប់ដឹងតែថា ជនពិការគឺសិទ្ធិរៀបការ ព្រោះគ្នាពិការហើយ ឲ្យមានគូស្រករទៅ ដើម្បីឲ្យមានកូនចៅតទៅមុខទៀត។ តែរៀបការរួចក៏គាត់មិនសូវបាននៅជាមួយគ្នាប៉ុន្មាន ជួនកាលប្រពន្ធគាត់មកលេងម្តងៗទៅ ប្រពន្ធហ្នឹងមិនដឹងនៅកន្លែងណាដែរ ខ្ញុំអត់ដឹង។ ជួនកាលក៏មិនដេកមួយយប់ ពីរយប់ទៅក៏គាត់ត្រឡប់ទៅវិញបាត់ទៅ។ ព្រោះកន្លែងខ្ញុំ គឺគ្មាននារីមាក់មួយទេ អត់ នៅតែប្រុសៗគ្នាឯង។

[១០:០៩:១២]

**ស៖** លោកមានប្រសាសន៍អម្បាញ់មិញគឺ រៀបការដើម្បីបង្កើតកូនចៅតទៅមុខទៀត។ ចុះចំណែកលោកវិញ លោកមានប្រសាសន៍អម្បាញ់មិញដែរថា អត់មានសិទ្ធិរៀបការ។ កាលណាគេនិយាយថា អត់មានសិទ្ធិរៀបការហ្នឹង តើលោកមានសិទ្ធិស្រឡាញ់នារីណាដែរឬទេ? ហើយមានសិទ្ធិស្នើដើម្បីរៀបការដែរឬទេ បើសិនបើមាន?

**ឆ៖** បាទ ជំនាន់នោះវាអាច បើមានសិទ្ធិក៏ចង់បានគេដែរ ប៉ុន្តែបើគេអត់ឲ្យមានសិទ្ធិ ក៏អត់តែប៉ុណ្ណោះឯង។ យុទ្ធជនទូទៅគឺអត់មានសោះ មានតែអ្នកពិការនិងកម្មាភិបាលប៉ុណ្ណោះឯង។

**ស៖** ខ្ញុំៗចង់សួរទៅលោកពីរបីសំណួរទៀត សូមលោកប្រធានអនុញ្ញាត។ នៅក្នុងកិច្ចសម្ភាសន៍របស់លោកដែលមានលេខឯកសារ E3/5149 សំណួរចុងក្រោយដែលលោកនិយាយថា អម្បាញ់មិញដែលថាលោក -- ខ្ញុំសូមអាន៖ “ពេលមួយនោះ នៅត្រពាំងខ្ពង់ ខ្ញុំបានទៅយកថ្មតេអ្វូ ខ្ញុំឃើញគេដឹកពួកទាហានភូមិភាគបូព៌ាបីឡានយកមក ខ្ញុំឃើញគេហែកកន្សែងចងមុខ និងចងស្ពាបសេក។ ខ្ញុំសួរ ណាំ ថាគេនាំពួកហ្នឹងទៅណា? ណាំ បានឆ្លើយថាពួកនោះ សុទ្ធតែពួកក្បត់ដែលត្រូវសម្លាប់។ ខ្ញុំបានឃើញគេសម្លាប់ពួកនោះដោយផ្ទាល់ភ្នែកដោយប្រើដែកភ្លោះទេះ។” អ៊ីចឹងលោកអាចបញ្ជាក់បន្ថែមខ្លីបានទេ លោកហេតុអ្វីបានជាលោកហ៊ានអះអាងថាពួកគាត់គឺជាទាហានបូព៌ា?

**ឆ៖** បាទ បានខ្ញុំហ៊ានអះអាងថាទាហានបូព៌ា ព្រោះខ្ញុំសួរ ណាំៗ គាត់ថាទាហាន ពួកទាហានបូព៌ា ពួកកងតំបន់ៗ--

**ស៖** បាទ អរគុណ--

**ឆ៖** បាទ សូមបំពេញបន្តិច។ ប៉ុន្តែស្លៀកពាក់ស៊ីវិល ខ្លះអត់មានអាវមានខោទេ មានតែក្រមាមួយ អត់មានខោអាវទាហានទេ ឃើញខ្លះចំណាស់ៗប្រហែលខ្ញុំនោះឯង ខ្លះក្មេងទៅ ខ្លះចាស់ ប៉ុនក្មេងតិចណាស់ មានអ្នកចំណាស់ៗច្រើនបាទ។

**ស៖** បាទ ខ្ញុំចង់សួរលោកពីរសំណួរថែមទៀត។ គឺអំពីករណីព្រឹត្តិការណ៍នៅវត្តស្លួង ខេត្ត ឥឡូវនេះខេត្តត្បូងឃ្មុំ។ តើលោកបានឃើញអ្វីនៅវត្តស្លួងហ្នឹង? នៅមន្ទីរពេទ្យស្លួង?

[១០:១២:៣៦]

**ឆ៖** បាទ ខ្ញុំដែលបានខ្ញុំទៅនៅមន្ទីរពេទ្យវត្តស្លួង ខ្ញុំរបួសនេះរបួសក របួសក្បាល គ្រាប់ផ្លោងវៀតណាម។ របួស គេបញ្ជូនខ្ញុំទៅសម្រាកពេទ្យនៅស្លួង តែខ្ញុំសម្រាកពេទ្យនៅស្លួងនោះ ខ្ញុំក៏បានឃើញខ្លះៗដែរអានេះ កាលពីមុន ក៏ខ្ញុំបានឆ្លើយទៀតដែរ ប៉ុន្តែពេលនេះ ខ្ញុំបាន--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារលោក នួន ជា -- មេធាវីលោក ខៀវ សំផន។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ត្រង់ចំណុចនេះដែរ ខ្ញុំសូមជំទាស់នឹងសំណួរទាំងអស់នេះ ពីព្រោះថាព្រឹត្តិការណ៍ទាំងអស់នេះវាមិនស្ថិតនៅក្នុងដីកាបំបែកសំណុំ -- កិច្ចដំណើរការនីតិវិធីនៃសំណុំរឿងយើងនេះទេ លោកប្រធាន។

**លោក ពេជ អង្គ៖**

បាទ លោកប្រធាន ចំណុចនេះគឺពិតជានៅក្នុងដីកា ដោយសារវាពាក់ព័ន្ធទៅនឹងការសម្អាតខ្មែរក្បត់ ហើយស្លួងគឺជាផ្នែកបូព៌ា ហើយដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿងតែម្តង។ សូមលោកប្រធានអនុញ្ញាត។

*(ចៅក្រមពិភាក្សាគ្នា)*

[១០:១៥:១៩]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបដិសេធការជំទាស់ ហើយសូមឲ្យមេធាវីសួរតែសំណួរមួយនេះបានហើយ។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** ខ្ញុំមានសិទ្ធិសួរតែមួយសំណួរទៀតទេ។ អ៊ីចឹង ខ្ញុំសូមសួរ អ៎! លើកអំពីចំណុចជាក់លាក់តែម្តង។ នៅក្នុងឯកសាររបស់លោកដែលលោកឆ្លើយទៅនឹងអ្នកសម្ភាសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានលេខ E3/7523 ហើយដែលមាន ERN 00875585, ជាភាសាបារាំង 00884241 ហើយនិងជាភាសាខ្មែរ 00061173។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមលើកឡើងអំពី ERN ម្តងទៀត លោកមេធាវី។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** ERN ជាភាសាខ្មែរ គឺ00061172, ជាភាសាអង់គ្លេស 00875585, ជាភាសាបារាំង 00884241។ នៅក្នុងផ្នែកដែលពាក់ព័ន្ធនោះ លោកថា ស្ត្រីជាច្រើនត្រូវបានគេយកទៅរំលោភនៅមន្ទីរពេទ្យស្លួង។ អ៊ីចឹងលោកអាចបញ្ជាក់បាន -- ហើយនៅក្នុងនោះក៏លោកបាននិយាយថា ពួកគាត់គឺជាខ្មែរ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ក្បត់។ តើលោកអាចបញ្ជាក់បានទេ ខ្សែក្បត់ ដែលលោកចង់ -- លោកអាចបញ្ជាក់បានទេ ស្ត្រីទាំងអស់នោះគឺមានចំនួនប៉ុន្មាននាក់? ហើយខ្សែក្បត់ហ្នឹង គឺលោកចង់សំដៅទៅលើស្ត្រីដែលលោកនិយាយថា ស្រីទាំងអស់នោះ គឺជាខ្សែក្បត់?

[១០:១៧:៣៨]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ!

សូមអញ្ជើញលោកមេធាវី ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំជំទាស់ម្តងទៀតហើយ លោកប្រធាន។ ខ្ញុំសូមឲ្យគាត់ពន្យល់ប្រាប់ខ្ញុំថា តើនៅក្នុងដីកាបំបែកកិច្ចដំណើរនីតិវិធីហ្នឹង មានចែងពីចំណុចដែលលោកមេធាវីហ្នឹងសួរត្រង់ណាដែរ?

**លោក ពេជ អង្គ៖**

បាទ ខ្ញុំពិបាកនឹងរកកថាខណ្ឌណាដល់កថាខណ្ឌ ដើម្បីបញ្ជាក់លោកស្រីអំពីបញ្ហានេះ ក៏ប៉ុន្តែសវនាការយើងរហូតមកពេលនេះ យើងនិយាយអំពីការធ្វើវិសុទ្ធកម្មទៅលើខ្សែក្បត់។ ដូច្នេះ យើងបាននិយាយច្រើនអំពីនេះ។ ហើយខ្ញុំមានការភ្ញាក់ផ្អើលដែលលោកស្រីមេធាវីសួរឲ្យខ្ញុំបញ្ជាក់ -- និយាយថា បញ្ហានេះមិនស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង។ ដូច្នេះខ្ញុំគិតថា បញ្ហាការធ្វើវិសុទ្ធកម្មទៅលើខ្សែក្បត់នេះ នៅតំបន់បូព៌ា គឺជាបញ្ហាមួយសំខាន់នៃសំណុំរឿង០០២ វគ្គពីរនេះ។ សូមលោកប្រធានអនុញ្ញាត។

*(ចៅក្រមពិភាក្សាគ្នា)*

[១០:១៩:២២]

**ប្រធានអង្គជំនុំ៖**

បដិសេធការជំទាស់។ ដោយសាររឿងនេះ វាពាក់ព័ន្ធនឹងគោលនយោបាយបោសសម្អាត។

សូមអញ្ជើញលោកមេធាវីបន្តសំណួរ។

លោកមេធាវី លោក ខៀវ សំផន ប្រសិនបើលោកឡើងមកជំទាស់នឹងបញ្ហាដដែល គឺមិនបាច់ទេ បើរឿងផ្សេង។ បាទ សូមអញ្ជើញ!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំពិនិត្យទៅលើលេខ ERN ជាភាសាខ្មែរ តាមការផ្តល់ដោយ

លោកមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីអម្បាញ់មិញនេះ គឺមិនមានចំណុចដែលដកស្រង់ទាក់ទងនឹងការសម្លាប់ ឬក៏វះពោះស្ត្រី ដូចការលើកឡើងរបស់លោកមេធាវីទេ។ នេះសូមបញ្ជាក់ឲ្យច្បាស់ផង។

**លោក ពេជ អង្គ៖**

បាទ ខ្ញុំសូមអានលេខឯកសារ ហើយនិង ERNសាជាថ្មី គឺឯកសារ E3/7523 ដែលជាកិច្ចសម្ភាសន៍របស់លោកសាក្សីរូបនេះ។ ហើយលេខឯកសារជាភាសាខ្មែរគឺ 00061173, ជាភាសាអង់គ្លេស 00875585, ជាភាសាបារាំង 00884241។ បាទ អ៊ីចឹងនៅក្នុងនោះគេបាននិយាយថា៖ "បើឃើញគេដាក់ឡានច្រើនដែរ កាលដែលខ្ញុំដេកពេទ្យនៅស្មោងហ្នឹងឃើញ អារ៉េម ជាអ្នកបញ្ជាដែរ។ អារ៉េម ប្រធានមន្ទីរ។ អារ៉េម ប្រធានមន្ទីរពេទ្យផង ហើយកាលខ្ញុំដេកពេទ្យ ក៏ឃើញគេចាប់នារីៗបូព៌ាមកសម្លាប់ក្នុងវត្ត។ កុមារតូចៗ គេថាទុកចិញ្ចឹមវាដល់ចាប់បោកនឹងកង់ឡានភូសៗស្រស់ៗ អារ៉េមកំបុតប៉ុណ្ណោះ។" បាទ អ៊ីចឹងកន្លែងនេះមានន័យថា គាត់បាននិយាយអំពីការចាប់នារីបូព៌ាមក។ បាទ មកសម្លាប់នៅក្នុងវត្ត។ អ៊ីចឹងខ្ញុំសូមសួរទៅសាក្សី ថាតើគេធ្វើអ្វីខ្លះទៅលើនារីដែលចាប់ពីបូព៌ា មកនោះ ហើយតើពួកគាត់មានគ្នាប៉ុន្មាននាក់ដែរ ដែលគេធ្វើទៅលើគាត់នោះ?

**ឆ៖** បាទ ពេលដែលគេចាប់នារីនោះ គឺថា ប្រពន្ធទាហាន ផើមៗ តែគេមិនហៅមកទេ យប់ជ្រៅស្ងាត់ គេអូសយកទៅពិសោធថ្នាំពេទ្យរបស់គេ នៅកន្លែងមន្ទីរពេទ្យ។ ពិសោធទៅ គេវះពិសោធមើល ចាក់ថ្នាំ ចាក់អី រស់វិញ គេសម្លាប់ចោលទៅ។ អាហ្នឹងខ្ញុំឃើញ ប្រាកដមែន ព្រោះខ្ញុំនៅដេកលើសាលា។ ហើយគេដឹកនារីនោះ តាមមុខផ្លូវ មុខសាលានេះឯង។ ហើយកន្លែងមន្ទីរគេ មន្ទីរគេខាងមុខសាលាដែរ ខាងមុខរាងខាងត្បូង អែបទៅខាងមន្ទីរពេទ្យរះកាត់ នៅស្នួលហ្នឹងឯង។ ហើយខ្ញុំដេកនៅលើសាលា។ តែយុទ្ធជនលបមើលដែរ គេប្រាប់ខ្ញុំ គេលបមើលឃើញ ក៏គេមកប្រាប់ខ្ញុំ ខ្ញុំក៏មិនដែលហ៊ានទៅលបមើលនឹងគេដែរ។ ប៉ុនគ្រាន់តែឃើញពីចម្ងាយ។ ប៉ុន្តែកាលនោះ តារ៉េម គាត់ក្តាប់មែន។ តារ៉េម គាត់ប្រធានមន្ទីរកងពល។ នៅពេទ្យស្នួល គាត់នៅក្នុងមន្ទីរពេទ្យនោះដែរ ពេទ្យស្នួល។ ទាំងប្រពន្ធកូនគាត់ តារ៉េម។ តារ៉េម គាត់កំបុតជើងម្ខាង។ អានោះ គឺខ្ញុំនិយាយតែរឿងពិត បានឃើញនឹងភ្នែកតែប៉ុណ្ណោះឯង។

[១០:២៣:៣៨]

**ស៖** បាទ សំណួរមួយផ្នែកទៀតរបស់ខ្ញុំដែលលោកមិនបានឆ្លើយ។ លោកអាចនិយាយបានទេ នារីមានផ្ទៃពោះដែលលោកថាផើមអម្បាញ់មិញ ពួកគាត់មានគ្នាច្រើនទេដែលគេចាប់យកទៅវះពោះ

នោះ?

**ឆ៖** គ្នានោះមិនច្រើនទេ ពីរនាក់ទេ ដែលខ្ញុំបានឃើញគេរះ។ វះពិសោធឆ្នាំនោះ ពីរនាក់បាទ។ ហើយនិង ខ្ញុំឮដូចថា កុមារនោះពីរនាក់។ កុមារនោះ ស្អាតៗទុកចិញ្ចឹម តាវ៉េម គាត់ទុកចិញ្ចឹម។ មិនដឹងម៉េចគាត់ ស្រាប់គេ ពួកពេទ្យៗហ្នឹងឯង លេងប្រលែង ថើបលិច ថើបកើតទៅ គាត់ជិះម៉ូតូមកពីណា គាត់បញ្ជាពួកនោះឯង ឲ្យចាប់បោកនឹងកង់ឡានក្បែរទឹក ក្បែរស្រះវត្ត វត្តស្នួង។ បាទ ប៉ុណ្ណោះឯងខ្ញុំដឹងប៉ុណ្ណោះអស់។

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកសាក្សីដែលបានឆ្លើយនឹងសំណួររបស់ខ្ញុំ។

លោកប្រធាន ខ្ញុំអស់សំណួរហើយ សូមអរគុណលោកប្រធាន។

[១០:២៤:៥៣]

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។

លោកមេធាវីការពារលោក ខៀវ សំផន តើលោកមានសំណួរចំពោះសាក្សីនេះទេ?

**កញ្ញា អង់តា ហ្គីសសេះ**

យើងមានសំណួរលោកប្រធាន យើងនៅសល់ពេលប្រហែលជា ២០នាទីជាងដែរ បើតាមយើងធ្វើការគណនាទៅ សល់ពេលពីលោកមេធាវី កូប៉េ ហ្នឹងលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

តាមការគិតគូររបស់អង្គជំនុំជម្រះឃើញថាលោកនៅសល់ប្រហែលជា១០នាទីទេ លោកមេធាវី។

អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទីគិតចាប់ពីពេលនេះតទៅ។ សូមអញ្ជើញសម្រាក!

*(សវនាការសម្រាកពីម៉ោង ១០:២៥ នាទី ដល់ម៉ោង ១០:៤៣ នាទី)*

[១០:៤៣:៤៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

សូមអញ្ជើញលោកមេធាវីការពារលោក ខៀវ សំផន មានសំណួរលើសាក្សី។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ មុនចាប់ផ្ដើម ខ្ញុំយល់តាមរយៈចម្លើយរបស់លោក លោកប្រធានថា យើងខ្ញុំមានតែ១០នាទីទេ។ ក៏ប៉ុន្តែសហព្រះរាជអាជ្ញា និង ដើមបណ្ដឹងរដ្ឋប្បវេណីបានបញ្ចប់<នៅប្រហែលម៉ោង១០:២៥នាទី គឺគេបានប្រើពេលជាងពីរវគ្គ>។ អ៊ីចឹង ខ្ញុំសូមលោកថាមេត្តាផ្ដល់ឱ្យខ្ញុំ១០នាទីបន្ថែមទៀត លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីនាំមុខតំណាង -- ខ្ញុំជាសហមេធាវីការពារក្ដីលោក ខៀវ សំផន។ ខ្ញុំនឹងសួរសំណួរបន្ថែម។ ខ្ញុំនឹងត្រឡប់មកសួរនៅប្រធានបទមួយចំនួនដែលបានឆ្លើយជូនសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។ លោក<បាននិយាយអំពីអ្វីដែល>លោកបានឃើញមន្ទីរពេទ្យស្នួង។ អ៊ីចឹងខ្ញុំដឹងថា តើមន្ទីរពេទ្យស្នួងហ្នឹងស្ថិតនៅភូមិណាស្រុកណា ខេត្តដែរ? មន្ទីរពេទ្យហ្នឹង តាមលោកឆ្លើយហ្នឹងថាជាអតីតវត្តមួយ។

[១០:៤៥:៤១]

**លោក សែម អ៊ំ៖**

**ឆ៖** បាទ មន្ទីរពេទ្យនោះ គឺមិនមែនមន្ទីរពេទ្យទេ គឺវត្ត១លោក បាទ។ វត្តមានចេតិយមានអីមានខ្មោច ពេញតែហ្នឹង វត្តលោក។

**ស៖** លោកនិយាយថា កន្លែងហ្នឹងជាចេតិយ។ អ៊ីចឹង ខ្ញុំចង់ដឹងថា កន្លែងហ្នឹងស្ថិតនៅឃុំណាស្រុកណា និងតំបន់ណា? លោកអាចឆ្លើយបញ្ជាក់ឱ្យបានច្បាស់ ព្រោះថាយើងអត់ស្គាល់ប្រទេសកម្ពុជាទេ អ៊ីចឹងសូមរៀបរាប់ឱ្យច្បាស់ផង ថានៅក្នុងឃុំណា ស្រុកណា តំបន់ណា និងភូមិភាគណា?

**ឆ៖** ខ្ញុំអត់បានស្គាល់ដែរឃុំ ស្គាល់តែវត្តស្នួង ខេត្តកំពង់ចាម មុនខេត្តកំពង់ចាម។ អារឿងភូមិអ៊ំ! ភូមិស្នួង វត្តស្នួង ខេត្តកំពង់ចាម ឃុំអត់ដឹង អត់ស្គាល់។ បើកាលនោះ មិនដឹងមានឃុំអីឯណាអត់។

01375079



**ស៖** ស្ត្រីដែលឃើញ ដែលលោកថា មានផ្ទៃពោះហ្នឹង លោកស្គាល់គាត់ទេ?

**ឆ៖** អត់ស្គាល់ទេ ព្រោះគេយកមកពីណាពីណីធ្វើម៉េចនឹងស្គាល់ បើខ្ញុំអ្នកឆ្ងាយដែរ។ អត់បានស្គាល់គាត់ផង។ គ្រាន់តែឃើញស្ត្រីផ្ទៃពោះៗ ថាប្រពន្ធកម្មាភិបាល ប៉ុណ្ណោះឯងទេ។

**ស៖** អ្នកណាជាអ្នកប្រាប់លោកថា គាត់ហ្នឹងជាប្រពន្ធកម្មាភិបាល?

**ឆ៖** ពួក តារ៉េម ហ្នឹងឯង ពួកបងរ៉េម ហ្នឹងប្រាប់ថាប្រពន្ធកម្មាភិបាល។

**ស៖** លោកថាពួក បងរ៉េម ហ្នឹងពួកហ្នឹងមានមុខងារអ្វីដែរ? អ៊ីចឹង ខ្ញុំចង់សួរបញ្ជាក់ឲ្យច្បាស់អ៊ីចេះសិនថា អ្នកដែលលោក -- និយាយប្រាប់លោកហ្នឹង មានតែម្នាក់ ឬក៏ច្រើននាក់ ហើយគាត់មានតួនាទីអ្វីដែរ?

[១០:៤៨:៣៥]

**ឆ៖** តែម្នាក់ តារ៉េម ហ្នឹងគាត់ប្រធានមន្ទីរ។ ប្រធានមន្ទីរកងពលផង ប្រធានមន្ទីរពេទ្យផង គាត់ក្តាប់ទាំងអស់។

**ស៖** លោកបាននិយាយថា ពួកបងរ៉េម អ៊ីចឹងបានន័យថាគ្នាច្រើនហើយ។ អ៊ីចឹង ខ្ញុំស្តាប់ច្រឡំឬយ៉ាងម៉េចដែលថា ដំបូងលោកថា ពួកបងរ៉េម ហ្នឹងប្រាប់លោក<ថា ស្ត្រីទាំងអស់នោះមកពីកន្លែងផ្សេង ហើយជាប្រពន្ធរបស់កម្មាភិបាល>។ អ៊ីចឹង ខ្ញុំសូមសួរបញ្ជាក់ឲ្យច្បាស់ថា អ្នកណាជាអ្នកប្រាប់លោក?

**ឆ៖** គឺបងរ៉េមៗ ប៉ុន្តែតាមទំនៀមទម្លាប់ ខ្មែរខ្ញុំៗហៅពួក – ពួកបងរ៉េម។ បងរ៉េម ហ្នឹង គឺក្រុមពេទ្យរបស់គាត់ហ្នឹងឯង គាត់ស្រីៗប្អូនដប់នាក់ ប្អូនប្រាំនាក់ទេ -- ប្អូនដប់នាក់ ពេទ្យនោះ ស្រីៗ។ ប៉ុន្តែ បងរ៉េម គាត់ប្រធាន។ បងរ៉េម នោះគាត់និយាយថា ប្រពន្ធកម្មាភិបាល ប៉ុន្តែទម្លាប់ខ្ញុំហៅ “ពួកៗ” នុំង គឺថាទម្លាប់អ៊ីចុះហើយ ខ្ញុំហៅពួកអ៊ីចឹងឯង។

[១០:៥០:០៤]

**ស៖** បើអ៊ីចឹង ឥឡូវខ្ញុំសួរលោកអ៊ីចេះវិញថា ក្នុងចំណោមពួក បងរ៉េម ហ្នឹង អ្នកណាជាអ្នកប្រាប់លោកអំពីរឿងថាស្ត្រីហ្នឹងជាប្រពន្ធកម្មាភិបាលនោះ?

**ឆ៖** បងរ៉េម ហ្នឹងឯងគាត់អ្នកប្រាប់ គាត់ប្រាប់ថា ពួកនេះសុទ្ធតែប្រពន្ធកម្មាភិបាលកងធំ កងអីគេចាប់យកទៅសម្លាប់ចោលហើយ ថាអ៊ីចេះ។ ចាប់បងៗ -- ប្តីៗអស់ទៅ នៅប្រពន្ធហ្នឹង ប្រពន្ធមានផ្ទៃពោះ ក៏គេចាប់យកមកពិសោធថ្នាំនោះឯង។ តែមិនច្រើនទេ ខ្ញុំឃើញតែពីរនាក់ទេ ហើយកុមារពីរ

នាក់ប៉ុណ្ណោះឯង។

**ស៖** បាទ អ៊ីចឹងបានន័យថា បងរ៉េម ផ្ទាល់ជាអ្នកប្រាប់រឿងនេះដល់លោក។ ហើយពេលហ្នឹង នៅមន្ទីរពេទ្យហ្នឹង លោកធ្វើអីដែរ?

**ឆ៖** ខ្ញុំអត់មានធ្វើអី ខ្ញុំអ្នកជំងឺ ខ្ញុំរបួសៗខ្ញុំសម្រាកពេទ្យ បាទ។

**ស៖** លោកគ្រាន់តែអ្នកជំងឺ។ អ៊ីចឹង រ៉េម ហ្នឹងគាត់មកនិយាយរឿងហ្នឹងប្រាប់លោកហ្នឹងនៅពេលណាដែរ?

**ឆ៖** ពេលថ្ងៃដែលខ្ញុំសម្រាកពេទ្យ។ តែខ្ញុំសូមរៀបរាប់ពី រ៉េម នោះគាត់ៗប្រធានមន្ទីរកងពលនោះ ខ្ញុំធ្លាប់នៅជាមួយគាត់ កាលនៅក្រុងភ្នំពេញ គេឲ្យខ្ញុំទៅ ខ្ញុំឆ្លើយហើយតើ ខ្ញុំ នែ! គេឲ្យខ្ញុំទៅរៀនតេអូ គាត់នោះឯងអ្នកក្តាប់នោះ រ៉េម នោះឯង គាត់ប្រធានមន្ទីរ បាទបានខ្ញុំស្គាល់គាត់។ គាត់កំបុតជើងម្ខាង។ គាត់អ្នកក្តោបក្តាប់ខ្ញុំ មែនគាត់ក្តាប់កងពល ហើយខ្ញុំនៅក្នុងមន្ទីរកងពលដែរ នៅកាន់តេអូ ប៉ុនខ្ញុំនៅតែជួរមុខកាន់កាំភ្លើងធំ។

**ស៖** លោកអាចបញ្ជាក់ឲ្យបានច្បាស់បន្តិចទេថាមន្ទីរពេទ្យ ឬក៏វត្តហ្នឹងស្ថិតនៅក្នុងភូមិភាគណាដែរ?

[១០:៥២:៥៩]

**ឆ៖** វត្តនោះស្ថិតនៅភូមិភាគឧត្តរ -- អ៎! ភូមិភាគបូព៌ា (បាទច្រឡំ) ភូមិភាគបូព៌ា វត្តៗស្ទួង។ ស្ទួងពីដើមវាខេត្តកំពង់ចាម ភូមិភាគបូព៌ា បាទ។

**ស៖** នៅក្នុងចម្លើយរបស់លោកជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ឯកសារ E3/7523, ERN ជាភាសាបារាំង <00884241>, ជាភាសាខ្មែរ 00061173 ទៅដល់74, ជាភាសាអង់គ្លេសគឺ 00875586 លោកបានឆ្លើយថា លោកបានឮគេនិយាយអំពីរឿងហ្នឹងៗ គឺលោកនៅភូមិភាគនិរតី។ អ៊ីចឹងកាលហ្នឹងគេសួរលោកថាលោកនៅឯណាពេលលោកឮរឿងហ្នឹង លោកថាលោកនៅនិរតី។ អ៊ីចឹងលោកអាចបញ្ជាក់ឲ្យបានច្បាស់បន្តិចទៅមើល ម៉េចក៏ពេលហ្នឹង លោកឆ្លើយថានៅភូមិភាគនិរតី ហើយឥឡូវលោកថានៅភូមិភាគបូព៌ានេះ?

**ឆ៖** ខ្ញុំអត់បានឆ្លើយនៅភូមិភាគនិរតីឯណាអត់ទេ។ ខ្ញុំឆ្លើយថាខ្ញុំទៅនៅ វ៉ៃនៅសមរភូមិ ប៉ុន្តែខ្ញុំរបួស ខ្ញុំមកសម្រាកនៅមន្ទីរពេទ្យភូមិភាគបូព៌ាបាទ។ រឿងនិរតីនៅឯលិចនេះទេ អត់មាននៅតំបន់នោះ។

**ស៖** តើលោកបានឃើញដោយផ្ទាល់ភ្នែកនូវការវះកាត់ស្ត្រីរូបហ្នឹងទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ខ្ញុំបានឃើញផ្ទាល់ភ្នែក ខ្ញុំទៅលួចមើល។ ពេទ្យគេអត់ឱ្យមើលទេ ប៉ុន្តែលួចៗ -- ជញ្ជាំងពេទ្យកាលនោះ គឺគ្មានជញ្ជាំងក្តារ ជញ្ជាំងស្អីទេ គឺជញ្ជាំងស្លឹក។ ជញ្ជាំងស្លឹក ហើយគេបាំងកៅស៊ូ បាំងតង់ក្រៅៗ ខ្ញុំលួចមើលតាមបង្អួចនោះ គេអូសរទេះ គេវះរួច គេអូសរទេះចេញ រទេះរុញ អាររទេះរុញចេញមកក្រៅ បាទ។ គេយកទៅកប់ចោល។ អាហ្នឹង ខ្ញុំឃើញប្រាកដ មែន បាទ។ ខ្ញុំមកនៅសម្រាកពេទ្យប្រហែលជាមួយខែជាងៗ បានខ្ញុំទៅកន្លែងសមរភូមិមុខវិញ បាទ។

[១០:៥៦:២២]

**ស៖** លោកឆ្លើយថាលោកជាអ្នកជំងឺ។ អ៊ីចឹង ឥឡូវ ខ្ញុំចង់អាននូវឃ្លាមួយរបស់លោក។ គឺនៅ ERN ដដែល ដូចខ្ញុំបានបញ្ជាក់អម្បាញ់មិញនេះ គឺឯកសារ E3/7523។ "ខ្ញុំឃើញការសម្លាប់ហ្នឹងដោយចៃដន្យ ពីព្រោះខ្ញុំដើរទៅរកថ្នាំតេអូ ហើយខ្ញុំទៅមួយភ្លែតទេ។ គេក៏សួរលោកថា៖ ពូឃើញប៉ុន្មានដង? ពេលនោះលោកឆ្លើយថា៖ ឃើញតែម្តងទេ។ គេក៏សួរលោកតទៅទៀតថា៖ តែម្តងទេ? លោកក៏ឆ្លើយថា៖ បើឃើញគេដាក់ឡាន ច្រើនដងដែរ កាលដែលខ្ញុំដេកពេទ្យ<>ហ្នឹង ឃើញ អារ៉េមវាជាអ្នកបញ្ជា។ អារ៉េមហ្នឹងប្រធានមន្ទីរផង ប្រធានមន្ទីរពេទ្យផង ហើយកាលខ្ញុំដេកពេទ្យ ឃើញគេចាប់ នារីៗបូព៌ាយកមកសម្លាប់ក្នុងវត្ត។" សូមបញ្ចប់ការដកស្រង់។ ដូច្នេះ សំណួរដំបូងពាក់ព័ន្ធនឹងចំណុចនេះ ខ្ញុំចង់សួរលោកថា លោកបានផ្សាភ្ជាប់ការដែលលោកឃើញការសម្លាប់មនុស្ស នៅពេលដែលទៅរកថ្នាំតេអូ ហើយក្នុងពេលដដែលនោះលោកបាននិយាយថា លោកជាអ្នកជំងឺនៅពេទ្យហ្នឹង។ លោកអាចពន្យល់ត្រង់ចំណុចហ្នឹងឱ្យបានច្បាស់បន្តិចបានទេ?

[១០:៥៨:០០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក -- សាក្សីកុំអាលទាន់ឆ្លើយ! សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

ខ្ញុំមិនប្រាកដថាមេធាវីលើកឡើងដោយចេតនា ឬក៏អត់នោះទេ។ ក៏ប៉ុន្តែសម្រង់ពាក់ព័ន្ធទៅនឹងការសម្លាប់<ដែលគាត់បានឃើញ> នៅពេលដែលគាត់ទៅយកថ្នាំរ៉ាដ្សនោះគឺ -- យកថ្នាំតេអូ គឺគាត់បានផ្តល់សក្ខីកម្មពីខាងដើមមកហើយ គឺមានឡានទាហានលន់ នល់។ <ទាំងអស់នេះជាសំណួរដែលសួរក្រោយពេលគាត់បាននិយាយរឿងនោះចប់> ហើយ<បន្ទាប់មក>ឈានចូលដល់ប្រធានបទថ្មី ពាក់ព័ន្ធទៅនឹងការសម្លាប់នៅមន្ទីរពេទ្យស្លូងនោះ គឺមេធាវីការពារក្តីមិនគួរសួរ<លើកឡើងថា សំណួរទាំងនោះ

ពាក់ព័ន្ធគ្នានោះទេ>។

[១០:៥៨:៥៧]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំចង់ឲ្យសាក្សីជាអ្នកឆ្លើយវិញ មិនមែនឲ្យលោកសហព្រះរាជអាជ្ញាឆ្លើយជំនួសសាក្សីទេ សាក្សីគាត់នៅទីហ្នឹងហើយ។

**ស៖** អ៊ីចឹង ខ្ញុំសួរដដែល លោកសាក្សី សំណួរអម្បាញ់មិញហ្នឹង សូមលោកឆ្លើយ?

**លោក សែម អ៊ំ៖**

**ឆ៖** បាទ ខ្ញុំសូមឆ្លើយថា រឿងនេះដាច់ដោយឡែកពីគ្នាទេ។ រឿងឡានបីនោះ គឺកន្លែងឡធ្យូង វាដាច់គ្នាប្រហែលជា២០គីឡូជាងពីវត្តស្លង។ កាលនោះមុន អានោះជារឿងមុន បាទ។ អារឿងខ្ញុំសម្រាកពេទ្យនោះ អានោះ ខ្ញុំអ្នកជំងឺមែន បាទ។ អានេះ ខ្ញុំឲ្យដាច់ដោយឡែក ហើយលោកថា ខ្ញុំនិយាយតែម្តងតែខ្ញុំនិយាយដាច់ដោយឡែក។ អាលើកវគ្គមុន ឡធ្យូង។ វគ្គលើកក្រោយនេះ គឺខ្ញុំរបួសសម្រាកពេទ្យនៅវត្តស្លង។ អានេះវាពីរៗកន្លែង បាទ។ ខ្ញុំសូមជម្រាប។ មិនមែនតែមួយកន្លែងទេ ពីរកន្លែង។ ហើយឡធ្យូងមួយកន្លែង ខ្ញុំបានបំភ្លឺរួចហើយ។ ហើយនៅវត្តស្លងនេះឯង ទើបតែសួរនេះបាទ។ ខ្ញុំសូមអស់។

[១១:០០:២០]

**ស៖** លោកៗឆ្លើយថា លោកមិនស្គាល់ស្ត្រីទាំងអស់ហ្នឹងទេ ហើយ អារ៉េម ជាអ្នកពន្យល់ប្រាប់លោក។ អ៊ីចឹងពេលនោះ រ៉េម ហ្នឹង គាត់ជាមេរបស់លោក <តើត្រឹមត្រូវ>ទេ?

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ថា រ៉េម ហ្នឹងគាត់ប្រធានមន្ទីរ។ ខ្ញុំៗទៅរៀនតេអូ ខ្ញុំនៅ -- គាត់ក្តោបក្តាប់ខ្ញុំ។ ពេលដែលខ្ញុំបែកពីគាត់ទៅកាន់តេអូ ខ្ញុំរបួស ខ្ញុំទៅសម្រាក ខ្ញុំជួបនឹងគាត់។ គាត់នៅកាន់មន្ទីរពេទ្យនៅវត្តស្លងនោះដែរបាទ។

**ស៖** ពេលដែលគាត់និយាយរឿងស្ត្រីហ្នឹងប្រាប់លោកហ្នឹង គឺក្នុងពេលប្រជុំ ឬក៏គ្រាន់តែក្នុងពេលជជែកគ្នាលេងធម្មតាទេ?

**ឆ៖** អត់មានប្រជុំទេ ខ្ញុំដើរទៅ ក៏ខ្ញុំសួរថា នារីនេះយកមកពីណា? គាត់ថា ហ៊ឺ! សុទ្ធតែប្រពន្ធកម្មាភិបាល។ ប៉ុណ្ណោះឯង និយាយតាមផ្លូវ តាមមុខកន្លែងមន្ទីរពេទ្យហ្នឹងឯង មិនមែនទៅមានអង្គប្រជុំអីធំដុំ អត់មានទេបាទ។

**ស៖** តើ រ៉េម មានបានប្រាប់លោកថា ស្ត្រីទាំងអស់ហ្នឹងជាប្រពន្ធរបស់កម្មាភិបាលណាខ្លះទេ?

គាត់មានបានរៀបរាប់ប្រាប់ឈ្មោះកម្មាភិបាល ហើយនិងមុខងាររបស់កម្មាភិបាលទាំងអស់ហ្នឹងទេ?

[១១:០២:១៥]

**ឆ៖** អត់ដឹងទេ អត់បានប្រាប់។ តារ៉េម ក៏គាត់មិនស្គាល់ដែរ ព្រោះខាងបូព៌ា និងនិរតីវាឆ្ងាយពីគ្នាដែរ មានទៅស្គាល់គេឯណា គ្រាន់តែស្គាល់ គេដឹងថាប្រពន្ធកម្មាភិបាល ព្រោះគេអ្នកដឹកនាំកន្លែងមន្ទីរពេទ្យនោះឯង គេហ្នឹងហើយអ្នកបញ្ជាឲ្យក្រុមពេទ្យ យកមកនោះ បាទ។ <>

**ស៖** លោកចង់មានន័យយ៉ាងម៉េចថា និរតី<ប្រឆាំងនឹង>បូព៌ាហ្នឹង ខ្ញុំមិនយល់កន្លែងចំណុចហ្នឹង?

**ឆ៖** បាទ ខ្ញុំឆ្លើយថា ខាងភូមិភាគបូព៌ាទើបតែនឹងទៅដែរ -- អ៎! ភូមិភាគនិរតី ទើបតែទៅនៅទាំងពួកខ្ញុំទាំងអីទើបតែទៅនៅភូមិភាគបូព៌ាហ្នឹងដែរ។ តែ តារ៉េម នោះ គាត់ទើបតែមកពីខាងនិរតី បានខ្ញុំថា និរតីនិងបូព៌ាគឺឆ្ងាយគ្នា អត់ដែលស្គាល់គ្នាទេ។ តែពួកដែលទើបតែនឹងទៅ ដែលខ្ញុំឆ្លើយមុននោះដែលវៀតណាមវ៉ៃចូលដល់កៅស៊ូជប់ហើយ បាននាំកម្លាំងនោះទៅ ទើបទៅប្រហែលជាពីរបីខែ បីបួនខែតែប៉ុណ្ណោះទេបាទ។

**ស៖** លោកសំដៅពេលនោះ ពេលចុងឆ្នាំ៧៨ ដើមឆ្នាំ៧៩ ពេលដែលវៀតណាមវ៉ៃចូលហ្នឹងមែនទេ?

[១១:០៤:២០]

**ឆ៖** បាទ ពេលនោះឯង ទើបទៅពេលនោះឯង។ កាលមុននៅធ្វើស្រែនៅបឹងបាយ៉ាបទេ។ គាត់នៅភ្នំពេញ តារ៉េម នោះ។ ខ្ញុំនៅបឹងបាយ៉ាប ទើបតែទៅដែលវៀតណាមវ៉ៃចូលមកទេ បាទ។

**ស៖** លោកឆ្លើយថា រ៉េម ជាប្រធានមន្ទីរពេទ្យ។ លោកដឹងទេថា រ៉េម ហ្នឹងហើយជាអ្នកចេញបញ្ជាឲ្យគេវះកាត់ស្ត្រីទាំងអស់ហ្នឹងមែនទេ?

**ឆ៖** បាទ រ៉េម ហ្នឹងហើយជាអ្នកបញ្ជានោះ គេប្រធានហ្នឹងហើយ គេហើយអ្នកបញ្ជា។

**ស៖** ជាការសន្និដ្ឋានរបស់លោកផ្ទាល់ ឬក៏ រ៉េម នេះមកប្រាប់លោកថា គាត់ហ្នឹងហើយជាអ្នកបញ្ជាឲ្យគេវះកាត់ស្ត្រីទាំងអស់ហ្នឹង?

**ឆ៖** អានេះជាការសន្និដ្ឋានទេ ខ្ញុំមិនបាន -- គាត់មិនបាននិយាយថាគាត់អ្នកបញ្ជាទេ ប៉ុន្តែប្រធានហើយ ដែលគេប្រធានហើយត្រូវតែបញ្ជាបាទ។ បើគាត់មិនបញ្ជា កូនទាហានណាហ៊ានធ្វើ។

**ស៖** លោកដឹងអំពីរចនាសម្ព័ន្ធនៅក្នុងមន្ទីរពេទ្យហ្នឹងទេ ហើយនិងអ្នកណាជាអ្នកសម្រេចជា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ប្រចាំថ្ងៃហ្នឹងក្រៅពី រ៉េម ហ្នឹងមានអ្នកណាខ្លះទៀត?

**ឆ៖** បាទ ពេទ្យនោះ គឺមិនមែនពេទ្យធំដុំទេ គឺពេទ្យកំប៉ិកកំប៉ុកទេ ពេទ្យសមរភូមិ ដែលថាមានបុគ្គលិកប្អូនដប់នាក់ទៅៗ សម្រាប់ទទួលអ្នកជំងឺបញ្ជូនមកកំពង់ចាមតែប៉ុណ្ណោះឯងទេ គ្មានអ្នកណាធំដុំអី មានតែ តារ៉េម នេះមួយ ហើយនិងនារីៗបុគ្គលិកតែប៉ុណ្ណោះឯង។

[១១:០៦:៥១]

**ស៖** អ៊ីចឹងខ្ញុំចង់សួរលោកថា លោកដឹងទេថាក្រៅពី រ៉េម ហ្នឹងអ្នកណាខ្លះទៀតជាអ្នកគ្រប់គ្រងក្តោបក្តាប់មន្ទីរពេទ្យហ្នឹង?

**ឆ៖** ខ្ញុំអត់បានដឹងអ្នកណាខ្លះទៀតទេ ខ្ញុំដឹង តារ៉េម មួយទេ។ ហើយខ្ញុំទៅសម្រាកតែពេទ្យតែម្តងហ្នឹងឯង របួស។

**ស៖** ខ្ញុំសូមចូលទៅប្រធានបទផ្សេង ពីព្រោះថាខ្ញុំនៅសល់ពេលខ្លីណាស់។ ខ្ញុំមានសំណួរមួយចំនួនតូចទៀត។ នៅក្នុងឯកសារដដែលគឺ E3/7523 ពេលដែលលោកនិយាយអំពីខោអាវទាហាន ដែលលោកបានឃើញនៅក្នុងឃ្លាំងរបស់វរៈ១៣ លោកបាននិយាយដូចតទៅ ERN ជាភាសាបារាំង 00884 233, ជាភាសាអង់គ្លេស 00875575, ជាភាសាខ្មែរ <0061164>*(ស៊ីក)*។ ពេលនោះគេសួរលោកដូចតទៅ គឺពាក់ព័ន្ធនឹងការរៀបចំផែនការក្បត់៖ "អ៊ីចឹងលោកមានបានឃើញគេរៀបចំប្រុងជើងការអ្វីទេ? បាទ ខ្ញុំឃើញៗគេរៀបចំ។ សួរ៖ មានខោអាវប៉ារ៉ា ខោអាវអីទេ? លោកឆ្លើយថា៖ មាននារីបីកងហើយ ផែនការគេត្រៀម<ពង្រាយកម្លាំងនៅជិត>វត្តភ្នំហ្នឹង ខ្ញុំឃើញគេត្រៀម ប៉ុន្តែរឿងហ្នឹងអត់មាននរណាប្រាប់ខ្ញុំទេ។ គេប្រាប់តែត្រឹមប្រធានក្រុម ប្រធានអីហ្នឹង។ កាលហ្នឹងខ្ញុំដឹងដោយសារខ្ញុំលួចមើលឯកសារគេ"។ ហើយនៅ ក្នុងសវនាការនេះលោកឆ្លើយថា លោកមិនបានលួចមើលឯកសារអីទេ គឺលោកទទួលបានព័ត៌មាននេះពីនីរសារ<របស់អឿន>។ អ៊ីចឹងពាក់ព័ន្ធនឹងឃ្លាដែលខ្ញុំទើបតែដកស្រង់អម្បាញ់មិញនេះ ខ្ញុំចង់ដឹងថា តើនៅពេលដែលលោកនិយាយអំពីកងនារីបីកងហ្នឹង លោកសំដៅទៅលើកងអ្វីដែរ?

[១១:០៩:២៤]

**ឆ៖** បាទ នារីអត់មានបីកងទេ នារីមានតែមួយកងហ្នឹងឯង មានតែមួយកងវរសេនាតូចប៉ុណ្ណោះឯង។ ខ្ញុំអត់បាននិយាយពីនារីមានបីកងឯណា បើកងនុ៎ងមានតែមួយកងនារី កងមិត្តជាតិ ប្រជុំ។

**ស៖** អ៊ីចឹងគឺកងនារីហ្នឹងមានមួយកង។ អ៊ីចឹងលោកនិយាយទៅលើកងនារីហ្នឹង តើកងនារីហ្នឹង

មានតួនាទីអីដែរពាក់ព័ន្ធនឹងផែនការដែលគេត្រៀមនៅវត្តភ្នំហ្នឹង? ហើយលោកបានស្តាប់ឮអ្វីខ្លះពាក់ព័ន្ធនឹងផែនការដែលលោកឃើញនៅវត្តភ្នំហ្នឹង?

**ឆ៖** ទេ ដឹងៗគេធ្វើអីទេ ប៉ុន្តែឃើញគេត្រៀមនុ៎ង កងនារី កងយុវជនទាំងអស់តែគ្នាហ្នឹងឯងអង្គាល់រំដោះបានមក គឺត្រៀមទាំងអស់គ្នា។ គេក៏ត្រៀម ខ្ញុំក៏ត្រៀមបាទ។ ប៉ុន្តែគេត្រៀមធ្វើផែនការអី គឺអត់ដឹង ថាគេធ្វើផែនការក្បត់ ផែនការអី គឺអត់បានដឹងទេ។ ដឹងគេរៀបខោអាវរៀបអី អាហ្នឹងគឺមែនឃើញប្រាកដមែន ប៉ុន្តែថារឿងត្រៀមហើយគេប្រាប់ ប្រជុំផ្សព្វផ្សាយថា ធ្វើផែនការវាយរំលំអ្នកនេះអ្នកនោះ គឺអត់មានដឹងទេបាទ។

**ស៖** មុននេះ ពេលដែលលោកឆ្លើយទៅនឹងសហព្រះរាជអាជ្ញា លោកថា ពេលដែលលោកពិភាក្សាជាមួយនីរសាររបស់ អឿន លោកដឹងអំពីផែនការនេះ ហើយការជជែកគ្នាលេងហ្នឹង គឺគ្រាន់តែជជែកគ្នាលេងធម្មតាទេ ពេលដែលមេៗកំពុងតែប្រជុំ។ ដូច្នេះ ខ្ញុំចង់ដឹងថាពេលនីរសាររបស់ អឿន ប្រាប់លោកអំពីផែនការហ្នឹង គាត់មានបាននិយាយអំពីការព្រួយបារម្ភរបស់គាត់ នៅពេលដែលគេ -- បើសិនជាគេដឹង -- បើសិនជាផែនការហ្នឹងបែកការណ៍ទេ?

**ឆ៖** អត់បានឮគាត់និយាយថាម៉េចថាម៉ាផង។ អត់មានឮថា ព្រួយបារម្ភខ្លាចបែកការណ៍ បែកអីអត់មានឮនិយាយផងបាទ។

[១១:១២:២៥]

**ស៖** គាត់ជានីរសារផ្ទាល់របស់ អឿន តើគាត់មានបានប្រាប់លោកថា មានអ្នកណាសួរនាំគាត់ពាក់ព័ន្ធទៅនឹងមេគាត់ ដែលត្រូវបានគេចាប់ខ្លួនទេ?

**ឆ៖** អត់មានអ្នកណាសួរគាត់ទេ។ ប៉ុន្តែគាត់និយាយថា មេ។ គាត់បានជូនទៅដែរ គាត់បានជូនទៅក៏គេចាប់គាត់ទៅ ក៏គាត់រត់មកវិញ។ គេឲ្យគាត់មកវិញ។ ចាប់ប្រធានគាត់ទៅ គេឲ្យមកវិញ គេឲ្យមកកន្លែងវិញ បាទ។

**ស៖** លោកប្រធាន ខ្ញុំសូមសំណួរចុងក្រោយ ខ្ញុំដឹងថា ខ្ញុំអស់ពេលទៅហើយ។ លោកសាក្សីខ្ញុំចង់ឲ្យលោកបញ្ជាក់បន្តិច ពេលដែលលោកទៅដល់ភ្នំពេញនៅខែមេសា ឆ្នាំ១៩៧៥ ហើយទីក្រុងនុ៎ង គឺត្រូវបានធ្លាក់ទៅក្នុងកណ្តាប់ដៃខ្មែរក្រហម តើទាហានដែលចូលរួមនៅក្នុងការប្រយុទ្ធហ្នឹង អាចរក្សាកាំភ្លើងនៅក្នុងដៃរបស់ខ្លួនទេ ឬក៏នៅពេលណាមួយនោះ គេបញ្ជាឲ្យកូនទាហានទាំងអស់ហ្នឹង ប្រគល់កាំភ្លើងហ្នឹងទៅឲ្យមេៗ ដើម្បីទទួលផែនការថ្មី ឬទទួលការចាត់តាំងថ្មីនោះ?

**ឆ៖** បាទ កាលនោះ គឺកាំភ្លើងនៅគ្រប់ដៃ អត់មានប្រមូលទេ រយៈតែយូរបានគេប្រមូលម្ដងបន្តិចៗ ដល់ពេលធ្វើស្រែ ខាងធ្វើស្រែខ្លាំងទៅ គេប្រមូលអស់រលីង អត់មានទុកសល់។ ពីដើមកាលមុនដំបូង គេប្រមូលកាំភ្លើងខ្លី យូរៗកាំភ្លើងវែង យូរៗ អស់រលីងទាំងវែង ទាំងខ្លី អស់ឡោង នៅចបម្ដង នៅបង្គី ដងរែក។ បាទ នៅតែប៉ុណ្ណោះឯងកម្មសិទ្ធិ អស់ហើយកាំភ្លើង អត់មានទេបាទ។ ខ្ញុំបញ្ជាក់ឲ្យច្បាស់អ៊ីចេះឯង ដែលបាន ខ្ញុំបានឃើញ ហើយនិងបានធ្វើ។ បាទ ប៉ុណ្ណោះឯង។

[១១:១៥:០៣]

**ស៖** សំណួរចុងក្រោយបន្តពីចម្លើយរបស់លោក។ ចាប់ពីពេលណាដែរដែលគេចាប់ផ្ដើមដកអាវុធពីទាហានទាំងអស់ហ្នឹង?

**ឆ៖** ក្រោយពេលរំដោះ៧៥មក ប្រហែលជា៧៦ៗហើយសម្រុកខ្លាំង ធ្វើស្រែខ្លាំង គេដកអស់ហើយ អត់មានទេ។ មានយុទ្ធជនណាមានស្អីកាន់នឹងដៃទេ ហើយគ្មាននឹងកម្លាំងសួរអ្នកណាអ្នកណីផងគ្មានទេ មានគិតតែព្រលឹមឡើងក៏ប្រឹងការងារដល់សព្វខ្លួនទៅ កសាងខ្លួនតមមាត់ តមកសន្សំសុខខ្លួនទៅអ្នកណាកាន់មិនបានក៏បាត់ខ្លួនទៅ មានតែប៉ុណ្ណោះឯង អស់ហើយខ្ញុំ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន សូមអរគុណដែលបានផ្ដល់ពេលវេលាបន្ថែមឲ្យខ្ញុំ ទោះបីជាខ្ញុំដឹងថាការសួរហ្នឹងមួយចំនួនហ្នឹង វាអាចលេចចេញក្រៅប្រធានបទក៏ដោយ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ អរគុណលោកសាក្សី អង្គជំនុំជម្រះអរគុណលោក សែម អំ ការស្ដាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សី រហូតមកដល់ពេលនេះបានដល់ទីបញ្ចប់ហើយ លោកអាចសម្រាកបានហើយ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយបុគ្គលិកផ្នែកអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនលោក សែម អំ វិលត្រឡប់ទៅវិញ។

ជាបន្ត អង្គជំនុំជម្រះប្រកាសសេចក្ដីសម្រេចផ្ទាល់មាត់ទទួលយកឯកសារភស្តុតាងនៃចម្លើយពីមុនចំនួនពីររបស់សាក្សី 2-TCW-1036។ អង្គជំនុំជម្រះកត់សម្គាល់ថា មេធាវីការពារក្តី លោក នួន ជា បានធ្វើសំណើសុំដោយផ្ទាល់មាត់អនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុងសុំឲ្យទទួលយកឯកសារភស្តុតាងនៃចម្លើយចំនួនពីររបស់សាក្សី 2-TCW-1036 ដែលត្រូវចាប់ផ្ដើមផ្ដល់សក្ខីកម្មនៅថ្ងៃនេះ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហើយមិនមានភាគីណាមួយជំទាស់ទៅលើសំណើសុំនេះទេ។ អង្គជំនុំជម្រះកត់សម្គាល់ថាឯកសារចំនួនពីរដែលស្នើសុំឲ្យទទួលយកនេះគឺឯកសារ F2/4/2/3.2.1 និងឯកសារ F2/4/2/3.2.2 ជាកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី 2-TCW-1036 ពីក្នុងសំណុំរឿង០០៤។

អង្គជំនុំជម្រះសាលាដំបូងរំឭកអំពីទម្លាប់អនុវត្តរបស់ខ្លួនក្នុងការទទួលយកជាឯកសារភស្តុតាងនូវចម្លើយមុនៗទាំងអស់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សីដែលនឹងចូលផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះអនុលោមតាមវិធាន៨៧(៣) និង៨៧(៤) នៃវិធានផ្ទៃក្នុង វាជាប្រយោជន៍ក្នុងការស្វែងរកការពិតដែលអង្គជំនុំជម្រះនិងភាគីអាចពិនិត្យមើលចម្លើយទាំងអស់របស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីដែលនឹងត្រូវមកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២/០២។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចទទួលយកឯកសារទាំងពីរនេះជាឯកសារភស្តុតាង និងដាក់លេខសម្គាល់ជាឯកសារ E3/10671 និង E3/10672។ ជាបន្ត មន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី 2-TCW-1036 និងមេធាវីប្រឹក្សាលោក ចាន់ សំបូរ មកកាន់កន្លែងផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១១:២០:០០]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

មុននឹងចាប់ផ្តើមសួរសាក្សីរូបនេះ យើងយល់ឃើញថា សំណើសុំរបស់មេធាវីការពារក្តី នួន ជា គឺស្នើសុំឲ្យទទួលយករូបថតធ្វើជាភស្តុតាង។ ដូច្នេះ តើយ៉ាងដូច្នេះមែនទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ អ៊ីចឹងហើយ។ មិនចាំបាច់ដល់ទៅទទួលយកទៅជាភស្តុតាងទេ យើងខ្ញុំគ្រាន់តែស្នើសុំឲ្យបង្ហាញទៅសាក្សីនៅរសៀលនេះ គឺជារូបថតដែលយកចេញមកពីគេហទំព័ររបស់ អ.វ.ត.ក។ <ខ្ញុំមិននិយាយនៅពេលនេះថាគាត់ជានរណានោះទេ ប៉ុន្តែ>គាត់គឺ ជាសាក្សីមួយរូបដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលនៅខែមិថុនា ឆ្នាំ២០១៥ រួចហើយ។ ហើយជាមួយនឹងសាក្សីថ្មីៗក៏គេមានថតរូប ហើយរូបថតនោះ ក៏បានដាក់បង្ហាញនៅលើគេហទំព័ររបស់ អ.វ.ត.ក ដែរ។ អ៊ីចឹងរូបថតនេះ យើងខ្ញុំចង់បង្ហាញដល់សាក្សីនៅពេលក្រោយនេះ។ ប្រហែលជារូបថតនេះ <>ថត<ដោយ> អ្នក<>ថត<រូប>នៅសាលាក្តីយើងនេះ ជាអ្នកថតផង។

[១១:២១:១៤]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើលោកចង់ប្រើប្រាស់ដោយរបៀបណា? តើរូបថតនេះ មានភាពពាក់ព័ន្ធដូចម្តេចដែរ?

សូមផ្តល់គោលបំណងបញ្ជាក់អំពីអត្តសញ្ញាណនៃរូបថតនេះផង ហើយដូចយើងបានលើកឡើង គឺយើងត្រូវតែស្នើសុំតាមវិធាន៨៧(៤) <បើលោកចង់យករូបថតនោះមកប្រើ>។ អ៊ីចឹង អង្គជំនុំជម្រះយល់ឃើញថា នេះគឺជាសំណួរមួយស្នើសុំឲ្យទទួលយករូបថតនេះជាភស្តុតាង។ តើរូបថតនេះ នឹងត្រូវយកមកសួរតទល់ជាមួយនឹងសាក្សីរូបនេះ ដើម្បីកំណត់អត្តសញ្ញាណអំពីអ្នកនៅក្នុងរូបថតនេះឬ? តើភាគីនីមួយៗ យល់បានច្បាស់លាស់ហើយឬនៅ អំពីសំណើសុំដាក់បង្ហាញរូបថតនេះ? អ៊ីចឹង អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ភាគីនីមួយៗ មិនជំទាស់ទៅនឹងការស្នើសុំបង្ហាញរូបថត និងទទួលរូបថតជាភស្តុតាងទេ។ សូមអរគុណលោកមេធាវី។

**ប្រធានអង្គជំនុំ៖**

មុននឹងចាប់ផ្តើមសក្ខីកម្មរូបនេះ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា សាក្សីនេះត្រូវបានស្តាប់ចម្លើយនៅក្នុងកិច្ចស៊ើបអង្កេតដែលកំពុងដំណើរការនៅក្នុងសំណុំរឿងផ្សេង។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកំណត់សាក្សីរូបនេះ ស្ថិតនៅក្នុងក្រុម "ក" នៃក្រុមទាំងបីប្រភេទនៅក្នុងអនុស្សរណៈរបស់ខ្លួន។ ឯកសារ E319/35 និងឯកសារ E319/48.5 ហើយបានស្នើថា សាក្សីរូបនេះ គួរប្រើរហស្សនាម ក្នុងគោលបំណងការពារនូវសម្ងាត់នៃកិច្ចដំណើរការស៊ើបអង្កេត។

អង្គជំនុំជម្រះយល់ឃើញថា វិធានការដែលមានកម្រិតបែបនេះ គឺត្រឹមត្រូវ សមស្របតាមច្បាប់នៅក្នុងករណីបែបនេះ។ ហើយការបង្គាប់នេះ គឺត្រូវធ្វើឲ្យមានតុល្យភាពគ្នា រវាងតម្រូវការនៃសាធារណភាពនៃសវនាការ ជាមួយនឹងការការពារសុច្ចភាពនៃការងារស៊ើបអង្កេត។ ហើយអង្គជំនុំជម្រះសូមរំឭកដល់ភាគីដែលថា ឲ្យគោរពឲ្យបានខ្ជាប់ខ្ជួននូវសេចក្តីណែនាំនៅក្នុងឯកសារ E319/7 ក្នុងការប្រើប្រាស់ឯកសារដាក់បង្ហាញសំណុំរឿងផ្សេង។

[១១:២៣:៥០]

របៀបសួរលោកសាក្សីក្នុងកិច្ចដំណើរការសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ តាមសំណើសហចៅក្រមស៊ើបអង្កេតអន្តរជាតិ គឺយើងបានប្រើប្រាស់តែរហស្សនាមរបស់លោកទេ។ ហើយលោកសាក្សីមានរហស្សនាម 2-TCW-1036 ហើយជាទូទៅ ភាគីនឹងតែងតែប្រើប្រាស់ហៅលោកក្នុងនាមជាសាក្សីប៉ុណ្ណោះ។ អ៊ីចឹងសូមលោកយល់ថា អង្គជំនុំជម្រះនឹងមិនអនុញ្ញាតភាគីពាក់ព័ន្ធ រួមទាំងអង្គជំនុំ

ជម្រះខ្លួនឯង ប្រើនាមត្រកូល និងនាមខ្លួនរបស់លោកជាសាធារណៈក្នុងសវនាការនេះទេ។

លោកសាក្សី តទៅនេះអង្គជំនុំជម្រះសូមបញ្ជាក់ទៅលើអត្តសញ្ញាណរបស់លោកដែលមាននៅក្នុងឯកសារ E3/9581 ដែលមានលេខ ERN ជាភាសាខ្មែរ 00960675 ហើយនិង ERN ជាភាសាអង់គ្លេស 00970078 និង ERN ជាភាសាបារាំង 01044642។

មន្ត្រីរដ្ឋបាលតុលាការ យកឯកសារនេះទៅជូនសាក្សីពិនិត្យ។

*(សាក្សីពិនិត្យមើលឯកសារ)*

សូមជូនវេទិកានេះ ទៅលោកចៅក្រម ហ្វេនស៍។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំសូមបញ្ជាក់បញ្ចប់បង្ហើយអំពីរូបថត។ យើងដឹងហើយសេចក្តីសម្រេចរបស់អង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងរូបថតដែលជាឧបសម្ព័ន្ធទៅនឹងអ៊ីម៉ែល ចុះថ្ងៃទី<២១> កញ្ញា ឆ្នាំ២០១៦ ដែលស្នើសុំឱ្យអង្គជំនុំជម្រះទទួលយកជាភស្តុតាង។

[១១:២៥:៤៩]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សុំលោកសាក្សីពិនិត្យមើលកន្លែងដែលមានហាយឡាយពណ៌ទឹកក្រូច ថាតើឈ្មោះរបស់លោក ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត មុខរបរ ឈ្មោះឪពុកម្តាយ ឈ្មោះប្រពន្ធ ចំនួនកូន និងទីលំនៅបច្ចុប្បន្នរបស់លោកពិតជាត្រឹមត្រូវឬទេ? លោកគ្រាន់តែឆ្លើយថា ត្រឹមត្រូវ ឬមិនត្រឹមត្រូវបានហើយ។

**2-TCW-1036៖**

**ឆ៖** ត្រឹមត្រូវបាទ។

**ស៖** អរគុណលោកសាក្សី។ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះថា សមត្ថភាពដែលលោកអាចដឹង គឺលោកមាន -- មិនមានចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ក៏ដូចជាបុគ្គលទាំងឡាយដែលទទួលយកជាភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីនេះទេ។ តើរបាយការណ៍នេះពិតជាត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវ។

**ស៖** អរគុណលោកសាក្សី។ ហើយថាលោកបានស្បថចំពោះមុខអ្នកតាដំបងដែករួចហើយ មុន

ពេលចូលផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះនេះ តើពិតមែនទេ?

**ឆៈ** ពិតមែន។

**សៈ** តទៅនេះ យើងសូមប្រាប់អំពីសិទ្ធិនិងករណីយកិច្ច ក្នុងឋានៈលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ ក្នុងឋានៈលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬក៏សុំឱ្យលោកធ្វើអត្ថាធិប្បាយ រៀបរាប់ណាដែលនាំឱ្យចម្លើយតប ឬការរៀបរាប់របស់លោកដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ អំពីករណីយកិច្ច ក្នុងឋានៈលោកជាសាក្សីនៅក្នុងកិច្ចដំណើរការចំពោះមុខអង្គជំនុំជម្រះ លោកត្រូវតែឆ្លើយតបនូវរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។ លើកលែងតែសំណួរណាដែលនាំឱ្យចម្លើយតប ឬក៏ការធ្វើអត្ថាធិប្បាយ រៀបរាប់របស់លោកនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងបានប្រាប់ពីសិទ្ធិរបស់លោកអម្បាញ់មិញនេះ។ ហើយក្នុងឋានៈលោកជាសាក្សី លោកត្រូវតែឆ្លើយការណ៍ណាដែលពិត ដែលបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬក៏បានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តហេតុ ហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។

តើលោកបានធ្លាប់បានផ្តល់សក្ខីកម្ម ឬផ្តល់កិច្ចសម្ភាសន៍ជាមួយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេរយៈពេលកន្លងមក? ហើយបើសិនជាបានធ្វើ ធ្វើប៉ុន្មានដង? ធ្វើនៅកន្លែងណា?

[១១:២៩:00]

**ឆៈ** បាទ ធ្វើបីដង នៅវត្តស្ទឹង នៅផ្ទះខ្ញុំ។

**សៈ** អរគុណលោកសាក្សី។ ហើយនៅមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនេះ តើលោកបានពិនិត្យមើល ឬក៏បានអាននូវកំណត់ហេតុដែលលោកបានផ្តល់សក្ខីកម្មកាលពីពេលមុនជាមួយអ្នកស៊ើបអង្កេត ដើម្បីធ្វើការរំឭកចងចាំរបស់លោកដែរឬទេ?

**ឆៈ** បាទ។

**សៈ** តាមសមត្ថភាពលោកអាចដឹងនិងចងចាំបាន តើលោកអាចបញ្ជាក់បានទេថា កំណត់ហេតុដែលស្តាប់ចម្លើយដែលលោកបានអានដើម្បីរំឭកការចងចាំនេះ គឺពិតជាត្រឹមត្រូវ សមស្របស៊ីសង្វាក់គ្នាទៅនឹងសក្ខីកម្មដែលលោកបានផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលមុននោះដែរឬ

ទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** អរគុណលោកសាក្សី។ នៅក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះផ្តល់វេទិការជូនទៅមេធាវីការពារក្តីលោក នួន ជា ក្នុងការសួរដេញដោលទៅសាក្សីរូបនេះមុនភាគីដទៃទៀតនៃរឿងក្តី។

តែពេលនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះទៅ រហូតដល់ម៉ោងមួយកន្លះរសៀល សូមអញ្ជើញចូលវិញបន្តកិច្ចដំណើរការសវនាការ។

អង្គជំនុំជម្រះអញ្ជើញលោកមកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញឲ្យបានមុនម៉ោងមួយកន្លះរសៀលនេះលោកសាក្សី។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យខ្លួនគាត់ត្រឡប់ចូលរួមសវនាការក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សូមអញ្ជើញសម្រាក!

*(សវនាការសម្រាកពីម៉ោង ១១:៣០ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣០:៤៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

ជាបន្តអង្គជំនុំជម្រះ សូមអញ្ជើញការពារលោក នួន ជា តាំងសំណួរលើសាក្សីរូបនេះ ហើយលោកមេធាវី រួមទាំងមេធាវីការពារក្តីលោក ខៀវ សំផន មានរយៈពេលពីរវគ្គនៃថ្ងៃសវនាការ។

សូមអញ្ជើញលោកមេធាវីការពារលោក នួន ជា!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សួស្តីលោក លោកស្រីចៅក្រម មេធាវី។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សួស្តីលោកសាក្សី ខ្ញុំមានសំណួរច្រើនដែរ ចង់សួរទៅកាន់លោកនៅរសៀលនេះ ហើយខ្ញុំសូមចាប់ផ្តើមតែម្តង។ តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេ តើមុនឆ្នាំ៧៥ លោកធ្វើអ្វីដែរ ហើយ

លោកបានចូលបដិវត្តន៍នៅពេលណា? នៅក្នុងឆ្នាំណាដែរ?

**2-TCW-1036៖**

**ឆ៖** ចូលឆ្នាំ៧២បង។

**ស៖** តើលោកនៅចាំទេ មុនឆ្នាំ៧៥ តើលោកបានធ្វើការងារអ្វីខ្លះ?

**ឆ៖** បាទ នៅអំពិលប្រហោង ខ្មែរក្រហមដែរ។

**ស៖** តើមានពេលណាមួយគេបានចាត់តាំងលោកឲ្យធ្វើជានីរសារ ធ្វើនៅក្នុងក្រុមខ្មែរក្រហមដែរឬទេ?

**ឆ៖** *(ឮមិនច្បាស់)*

**ប្រធានអង្គជំនុំ៖**

លោកសាក្សីលោកឆ្លើយម្តងទៀត ហើយឆ្លើយឲ្យឮៗ! ហើយនៅពេលដែលមីក្រូហ្វូនចេញពណ៌ក្រហម អាហ្នឹងចាំលោកឆ្លើយ។

**2-TCW-1036៖**

**ឆ៖** ខ្ញុំចូលតាំងពី៧៥ នៅជាមួយគាត់។ ហើយខ្ញុំបាន អ៊ីចឹងបានខ្ញុំមកនៅអំពិលប្រហោង ដល់៧៧ ខ្ញុំគេចាប់ខ្ញុំដាក់គុកហើយ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំនឹងសួរចំណុចហ្នឹង។ លោកបានលើកឡើងថា <"គាត់"> តើនៅមុនឆ្នាំ៧៥ លោកធ្លាប់ធ្វើជានីរសារឲ្យ <តាញ៉ឹម> ដែលជាប្រធានខាងភូមិភាគពាយ័ព្យដែរឬទេ?

**ឆ៖** បាទ។

**ស៖** លោកបានលើកឡើងដោយសង្ខេបនៅលើហេតុការណ៍<ក្រោយ>ឆ្នាំ៧៥ ហើយខ្ញុំសូមសួរ ហេតុការណ៍ក្នុងឆ្នាំ៧៥តែម្តងទៅ។ តើត្រឹមត្រូវដែរឬទេ ក្រោយឆ្នាំ៧៥ លោកធ្វើជាទាហាននៅក្នុងខេត្តប៉ៃលិន? ហើយក្រោយមក នៅក្នុងឆ្នាំ៧៦ តាញ៉ឹម បានស្នើលោកធ្វើជាអង្គរក្សកងការពាររបស់គាត់?

**ឆ៖** បាទ។

**ស៖** តើលោកជាកងការពាររបស់គាត់ហ្នឹងរហូតដល់ពេលគេចាប់ខ្លួនគាត់មែនដែរឬទេ?

**ឆ៖** បាទ។

[១៣:៣៥:០៤]

**ស៖** តើកងការ -- មានកងការពារប៉ុន្មាននាក់ដែរ បើរួមទាំងលោកនៅចន្លោះឆ្នាំ៧៥ រហូតដល់ខែឧសភា ឬក៏មិថុនា ឆ្នាំ៧៨។ តើមានកងការពារគាត់ រួមទាំងលោកហ្នឹងប៉ុន្មាននាក់ដែរ?

**ឆ៖** ពួកគាត់ ខាងគាត់ខាងជាប់គាត់បីនាក់ ខ្ញុំខាងក្រៅនេះបួននាក់។

**ស៖** តើលោកជាកងការពារម្នាក់ក្នុងចំណោមបីនាក់ដែលនៅជាប់គាត់ដែរឬទេ?

**ឆ៖** អត់ទេ។

**ស៖** ខ្ញុំនឹងសួរចំណុចហ្នឹងឡើងវិញ ក៏ប៉ុន្តែដំបូងខ្ញុំសូមសួរលោកសិនថា តើលោកនឹកឃើញឬក៏នៅចាំកងការពារណាម្នាក់ក្នុងចំណោមកងការពារទាំងបីដែលនៅជាប់ជាមួយនឹង រស់ ញឹម ដែរឬទេ?

**ឆ៖** ខ្ញុំអត់ចាំផង ខ្ញុំបែកយូរហើយហ្នឹង ខ្ញុំអាល័យជាប់គុកនេះ ភ្លេចភ្លាំងអស់ អត់ចាំទេ។

**ស៖** មុនពេលដែលខ្ញុំសួរសំណួរពាក់ព័ន្ធទៅនឹងការងាររបស់លោកជាកងការពារ ខ្ញុំសូមសួរ<>លោក<អំពី>នីរសារសិន <គឺអ្នកដែល>ធ្លាប់ធ្វើការឲ្យ តាញឹម ឬក៏ រស់ ញឹម ផងដែរ។ តើលោកធ្លាប់ស្គាល់នីរសារឈ្មោះ ជ្រូក ដែរឬទេ នីរសាររបស់គាត់ណា?

[១៣:៣៧:១២]

**ឆ៖** ស្គាល់។

**ស៖** តើគាត់ហ្នឹងជានីរសារ ឬក៏ជាកងការពារ?

**ឆ៖** គេជាប់គាត់ជានិច្ចពួកហ្នឹង ខ្ញុំគ្រាន់ការពារក្រៅពួកខ្ញុំនេះផ្សេង ទៅណាទៅឆ្ងាយៗខ្ញុំ។

**ស៖** តើលោកស្គាល់មនុស្សម្នាក់ទៀតដែលធ្លាប់ទៅធ្វើជានីរសារផងដែរ ក៏ប៉ុន្តែមិនមែនជានីរសារ<សម្រាប់តែ> រស់ ញឹម នោះទេ អាចជានីរសាររបស់ តាប៉ែត ឬក៏ នួន ជា ផងដែរ ហើយគាត់ហ្នឹងឈ្មោះ តាលី ហៅ តាគឹម។ តើលោកធ្លាប់ស្គាល់ទេ?

**ឆ៖** អត់ អត់ដែលឃើញផង។

**ស៖** មិនជាថ្វីនោះទេ នៅពេលនេះខ្ញុំសួរអំពីការងាររបស់លោកជាកងការពារវិញម្តង ឲ្យខាងប្រធានភូមិភាគពាយ័ព្យ រស់ ញឹម។ តើការងារប្រចាំថ្ងៃរបស់លោកធ្វើអ្វីដែរ លោកអាចពិពណ៌នាបានដែរឬទេ?

**ឆ៖** អត់មានអីធ្វើផង ដល់គាត់ដល់ត្រូវការទៅណាទៅគាត់ហៅទៅ ណាមិនបានទៅនៅកន្លែងប៉ុនខ្ញុំផ្សេងគាត់ នៅតែចាំតែឡានគាត់។

**ស៖** នៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយមួយ ក្នុងចំណោមបី E3/9581 នៅក្នុងសំណួរចម្លើយទី៣ លោកបានឆ្លើយថា លោកធ្វើជាកងការពាររបស់គាត់ទៅៗតាមគាត់គ្រប់ទីកន្លែងទាំងអស់។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** អត់។ ស្របពេលដែលឆ្ងាយបានខ្ញុំទៅ ដល់ជិតៗហ្នឹងអត់ទៅទេ។

[១៣:៤០:១៣]

**ស៖** ប្រសិនបើ គាត់ទៅតាមកន្លែងជិតៗ តើកងការពារផ្សេង ឬក៏ពីរនាក់ផ្សេងដែលទៅជាមួយគាត់ដើម្បីការពារសន្តិសុខគាត់ មែនដែរឬទេ?

**ឆ៖** បាទ។

**ស៖** តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេ លោករស់នៅទីណាដែរក្នុងអំឡុងពេលដែលលោកធ្វើជាកងការពាររបស់ រស់ ញឹម?

**ឆ៖** នៅបាត់ដំបង កន្លែងអំពិលប្រហោង។

**ស៖** តើត្រឹមត្រូវដែរឬទេដែលថាលោករស់នៅក្នុងផ្ទះមួយចម្ងាយប្រហែលជា៥០ម៉ែត្រពីអំពិលប្រហោង?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** តើត្រឹមត្រូវដែរឬទេផងដែរដែលថាផ្ទះរបស់ រស់ ញឹម ហើយនិងមន្ទីរធ្វើការងាររបស់គាត់ហ្នឹងគឺស្ថិតនៅអំពិលប្រហោង?

**ឆ៖** អំពិលប្រហោងហើយអានោះ។

**ស៖** តើត្រឹមត្រូវដែរឬទេអំពិលប្រហោងនេះ គឺជាមន្ទីរការងារ មន្ទីរធ្វើការងាររបស់រស់ ញឹម? ហើយផ្ទះរបស់ រស់ ញឹម នោះ គឺស្ថិតនៅចម្ងាយប្រហែលជា១គីឡូម៉ែត្រពីផ្សារលើក្នុងខេត្តបាត់ដំបង?

**ឆ៖** ត្រឹមត្រូវហើយ។

[១៣:៤២:៤៩]

**ស៖** តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេថាតើមានអ្វីកើតឡើងខ្លះនៅពេលដែលលោកទៅការពារគាត់ពីកន្លែងមួយទៅកន្លែងមួយ <តើលោកធ្វើអ្វី>? តើ<>លោកដើរពីផ្ទះលោកទៅកាន់ផ្ទះគាត់ទៅដល់អំពិលប្រហោង ហើយរង់ចាំគាត់រហូតដល់គាត់ចេញមក ហើយទើបទៅឬយ៉ាងម៉េច តើលោកអាចរៀបរាប់អំពីចំណុចហ្នឹងដែរឬទេ?

**ឆ៖** បាទ ចេញហើយបានខ្ញុំទៅ ដល់ជួបគាត់ហ្នឹងបានទៅបណ្ដោយហ្នឹង អត់ចាំយូរទេ។

**ស៖** តើឡានរបស់ រស់ ញឹម ហ្នឹងទុកនៅផ្ទះរបស់លោក ឬក៏ទុកនៅអំពិលប្រហោង តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេវាយ៉ាងម៉េចដែរ?

**ឆ៖** គាត់ទុកនឹងផ្ទះគាត់។ កន្លែងខ្ញុំអត់មានឡានទេ។

**ស៖** តើឡានហ្នឹង ឡានប្រភេទអ្វីដែលលោកបើកនៅពេលដែលលោកដឹកគាត់ ជូនគាត់ដើម្បីការពារសុវត្ថិភាពជូនគាត់ហ្នឹង ប្រភេទឡានអីដែរ?

**ឆ៖** ឡានសអាហ្នឹង ឡានឃ្មុំបស ឡានពីសង្គម។ អាហ្ស៊ីបនោះ ឡានប្រទេសផ្សេងទៀត។

**ស៖** តើឡានហ្ស៊ីបពណ៌សហ្នឹងដែលលោកបើកប្រើប្រាស់ហ្នឹង លោកបើកគ្រប់ពេលទាំងអស់នៅពេលដែលលោកជាកងការពាររបស់គាត់ និងជាអ្នកបើកឡាន។ បានន័យថាពីឆ្នាំ៧៦ រហូតដល់ពេលគេចាប់ខ្លួនគាត់។ តើលោកប្រើប្រាស់ឡានពណ៌ស ឡានហ្ស៊ីបហ្នឹងមែនដែរឬទេ?

**ឆ៖** បាទ។

[១៣:៤៥:១៤]

**ស៖** យើងបានពិភាក្សាគ្នាអំពីផ្ទះរបស់ រស់ ញឹម និងមន្ទីរធ្វើការងាររបស់គាត់នៅអំពិលប្រហោង។ តើមូលដ្ឋានយោធា កងទ័ពរបស់ តាញឹម ហ្នឹង នៅកន្លែងណាដែរ តើលោកស្គាល់ទេ?

**ឆ៖** អំពិលប្រហោងនៅជុំវិញផ្ទះគាត់ហ្នឹង រាប់ផ្ទល់។

**ស៖** ខ្ញុំយល់ ក៏ប៉ុន្តែគាត់មានមូលដ្ឋានកងទ័ពឈរជើងរបស់គាត់ដែរឬទេ បានន័យថាគាត់ធ្លាប់ទៅមូលដ្ឋានកងទ័ពតាមឡានហ្ស៊ីប ដែលលោកបើកជូនគាត់ទៅកន្លែងនុ៎ងដែរឬទេ គាត់មានទេមូលដ្ឋានទ័ព?

**ឆ៖** មានតាំងពីស្វាយទៅ ដូច នែ! អូរជ្រៅ សំឡូត ប៉ៃលិន ប៉ុណ្ណឹង។

**ស៖** ខ្ញុំសួរលោក ដោយសារតែលោកបានឆ្លើយនៅក្នុងឯកសារទីដំបូងរបស់លោក។ ឯកសារ E3/9581 សំណួរចម្លើយទី៤ លោកបានឆ្លើយថា “ស៊ីសុផុនក៏ជាកន្លែងយោធារបស់ តាញឹម ផងដែរ។” តើលោកបានដឹកគាត់ ជូនគាត់ទៅកាន់ស៊ីសុផុនដែរឬទេ?

**ឆ៖** ជូនបង។

**ស៖** តើត្រឹមត្រូវដែរឬទេ នៅខាងជើងផ្ទះរបស់ រស់ ញឹម គឺជាផ្ទះរបស់ តាប៉ែត ហៅថា <តាកន្ទុល> ដែលជាអ្នកកាន់កាប់នៅភូមិភាគពាយ័ព្យផងដែរ គឺជាបុគ្គល<ទី២ ឬ>ទី៣?

**ឆ៖** បាទ។

**ស៖** តើលោកធ្លាប់ជូនគាត់ទៅកាន់ផ្ទះ តាប៉ែត ទេ?

**ឆ៖** អត់ដែរទេ។

**ស៖** តើត្រឹមត្រូវដែរឬទេ នៅអំពិលប្រហោង តាញ៉ឹម នោះបានប្រជុំនៅទីនោះជាមួយនឹងមេបញ្ជាការកងទ័ពរបស់គាត់?

**ឆ៖** មែន។

[១៣:៤៨:១៥]

**ស៖** នៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយរបស់លោកដដែល គឺត្រង់សំណួរចម្លើយ៦២ គឺលោកលើកឡើងថា "គេអត់ឲ្យលោកចូលទីតាំងប្រជុំនៅអំពិលប្រហោងនោះទេ"។ តើត្រឹមត្រូវដែរឬទេ បើសិនជាត្រឹមត្រូវមែន ហេតុអ្វីគេមិនឲ្យលោកចូល?

**ឆ៖** វាខុសគ្នា។ គេផ្ទាល់ ខ្ញុំក្រៅ។ គេខ្សែទី១ ខ្សែទី២។ ខ្ញុំទី២ គេទី១។

**ស៖** ខ្ញុំមិនទទួលបានចម្លើយទេ ក៏ប៉ុន្តែខ្ញុំនឹងបង្ហាញចំណុចហ្នឹងនៅលើអេក្រង់ លោកសាក្សី។ លោកសាក្សី ខ្ញុំសូមបន្តសួរលោកអំពីការចាប់ខ្លួន រស់ ញ៉ឹម។ តើគេចាប់ រស់ ញ៉ឹម នៅទីណា? តើលោកចាំទេ?

**ឆ៖** ខ្ញុំអត់ដឹង គាត់ទៅចេញខ្ញុំផុតហើយ។ ចេញទៅផ្លូវស្វាយហ្នឹង មិនដឹងគេចាប់ណាៗ អត់ដឹងផង ខ្ញុំនៅឯណោះ។

[១៣:៤៩:៥៧]

**ស៖** ខ្ញុំសាកមើល ថាតើខ្ញុំអាចជួយឲ្យលោកចងចាំដែរឬទេ? សំណួរចម្លើយ<៣០>នៅក្នុងកំណត់ ហេតុដដែល លោកបានឆ្លើយថា រស់ ញ៉ឹម ត្រូវបានគេចាប់នៅស៊ីសុផុន នៅពេលដែលគាត់ព្យាយាមរត់ទៅកាន់ខេត្តកំពង់ចាម។ តើលោកនឹកឃើញទេ?

**ឆ៖** អត់។

**ស៖** ខ្ញុំដូចជាស្រឡាំងកាំងចំពោះចម្លើយដែលលោកឆ្លើយនៅពេលនេះ។ លោកសាក្សី បីឆ្នាំមុន ត្រឹមតែបីឆ្នាំមុនប៉ុណ្ណោះ ដែលលោកបានឆ្លើយប្រាប់អ្នកស៊ើបអង្កេត ហើយលោកលើកឡើងថា កម្មាភិបាលភូមិភាគនិរតី គឺចាប់ខ្លួនគាត់នៅស៊ីសុផុន នៅពេលដែលរស់ ញ៉ឹម នេះគេចខ្លួន កំពុងតែព្យាយាមគេចខ្លួនទៅខេត្តកំពង់ចាម។ ហើយការចាប់ខ្លួននេះប្រហែលជានៅចុងឆ្នាំ១៩៧៨។ តើបានន័យថា នៅ

ពេលនេះ លោកអត់ចាំអ្វីទាល់តែសោះ ទីតាំងដែលគេចាប់គាត់ ឬមួយក៏យ៉ាងម៉េចដែរ?

**ឆ៖** គ្រាន់ខ្ញុំឮគេថា គ្រាន់ពួកក្រៅៗទៀតគេថា ខ្ញុំអត់ដឹង ឮគេថាៗអត់ជឿគេ ខ្ញុំមិនបានឃើញផ្ទាល់ភ្នែក។

**សៈ** មានភស្តុតាងផ្សេងទៀតមកពី ដែលឆ្លើយមកពីកម្មាភិបាលពាយ័ព្យបានឆ្លើយថា គាត់ឮថាមានកន្ទុំរុយ ឬក៏ឧទ្ធម្ភាគចក្រនៅពេលដែលគេចាប់ខ្លួន រស់ ញឹម។ តើលោកអាចចាំបានទេ ជាពិសេសនៅក្នុងឯកសារ E3/9578 <សំណួរចម្លើយលេខ១០> តើលោកនៅចាំទេ ហើយមានឮអំពីករណីហ្នឹងដែរឬទេ?

**ឆ៖** អត់។

[១៣:៥២:២៨]

**សៈ** តើនរណាគេប្រាប់លោកដែលថា រស់ ញឹម ហ្នឹងនៅពេលនោះ ព្យាយាមរត់គេចទៅខេត្តកំពង់ចាម មុនពេលដែលគេចាប់ខ្លួនគាត់?

**ឆ៖** ខ្ញុំអត់ស្គាល់ឈ្មោះ គាត់មកហ្នឹង សួរឮដំណឹងពីគេ ឮគេថាអ៊ីចឹង ថាស្គាល់គាត់ច្បាស់។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

រង់ចាំបន្តិច មេធាវី គាត់ស្ដាប់លោកអត់ឮទេ ដោយសារតែឧបករណ៍របស់គាត់ស្ដាប់សំឡេងហ្នឹងអស់ថ្ម។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ គឺស្ដាប់ទៅអត់ឮអម្បាញ់មិញ ឧបករណ៍ខ្ញុំវាហាក់ដូចជាគាំងខូច។ សូមលោកសាក្សីឆ្លើយម្ដងទៀតលោកសាក្សី។

**2-TCW-1036៖**

**ឆ៖** ខ្ញុំអត់ដឹងទេ គាត់ទៅហ្នឹងក៏ ដោយសារគេប្រាប់។ អត់ស្គាល់ឈ្មោះគេ ប៉ុន្តែខ្ញុំអត់ជឿ អត់ឃើញនឹងភ្នែកខ្ញុំ។ ព្រោះថា ងាប់ហើយ ងាប់នឹងស្វាយ ចាប់នៅស្វាយ ខ្ញុំក៏ខ្ជិលសួរ ខ្ញុំដើរចេញមក។

[១៣:៥៣:៥៣]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**សៈ** ខ្ញុំសូមបន្តទៅមុខទៀតលោកសាក្សីសួរអំពីចំណុចផ្សេងវិញ។ លោកបានឃើញ រស់ ញឹម ប្រហែលជារៀងរាល់ថ្ងៃតាមខ្ញុំសន្និដ្ឋាន ឬក៏នៅចន្លោះឆ្នាំ៧៦ រហូតដល់ពេលគេចាប់ខ្លួនគាត់នៅឆ្នាំ៧៨។

01375098



តើលោកធ្លាប់ស្គាល់កូនៗរបស់ រស់ ញ៉ឹម ដែរឬទេ?

**ឆ៖** ស្គាល់។

**ស៖** តើលោកនៅនឹកឃើញ នៅចាំឈ្មោះពួកគាត់ដែរទេ?

**ឆ៖** ចាំ។

**ស៖** ហើយឈ្មោះអីដែរ?

**ឆ៖** ឈ្មោះ ជាល ហៅ ឆ្នាំង ហើយទី២ បាន -- នែ! នេះនែ! ភ្លេចហើយភ្លេច។ ឆ្នាំង, ស៊ីហួរ ហើយមួយទៀត ភ្លេចអស់ហើយបងអើយ។ អាពៅឈ្មោះ កញ្ច្រែង – ឈ្មោះកញ្ច្រែង ពៅគេស្រី បាទ គ្នាគាត់បួននាក់ ចាំៗតែបី។

**ស៖** តើគាត់មានកូនទីបី ឈ្មោះ ស៊ីហួរ ទេ?

**ឆ៖** ខ្ញុំអត់បានដេញដោលសួរផង កូនគាត់ ឃើញតែបីបួននាក់ហ្នឹង។

**ស៖** ខ្ញុំស្ដាប់ -- ខ្ញុំបានទទួលថា ឈ្មោះមានឈ្មោះមួយ ស៊ីហួរ នៅក្នុងឯកសារ E3/9581 នៅក្នុងសំណួរចម្លើយ៥៥ ក៏ប៉ុន្តែខ្ញុំអត់ គិតថាអាហ្នឹងចំណុចណាសំខាន់ទេ។ លោកបានលើកឡើងកូនបងរបស់គាត់ឈ្មោះ ជាល។ ហើយតើលោកដឹងទេ ជាល ហ្នឹងមានរៀបការទេនាពេលនោះ? ហើយការជាមួយនរណាគេដែរ?

**ឆ៖** អត់ដឹងផង គាត់នៅស្វាយស៊ីសុផុនឯណោះ។

[១៣:៥៦:៣៦]

**ស៖** តើ ជាល មានតួនាទីមុខងារអ្វីដែរនៅភូមិភាគពាយ័ព្យនុ៎ង?

**ឆ៖** អត់ដឹងគាត់ធ្វើអីផង ពេលគេនៅនឹងស្វាយហ្នឹង ដឹងគាត់ធ្វើអី អត់សូវដឹងដែរ។

**ស៖** តើលោកដឹងទេថា តើ រស់ ញ៉ឹម មានកូនចិញ្ចឹមដែរឬទេ?

**ឆ៖** អត់ដឹងផង ឃើញតែកូនគាត់។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំមានការកត់សម្គាល់មួយ ពីព្រោះថាក្នុងភាសាបារាំងខ្ញុំឮនិយាយពី ហ៊ួ នឹម ទៅវិញ។ អ៊ីចឹងសូមឲ្យលោកបញ្ជាក់ឲ្យច្បាស់ ហ៊ួ នឹម ឬក៏ រស់ ញ៉ឹម? បាទ អ៊ីចឹងសូមឲ្យអ្នកបកប្រែប្រយ័ត្នប្រយែង

ផង។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំអាចបញ្ជាក់ជាភាសាអង់គ្លេសបាន រស់ ញឹម។ បាទ មិនមែន ហ៊ូ នឹម ទេ រស់ ញឹម ជាឈ្មោះភាសាខ្មែរ។ ភាសាអង់គ្លេសគឺប្រកប អ័រ-អូ-អេស អេន-អេច-អាយ-អឹម – រស់ ញឹម។

**ស៖** លោកសាក្សី តើលោកពិតជាបាននិយាយថា លោកមិនស្គាល់ ហើយមិនបានដឹងថាគាត់មានកូនចិញ្ចឹម ឬកូនធម៌នោះទេ?

[១៣:៥៨:៣៩]

**2-TCW-1036៖**

**ឆ៖** អត់ដែលដឹងផង ដឹងគាត់នៅឯណា កូនគាត់។ នៅក្រឡាញ់អត់មានឃើញមាន។

**ស៖** គេសួរសំណួរលោកអំពីបុគ្គលម្នាក់ឈ្មោះ ហំ ឬក៏ តាហំ។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក លោកស្គាល់ ហំ ឈ្មោះ ហំ នេះមួយចំនួន។ តើលោកមានដឹង ហើយស្គាល់ តាហំ ឬ ដែលនៅកៀកនឹង រស់ ញឹម ដែរឬទេ?

**ឆ៖** ស្គាល់ តាហំ ហ្នឹងស្គាល់។

**ស៖** តើគាត់ជានរណាគេដែរ? ហំ ដែលនៅជាប់កៀកនឹង រស់ ញឹម នោះ?

**ឆ៖** ខ្ញុំអត់ស្គាល់ឈ្មោះ ស្គាល់ឈ្មោះតែ ហំ ហ្នឹងដែរ គាត់នៅជាប់ជិតគាត់ បានគាត់នៅទុកមន្ទីរ ការខុសត្រូវកន្លែងហ្នឹង។

**ស៖** ហើយ ហំ ដែលលោកនិយាយជាមួយនុ៎ង គឺគាត់គឺជាអនុសេនាធិការពាយ័ព្យហ្នឹងមែនដែរឬទេ?

**ឆ៖** មែន។

**ស៖** ហើយបុគ្គលដែលយើងជជែកគ្នានៅពេលនេះ តើគាត់មានឈ្មោះ <ធឿន ទាត់> ហើយដែលគាត់គឺជាឧត្តមសេនីយត្រីនៅក្នុងកងយោធពលខេមរភូមិន្ទ ហើយគាត់បានទទួលមរណភាពហើយ <កាលពីពីរខែមុននេះ> តើលោកដឹងទេ យើងនិយាយពីបុគ្គលហ្នឹង មែនដែរទេ?

**ឆ៖** អត់។ មិនដែលឃើញ មិនដែលអីផង មិនដែលស្គាល់ផង។

**លោក វ៉ិចទ័រ កូប៉េ៖**

នៅពេលនេះ ខ្ញុំមានរូបថត សូមអនុញ្ញាតពីលោកប្រធាន។ លោកប្រធាន ខ្ញុំចង់បង្ហាញរូបថត

ដែលយើងបានជជែកគ្នានៅមុនអាហារថ្ងៃត្រង់។ ខ្ញុំមានច្បាប់ថតចម្លងច្រើនដែរ ប្រសិនបើភាគីចាប់អារម្មណ៍នោះ គឺថាខ្ញុំអាចចែកជូនបាន។ ខ្ញុំក៏បានបញ្ជូនតាមរយៈអ៊ីម៉ែលផងដែរ លោកប្រធាន។

[១៤:០១:២៧]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអនុញ្ញាតពីលោកប្រធានដែរ បញ្ចាំងនៅលើអេក្រង់ដើម្បីឱ្យសាធារណជន និងអ្នកតាមដានទាំងអស់បានឃើញ។

**ប្រធានអង្គជំនុំ៖**

សូមមន្ត្រីសោតទស្សន៍ បង្ហាញរូបថតនេះតាមអេក្រង់ទូរទស្សន៍។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ មិនមែនរូបថតហ្នឹងទេ ខុសហើយ។

ខាងសោតទស្សន៍សូមចាក់បញ្ចាំង គឺរូបថតពណ៌។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** វាពិបាកក្នុងការបញ្ចាំងនៅលើអេក្រង់។ លោកសាក្សី តើលោកស្គាល់ទេបុគ្គលរូបហ្នឹង?

**2-TCW-1036៖**

**ឆ៖** អត់។

[១៤:០៣:១៨]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើលោកអាចបញ្ជាក់នៅក្នុង ដើម្បីជាប្រតិចារឹកទេ ដោយសារតែអត់ឃើញអំមិញ។

**លោក វ៉ិចទ័រ កូប៉េ៖**

រូបថតនេះ គឺជារូបថតរបស់បុគ្គលឈ្មោះ<ធឿន ទាត់> នេះមកផ្តល់សក្ខីកម្មនៅ<ខែមិថុនា> ឆ្នាំ២០១៥។<រូបថតនេះថតដោយអ្នកថតរូប ពេលដែលគាត់>អង្គុយនៅលើកៅអីតែមួយ<នេះ។ ដូច្នេះនេះគឺគាត់។>

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**អ្នកបកប្រែ៖**

សូមឱ្យ លោកប្រធាន សូមមេធាវីបញ្ជាក់ឈ្មោះឡើងវិញ ឮតែ តុំតូច។

**ប្រធានអង្គជំនុំ៖**

សូមលោកមេធាវីបញ្ជាក់ឈ្មោះៗហ្នឹងឡើងវិញ!

**លោក វ៉ិចទ័រ កូប៉េ៖**

គាត់មានឈ្មោះច្រើន គាត់បានមកផ្តល់សក្ខីកម្ម <ឈ្មោះ ធឿន ទាត់> នៅគាត់ ពេលដែលគាត់មកបញ្ជាក់ផ្តល់សក្ខីកម្មនៅទីនេះ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ប្រហែលជាលោកសូមបញ្ជាក់ឱ្យបានច្បាស់ ដោយសារតែវាមានបញ្ហាក្នុងការបកប្រែឈ្មោះនេះចេញ។

**លោក លីវ សុវណ្ណា៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបញ្ជាក់ឈ្មោះ គាត់ឈ្មោះ ទាត់ ធឿន – ទាត់ ធឿន។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកអត់ស្គាល់<រូបថតហ្នឹង>ទេ <ហើយឈ្មោះក៏លោក>អត់ដែលឮឈ្មោះហ្នឹងទេ <តើមែនទេ>?

**ឆ៖** អត់។

[១៤:០៥:១២]

**ស៖** ខ្ញុំព្យាយាមសួរម្តងទៀតលោកសាក្សី។ គាត់ក៏ប្រើឈ្មោះមួយទៀត ផ្សេងទៀតផងដែរ ប្រហែលជាឈ្មោះហ្នឹងអាចលោកស្តាប់ទៅស្រដៀង។ លោកប្រធានខ្ញុំយោងលើឯកសារ E3/10665 បាទ គឺ E3/10665 គឺជា<ប្រតិចារឹកនៃ>កិច្ចសម្ភាសន៍របស់អ្នកធ្វើខ្សែវីដេអូ រ៉ូប៊ីត លឹមគិន ជនជាតិអង់គ្លេស <ជាមួយនឹង ទាត់> ហើយហៅដាក់នៅក្នុងហ្នឹងដាក់ឈ្មោះថា ហំ។ ជាពិសេសនៅក្នុង ERN ជាភាសាអង់គ្លេស <01156797>, ខ្មែរ 01168438 អត់មានបកប្រែជាភាសាបារាំងនោះទេ។ បុគ្គលរូបនេះក៏គេហៅឈ្មោះគាត់ថា ឈ្មោះ ម៉េត។ គាត់<និយាយ>អំពីកូនក្តីរបស់ខ្ញុំឈ្មោះ នួន ជា នេះ

<ហើយ> នួន ជា នេះស្គាល់ តាហំ <ដែលមាន>ឈ្មោះ<ថា> ម៉េត ផងដែរ។ តើលោកស្ដាប់ហើយហ្នឹង តើលោកនឹកឃើញទេ?

**ឆ៖** នឹកមិនឃើញទេ ខ្ញុំមិនស្គាល់ផង។

**ស៖** មិនអីទេលោកសាក្សី។ ខ្ញុំសួរអំពីកូនបងរបស់ រស់ ញឹម លោកបញ្ជាក់ហើយថា មិនដឹងថាគាត់ការ<ឬក៏អត់>នោះទេ។ ខ្ញុំសួរសំណួរបន្តទៀតទៅលើចំណុចហ្នឹង តើលោកស្គាល់អតីត មេភូមិភាគបូព៌ាឈ្មោះ សោ ភឹម ដែរឬទេ?

**ឆ៖** អត់ផង។

[១៤:០៧:៤៤]

**លោក វិុចទ័រ កូប៉េ៖**

លោកប្រធានខ្ញុំសូមអនុញ្ញាតបញ្ចាំងរូបថតមួយទៀតផងដែរ រូបថតរបស់បុគ្គលម្នាក់គឺបុគ្គល សោ ភឹម ហើយខ្ញុំសូមបញ្ចាំងនៅលើអេក្រង់ផងដែរលោកប្រធាន ហើយខ្ញុំនឹងសួរសំណួរទៅកាន់សាក្សីថា តើសាក្សីស្គាល់បុគ្គលហ្នឹងនៅរូបថតខាងឆ្វេងដែរឬទេ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ដូចធម្មតា យើងត្រូវការឲ្យវាមាន>នៅក្នុងសំណុំរឿង<ដែលបានផ្ដល់ឲ្យ វាអត់ទាន់មាននៅទីនោះ>ទេ?

**លោក វិុចទ័រ កូប៉េ៖**

<វាមាននៅក្នុងសំណុំរឿងរួចហើយ។ គឺ>ឯកសារ E3/3015R <ហើយវាយកចេញពីខ្សែភាពយន្តមួយ> នៅត្រង់ម៉ោង ០១:២៤។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមឲ្យមន្ត្រីសោតទស្សន៍ដាក់បង្ហាញរូបថតតាមអេក្រង់ទូរទស្សន៍។

មន្ត្រីរដ្ឋបាលតុលាការយករូបថតនេះ យកទៅបង្ហាញឲ្យសាក្សី។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ហើយសូមបញ្ចាំងនៅលើអេក្រង់ កុំដកចេញ ជាការណែនាំទៅដល់ខាងផ្នែកសោតទស្សន៍។

[១៤:០៩:២៤]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី បុគ្គលម្នាក់ពាក់មួកកន្ទីប នៅខាងឆ្វេងនេះចុងខាងឆ្វេងនេះ តើលោកស្គាល់គាត់ទេ?

**2-TCW-1036៖**

**ឆ៖** អត់។

**ស៖** ហើយចុះអ្នកដែលឈរបន្ទាប់នៅអ្នកខាងឆ្វេងហ្នឹងលោកស្គាល់ទេ?

**ឆ៖** អត់ដែរ។

**ស៖** តើលោកមិនដែលធ្លាប់ឃើញ ប៉ុល ពត ពីមុនទេ ឬក៏យ៉ាងម៉េច?

**ឆ៖** អត់ដែលឃើញ។

[១៤:១០:០៤]

**ស៖** អ៊ីចឹងមិនអ្វីនោះទេ។ ខ្ញុំសាកសួរលោកក្នុងសំណួរផ្សេងវិញម្តង តើលោកនឹកឃើញទេ ហើយបន្ទាប់ បើសិនជាមិននឹកមិនឃើញទេ ខ្ញុំនឹងបន្តទៅប្រធានបទផ្សេង។ លោកសាក្សី បុគ្គលឈ្មោះ ហំ ដែលជាអតីតអនុសេនាធិការនៅខាងពាយ័ព្យនេះ គឺថាបានមកផ្តល់សក្ខីកម្មនៅក្នុងតុលាការនេះ។ គាត់បាននិយាយរៀបរាប់អំពីការរៀបអាពាហ៍ពិពាហ៍របស់ ជាល ដែលរៀបការជាមួយកូនស្រីរបស់ សោ ភឹម ដែលនៅក្នុងរូបថតហ្នឹង គឺគាត់ឈរខាងឆ្វេង។ គាត់បានជម្រាបនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ -- ម៉ោង <០៩:៤៥> គាត់បានឆ្លើយនៅតុលាការកំពូល គាត់ថាគេរៀប -- អ្នកទាំងពីររៀបការឆ្នាំ៧៨។ ហើយ ហំ នេះក៏បានឆ្លើយប្រាប់ទៅ រ៉ូប៊ីត លឹមគិន ដែលជាអ្នកថតខ្សែភាពយន្តផងដែរ គាត់បាននិយាយប្រាប់អ្នកថតខ្សែភាពយន្តនោះថា អ្នកទាំងពីរហ្នឹង គាត់រៀបការក្រោយថ្ងៃរំដោះ ឆ្នាំ៧៥ ហើយ ហំ ហ្នឹង ក៏បានលើកឡើងផងដែរ ខ្ញុំសូមដកស្រង់ជាក់លាក់ចេញពីកិច្ចសម្ភាសន៍របស់គាត់តែម្តង។ ឯកសារ E3/10665, ERN ត្រង់ <01156806>, ឯកសារខ្មែរ 01168451 គាត់បានឆ្លើយថា សោ ភឹម គឺជាឪពុកក្មេករបស់កូនបងលោក រស់ ញឹម។ គាត់មកទស្សនកិច្ចរៀងរាល់បួន ឬក៏ប្រាំខែម្តង មកពីខាងបូព៌ា។ នៅពេលដែលលោកជាកងការពាររបស់ រស់ ញឹម នេះ តើធ្លាប់ដែលឃើញ សោ ភឹម នេះ មកបួន ឬក៏ប្រាំខែម្តង ដើម្បីមកជួបនឹង<កូនស្រី និង>កូនប្រសាប្រុសរបស់គាត់ដែរឬទេ?

[១៤:១៣:១០]

**ឆ៖** អត់ដែលឃើញទេ។ ខ្ញុំនៅនោះ ក៏គេមិនឲ្យខ្ញុំ គេធំៗមិនឲ្យមកចូលជិតកន្លែងគាត់ទេ ខ្ញុំនៅ

ក្រៅៗហ្នឹង ការពារក្រៅ។

**សៈ** ខ្ញុំសូមត្រឡប់សួរអំពីការរៀបការរបស់កូនបងលោក រស់ ញឹម និងកូនស្រីរបស់ សោ ភឹម <នៅខែសីហា ឆ្នាំ៧៥។> ឯកសារហ្នឹងគឺ<ជាភាសាអង់គ្លេស 01156803> ខ្មែរ 01168447 ដែលគាត់បានឆ្លើយប្រាប់ រ៉ូបឺត លឹមគិន គាត់បានលើកឡើងអំពីករណីដែលថាគាត់ទៅចូលរួមអាពាហ៍ពិពាហ៍ការរៀបការឆ្នាំ -- ក្រោយឆ្នាំ៧៥ <នៅបូព៌ា> ដែលជាការរៀបការរបស់កូន សោ ភឹម។ តើលោកមានដែល -- តើលោកនឹកឃើញទេថាលោកធ្លាប់ជូនលោក រស់ ញឹម ទៅចូលរួមការរៀបការកូនប្រុសរបស់គាត់ ឬក៏ធ្លាប់ពួកឯងការពាររបស់ រស់ ញឹម ហ្នឹងរៀបរាប់ថាធ្លាប់ដឹក រស់ ញឹម ហ្នឹងទៅរៀបការកូនគាត់នៅក្រោយឆ្នាំ៧៥?

**ឆៈ** អត់ដែលទេអាហ្នឹង មិនដែលបើកទេ គេផ្សេងអ្នកបើក។

[១៤:១៤:៥៧]

**សៈ** មិនជាថ្វីនោះទេ។ ខ្ញុំសូមចូលទៅដល់ប្រធានបទមួយទៀតដែលយើងចាប់អារម្មណ៍យ៉ាងខ្លាំង<និងមូលហេតុ>ដែលលោកមកផ្តល់សក្ខីកម្មនៅទីនេះ។ លោកសាក្សី តើលោកនៅចាំថា បានជូន តាញឹម ទៅកាន់ភ្នំដិន ដែរឬទេ?

**ឆៈ** អត់ដែលជូនផង។

**សៈ** បាទ ជាចម្លើយមួយដែលគួរឲ្យចាប់អារម្មណ៍។

**ឆៈ** ខ្ញុំមិនដែលជូនគាត់ទៅទេ។ ខ្ញុំគ្រាន់ ដែលគាត់ទៅភ្នំដិន ខ្ញុំដោយសារគាត់ឲ្យអ្នកក្រៅងទៃហ្នឹង ដែលគេបើកជាប់ កាលនោះបើកឡានទៅ ដឹករបស់របរពីភូមិភាគនោះមក។ ដឹងតែចាំ គេយកមកឲ្យខ្ញុំ បើកពីនោះមកវិញមក។ ខោអាវ។

**សៈ** ខ្ញុំសួរឲ្យចំៗតែម្តង លោកសាក្សី ហើយខ្ញុំសាកល្បងមើល តើខ្ញុំអាចឲ្យលោកនឹកឃើញដែរឬទេ។ គឺត្រឹម<>តែបីឆ្នាំកន្លងទៅតែប៉ុណ្ណោះ។ នៅពេលនោះ បីឆ្នាំមុនលោកបានជម្រាបអ្នកស៊ើបអង្កេតដូចតទៅ ឯកសារ E3/9581 លោកប្រធាន សំណួរចម្លើយទី៣ និងទី៤។ “ខ្ញុំធ្លាប់ជូន តាញឹម ទៅភ្នំដិន ដែលនៅជាប់ព្រំដែនវៀតណាម” បាទ ខ្ញុំឈប់ត្រឹមហ្នឹងសិន។ នៅក្នុងហ្នឹង លោកបានឆ្លើយថា លោកធ្លាប់ជូន តាញឹម ទៅភ្នំដិន។ តើត្រឹមត្រូវដែរឬទេ?

**ឆៈ** អត់។

**សៈ** សំណួរដែលសួរបន្ទាប់ពីហ្នឹង ទៅ អ្នកស៊ើបអង្កេត សួរថា៖ “តើហេតុអ្វីបានជាលោកទៅ

ភ្នំដិនជាមួយ តាញ៉ឹម? គាត់ឲ្យខ្ញុំការពារ ពេលដឹកខោអាវយោធាពីភ្នំដិន មកដាក់នៅអំពិលប្រហោង និង នៅស៊ីសុផុន ក្នុងឆ្នាំ១៩៧៧។ ស៊ីសុផុន ក៏ជាកន្លែងឃោធារបស់ តាញ៉ឹម ដែរ។" តើលោកនឹកឃើញទេ លោកសាក្សី?

**ឆ៖** នឹកឃើញហើយ មកហ្នឹងមែន។ ភ្លេច មិនដឹងប៉ុន្មាន ភ្លេច ខ្ញុំមិនសូវដឹងអីផង។ ឥឡូវ វាចេះតែភ្លេចភ្លាំងហើយ។

[១៤:១៨:៥០]

**ស៖** បាទ ខ្ញុំសប្បាយចិត្ត ដែលខ្ញុំអាចឲ្យលោកនឹកឃើញឡើងវិញ លោកសាក្សី។ តើលោកនៅចាំអ្វីខ្លះពាក់ព័ន្ធនឹង តាញ៉ឹម ហើយនិងលោកទៅភ្នំដិន ដើម្បីដឹកខោអាវយោធាហ្នឹង តើលោកនឹកឃើញអ្វីខ្លះដែរទៅ?

**ឆ៖** ខ្ញុំអត់នឹកឃើញ នឹកថាគ្រាន់តែដឹកអីវ៉ាន់មក គាត់ ដឹងទៅណាណី អត់ដឹង។ ដឹងតែការពារគាត់ គេមិនឲ្យចូលគាត់ផង។ យាមឆ្ងាយពីគាត់។ គេអោអ្នកការពារផ្សេង ជាប់នឹងគាត់ហ្នឹង។ ខ្ញុំក្រៅគាត់ ទី២ យាម។

**ស៖** តើភ្នំដិននៅកន្លែងណាដែរ លោកសាក្សី?

**ឆ៖** ខ្ញុំចេញយប់ អត់ដឹង យប់។ ទាល់តែគេអ្នកស្គាល់ផ្លូវ ខ្ញុំមិនដែលមកផង ខ្ញុំអត់ស្គាល់។ ខ្ញុំមកជាមួយគេ គេនាំមក។

**ស៖** ប៉ុន្តែជាប្រហាក់ប្រហែល លោកអាចគិតថា ភ្នំដិនហ្នឹងនៅកន្លែងណាដែរ? តើភ្នំដិនស្ថិតនៅទីណាដែរ?

**ឆ៖** គេថា ភ្នំដិន ជាប់ស្រុកយួន បើខ្ញុំមិនដែលមក ឮគេថា ពួកគាត់ថា ហើយខ្ញុំមកជាមួយគេមក មិនដឹងផ្លូវណាណីចេះតែបើកជាមួយគេមក គេនាំផ្លូវទៅ។ ដល់ដាក់ឡាន យកឡានទៅ ដឹកអីវ៉ាន់មក បានបើកមកវិញ។

[១៤:២០:៥៨]

**ស៖** យើងមើលទៅលើផែនទីទៅឃើញថា វាជាប់ព្រំដែនវៀតណាម។ ភ្នំដិននេះ គឺថាស្ថិតក្នុងភូមិភាគនិរតី។ តើលោកនិងអ្នកដទៃទៀតនេះ បានទៅធ្វើដំណើររួមគ្នាជាមួយ តាញ៉ឹម ទៅដឹកឯកសណ្ឋានកងទ័ពមកពីភ្នំដិន នៅពេលណា?

**ឆ៖** គាត់ទៅថ្ងៃ ខ្ញុំទៅយប់។ អត់ដឹង ភ្លាមម៉ោងប៉ុន្មានផង អត់ដឹង។ បែបវាស់ព្រឹក ឡាន មិន

ដែលបើកថ្ងៃទេ មកដឹកអីៗក៏ដោយមិនដែលចេញមកថ្ងៃទេ ចេញតែយប់។

**ស៖** ខ្ញុំយល់ស្របហើយថាលោកដឹកហ្នឹងនៅពេលយប់។ ក៏ប៉ុន្តែ តើនៅក្នុងឆ្នាំ១៩៧៦ ឬ៧៧ ឬក៏នៅពាក់កណ្តាលឆ្នាំ៧៨ លោកនឹកឃើញទេ?

**ឆ៖** នឹកឃើញ។ ឆ្នាំ៧៨ -- ប្រាំពីរៗ ប៉ុនអាដឹកហ្នឹងមិនដឹងឆ្នាំណា ដល់៧៧ បែកបាក់គ្នាអស់រលីង ហើយពួកនោះវាចូលមក រប៉ាត់រប៉ាយពេញស្រុក ពេញភូមិអស់។

**ស៖** តើវាចុងឆ្នាំ៧៧ ឬក៏យ៉ាងណា លោកអាចនឹកឃើញទេ?

**ឆ៖** ចុងបងចុង។

**ស៖** តើនៅពេលហ្នឹងការវាយប្រយុទ្ធគ្នាជាមួយនឹងកងទ័ពវៀតណាម កំពុងតែបន្តប្រយុទ្ធគ្នាឬ?

**ឆ៖** ខ្ញុំអត់នៅ ប្រជាជនធ្វើអីផង ដែលវៀតណាមចូលនោះ។

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយដដែល ដែលខ្ញុំលើកឡើងនោះ លោកថា តាញ៉ឹម មិនបានទៅភ្នំដិន ញឹកញាប់ទេ គាត់ទៅម្តងម្កាល ហើយយូរណាស់ហើយ។ តើលោកចង់និយាយថាដូចម្តេចដែលលោកថា តាញ៉ឹម ហើយនិងខ្លួនលោកផ្ទាល់ហ្នឹងទៅភ្នំដិន ទៅដឹកឯកសណ្ឋានកងទ័ពហ្នឹង តើតាញ៉ឹម ទៅហ្នឹងទៅតែ ម្តង ពីរដង ឬក៏ប្រាំដង។ លោកនឹកឃើញទេ ប៉ុន្មានដងដែរ?

[១៤:២៤:២៤]

**ឆ៖** បាទនឹកឃើញ។ ប៉ុន្តែទៅ ខ្ញុំអត់ដឹងគាត់ទៅប៉ុន្មានដង អត់ដឹងទេ ខ្ញុំដឹងតែដឹកខោអាវតែម្តងហ្នឹងឯង។ មានផែនការថ្មីអត់ប្រាប់ខ្ញុំ គាត់ធ្វើរៀងខ្លួន។ ខ្ញុំក៏បែកពីគាត់ទៅ ចូលជាឆ្នាំ៧៧, ៧៨ហ្នឹង។

**ស៖** តើឯកសណ្ឋានកងទ័ពហ្នឹង ជាឯកសណ្ឋានរបៀបណាដែលលោកដឹកជញ្ជូនមកពីភ្នំដិន គឺដឹកមកពីភ្នំដិននៅជាប់ព្រំដែនកម្ពុជាវៀតណាមនោះ? ហើយលោកដឹកហ្នឹងដឹកទៅស៊ីសុផុន គឺដឹកទៅភូមិភាគពាយ័ព្យ លោកនឹកឃើញទេ ថាឯកសណ្ឋានទាំងអស់នេះជាឯកសណ្ឋានរបៀបណាដែរ?

**ឆ៖** ឯកសណ្ឋានវៀតណាម ខៀវៗ។

**ស៖** តើលោកអាចប៉ាន់ប្រមាណបានទេ លោកដឹកជញ្ជូនឯកសណ្ឋានហ្នឹងដឹកជញ្ជូនឯកសណ្ឋានពីព្រំដែនវៀតណាមត្រឡប់ទៅភូមិភាគពាយ័ព្យវិញហ្នឹងចំនួនប៉ុន្មានកំប្លេដែរ?

**ឆ៖** គាត់អត់ប្រាប់ផង ដឹកប៉ុន្មានៗអត់ដឹងទេ គ្រាន់តែដឹកមក។

**ស៖** លោកទើបនិយាយអម្បាញ់មិញថា ជាឯកសណ្ឋានវៀតណាម ធ្វើម៉េចបានលោកដឹង? តើវាមានកាលៈទេសៈឬក៏មានឱកាសណាមួយដែលនាំឲ្យលោកពិនិត្យមើលដឹងថាហ្នឹងគឺជាឯកសណ្ឋាន

ខោអាវកងទ័ពវៀតណាម? ម៉េចបានៗលោកដឹង?

**ឆ៖** ចុះបើឃើញនៅកន្លែងជាប់ហ្នឹង បើកឲ្យអ្នកការពារគាត់ហ្នឹង។

**ស៖** ខ្ញុំយល់ហើយ ប៉ុន្តែតើវាមានៗសំអាងអ្វីដលនាំឲ្យលោកទើបតែនិយាយអម្បាញ់មិញថា ខោអាវហ្នឹងគឺថាវាមានប្រភពចេញមកពីវៀតណាម?

**ឆ៖** ប្រភពចេញ ខ្ញុំអត់ដឹង ដឹងគាត់ -- ខ្ញុំមិនប៉ានទៅជិតគាត់ផង ដឹងគាត់ត្រូវគ្នាម៉េចៗអត់សួរដឹងដែរ។

[១៤:២៧:៤១]

**ស៖** តើលោកដឹងទេថា ហេតុអ្វីបានជា រស់ ញឹម ខ្លួនគាត់ផ្ទាល់ដែលជាលេខាភូមិភាគពាយ័ព្យ គឺថាធ្វើដំណើរទៅព្រំដែនវៀតណាមដោយផ្ទាល់ខ្លួនទៅដឹកឯកសណ្ឋានខោអាវកងទ័ពវៀតណាម ហើយដឹកត្រឡប់ទៅវិញទៅទីតាំងរបស់គាត់នៅស៊ីសុផុន ភូមិភាគពាយ័ព្យ នៅឯអំពិលប្រហោង? ហេតុអ្វីក៏ រស់ ញឹម ខ្លួនគាត់ហ្នឹងទៅជាមួយដែរ?

**ឆ៖** ចាខ្ញុំអត់ដឹងទេ ទៅហ្នឹង អត់មានទៅផង គាត់និយាយតាមទូរស័ព្ទយើងទូរស័ព្ទខ្សែហ្នឹង។

**ស៖** ចុះគាត់និយាយថាដូចម្ដេច? លោកឮថា លោកឮគាត់និយាយដូចម្ដេចដែរ?

**ឆ៖** អត់មានទេបង អត់មាននិយាយប្រាប់ពួកខ្ញុំទេ ព្រោះអាពួកគាត់ជាប់នឹងគាត់ៗប្រាប់ បើខ្ញុំអ្នកការពារក្រៅ ក្រុមទី២ គេទី១ ខ្ញុំទី២។ កាលណាទៅឆ្ងាយហៅខ្ញុំទៅ បើមិនបានទៅនៅផ្ទះ ដេកនៅផ្ទះទៅ កន្លែងហ្នឹង។ យូរៗទៅម្ដង មានផែនការទៅ មានផែនការក៏មិនប្រាប់ខ្ញុំដែរ អត់។ ខ្ញុំអត់សួរដឹងរឿងប៉ុន្នានទេ។

**ស៖** តើលោកដឹងទេនៅពេលទៅដឹកជញ្ជូនហ្នឹងគេប្រើប្រាស់រថយន្តប៉ុន្មានគ្រឿងដែរ?ខ្ញុំដឹងថាៗលោកបើកអាហ្ស៊ីបពណ៌ស ប៉ុន្តែឡានដទៃទៀតហ្នឹងណា សរុបទៅទាំងអស់ប៉ុន្មានគ្រឿងដែរ ទៅដឹកឯកសណ្ឋានកងទ័ពនុ៎ង?

**ឆ៖** *(ឮមិនច្បាស់)* ទៅតែមួយគ្រឿង ឡានអាស្លាក ហ្សេ.អឹម.សេ កង់១០។

[១៤:២៨:៥៨]

**ស៖** តាមខ្ញុំស្ដាប់ទៅ ខ្ញុំយល់ថាឯកសណ្ឋានហ្នឹងគឺយកមកដាក់នៅក្នុងឡានធំនុ៎ងមែនទេ?

**ឆ៖** បាទ។

**ស៖** រួចចុះ ខ្លួនលោកផ្ទាល់ៗហ្នឹង បានជួយលើកដាក់ឯកសណ្ឋានយោធាហ្នឹងដាក់ទៅចូលក្នុង

01375108



ឡាន ហ្សេ.អឹម.សេ ហ្នឹងដែរឬទេ?

ឆ៖ អត់ទេ។ គេដឹកខ្លួនគេយកមកឲ្យ គេដូរកម្លាំងគ្នា គេមិនឲ្យយើងចូលទៅ។

ស៖ ចុះហេតុអីបានជាគេមិនអនុញ្ញាតឲ្យលោកជួយលើកដាក់?

ឆ៖ ខ្ញុំនៅក្រៅណេះបង នៅកន្លែង បើគេយកឡានទៅដឹកមក គេឲ្យខ្ញុំចាំនៅហ្នឹង ហូបបាយនៅហ្នឹង គេដឹកខ្លួនគេយកមក។ ម៉ោងប្រាំមួយ ម៉ោងប្រាំពីរបានចេញពីនុំងមក។ ខ្ញុំមិនសូវដែលមកផងភ្នំពេញអីមិនដែលមកទេ មិនស្គាល់ផង។ គេដឹកយកមកឲ្យ ខ្ញុំយប់បើកមក។

[១៤:៣១:២៧]

ស៖ តើលោកអាចរៀបរាប់ជូនតុលាការបន្តិចបានទេថា តើការដឹកជញ្ជូនហ្នឹង ដឹកជញ្ជូនតាមផ្លូវជាតិមួយណា ហើយនៅពេលដឹកជញ្ជូនហ្នឹង តើឈប់ប៉ុន្មានដងដែរ ឈប់ញ៉ាំញ៉ាំទេ ហើយនៅពេលដែលដឹកជញ្ជូនឯកសណ្ឋានហ្នឹង តើត្រូវបានកងទ័ព ឬក៏កម្មាភិបាលដទៃទៀតត្រួតពិនិត្យឆែកឆេរមើលឡាន ហ្សេ.អឹម.សេ ហ្នឹងដែរទេ? សូមលោករៀបរាប់ឲ្យបានលម្អិតបន្តិចបានទេ?

ឆ៖ អត់ទេបង មានឆែកឆេរអីទេ បើថាដឹកមានអ្នកណាឆែកឆេរ លេខ៣២ លេខគាត់ហ្នឹង ១៣២ មានអ្នកណាឆែកផង ដឹកមកតាមផ្លូវ អត់។

ស៖ លេខ៣២ហ្នឹង លេខ៣២ តំណាងឲ្យអីដែរលោក?

ឆ៖ ដាក់លេខឡានគាត់នុំង ដាក់លេខឡាន៣២។

ស៖ ខ្ញុំខ្លាចតែខ្ញុំស្ដាប់លោកមិនយល់ទេ។ លោកខ្លួនឯងនិយាយថា លោកទៅពេលយប់ ហើយ រស់ ញឹម ទៅពេលថ្ងៃ។ តើនេះគឺជាអ្វីដែលលោកទើបឆ្លើយអម្បាញ់មិញនេះមែនទេ?

ឆ៖ បាទ ខ្ញុំដឹងថាគាត់មិនដែលទៅយប់ទេ។ បើថាថ្ងៃខ្ញុំ -- យប់មានការអី យូរទៅម្ដង មិនដែលជាប់ជាមួយគាត់ទេ អត់សូវដឹងប៉ុន្មានផង។ គេរកតែគ្រាន់បើជាមួយគាត់ ដើរជាប់ជាមួយគាត់ហ្នឹង។

ស៖ តើលោកដឹងទេ នៅពេលដែល រស់ ញឹម ទៅជាមួយនឹងលោក ហើយនិងអ្នកដទៃទៀតទៅឯភ្នំដិនហ្នឹង អ្នកណាជាអ្នកបើកបរជូនគាត់ តាមដែល ការដឹកផ្ទាល់របស់លោកហ្នឹង អ្នកណាជាអ្នកបើកបររបស់គាត់?

ឆ៖ ឈ្មោះអាជ្រូក ហៅតែ អាជ្រូកៗ វាធាត់ដូចជ្រូក ហៅ អាជ្រូក។

[១៤:៣៤:១៨]

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**ស៖** តើតាញ៉ឹម ចេញទៅមុន ហើយលោកជាមួយនិងឡានធំនោះទៅតាមក្រោយ ឬក៏យ៉ាងណា ឬក៏លោកចេញទៅមុន តាញ៉ឹម ទៅតាមក្រោយវិញ?

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំកត់សម្គាល់ឃើញថា ខ្ញុំមិនជំទាស់ទេ ក៏ប៉ុន្តែឃើញសាក្សីនេះ ពិភាក្សាជាមួយមេធាវីប្រឹក្សារបស់គាត់ ហើយប្រសិនណាជាគាត់មិនយល់កន្លែងណា អាចសួរ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំអត់បានកត់សម្គាល់ឃើញអ៊ីចឹង ប៉ុន្តែលោកចង់ឲ្យសាក្សីហ្នឹងនិយាយប្រាប់លោក ថាគាត់និយាយអ្វីជាមួយមេធាវីឬ?

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ អ៊ីចេះទេ ខ្ញុំអ៊ីចេះគឺថា ខ្ញុំរំលងសំណួរ។ ខ្ញុំមើលទៅឃើញដូចសាក្សីខ្លាចហើយភ័យ។ គាត់រាងដូចជាភ័យញាប់ញ័រណាស់។ <ជាការពិត ខ្ញុំមិនចង់ដឹងអ្វីដែលបានផ្តល់ការប្រឹក្សាយោបល់នោះទេ ប៉ុន្តែបើមានអ្វីដែលយើងគួរដឹងនោះ អ៊ីចឹងពេលនេះគឺជាពេលសមរម្យហើយ>។

**ប្រធានអង្គជំនុំ៖**

លោកសាក្សី! លោកឆ្លើយតាមសំណួររបស់ -- សំណួររបស់លោកមេធាវី ហើយលោកកុំបារម្ភនិងខ្លាច ហើយលោកមានសិទ្ធិឆ្លើយអ្វីដែលលោកបានចាំចងចាំកន្លងមក។ សូមអញ្ជើញ!

**2-TCW-1036៖**

**ឆ៖** គេយើងនិយាយជាប់ជាមួយគាត់ហ្នឹង ខ្ញុំវា ចូល៧២ បន្តៗមកដល់ នេះមកគាត់ឈប់ឲ្យខ្ញុំនេះទៅដើរ កន្លែងៗ មិនសូវជាប់គាត់ប៉ុន្មាន។

**ប្រធានអង្គជំនុំ៖**

លោកសាក្សី សូមលោកឆ្លើយឲ្យលះៗ ដាច់ៗ លោកកុំខ្លាចអីទាំងអស់។ ឆ្លើយដូចលោកនិយាយនៅផ្ទះអ៊ីចឹង។

**2-TCW-1036៖**

**ឆ៖** មិនយល់។ ឲ្យខ្ញុំនិយាយមូលហេតុអី *(ឮមិនច្បាស់)*។

**ប្រធានអង្គជំនុំ៖**

លោក១១មេធាវី លោកសួរសំណួរម្តងទៀត ហើយលោកសាក្សីចាំស្តាប់សំណួររបស់លោក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មេធាវីដោយយកចិត្តទុកដាក់ឲ្យច្បាស់លាស់ ដើម្បីរំឭកការចងចាំរបស់លោក។

[១៤:៣៧:១៩]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំអាល័យតែបារម្ភអំពីសាក្សី ក៏ភ្លេចសំណួរសួរមុនហ្នឹងមិនដឹងសួរថាម៉េចដែរ ក៏ប៉ុន្តែមើលម៉ោងទៅក៏ដល់ពេលសម្រាកហើយលោកប្រធាន។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកសាក្សី លោកស្រួលបួលទេហ្ន៎! លោកៗស្រួលខ្លួនទេហ្ន៎! ឬក៏លោកមានៗអារម្មណ៍ថា សុខភាពមិនល្អទេឬក៏យ៉ាងណា?

**2-TCW-1036៖**

ដូចរាងភ័យៗហ្នឹងដែរ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ភ័យ សម្រាប់សាក្សី គឺធម្មតាអ៊ីចឹងហើយ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** មិនជាថ្វីទេ ឥឡូវខ្ញុំសូមសួរសំណួរមួយចុងក្រោយសម្រាប់មុនពេលឈប់សម្រាកនេះ។ លោកសាក្សីៗ លោកចង់ឆ្លើយនៅក្នុងសវនាការអសាធារណៈ មានន័យថា គឺលោកចង់ឲ្យសួរលោកជាសម្ងាត់ឬ?

**2-TCW-1036៖**

**ឆ៖** ប៉ុនវាមិនសូវចាំផង ហើយខ្ញុំ ដូចច្រើនពេករាងប្រផិតប្រផើយ វាមុខភ្លេចក្រោយ ក្រោយភ្លេចមុខ ដដែលៗមិនបានឆ្លើយ។

**ស៖** ខ្ញុំក៏សូមស្នើសុំទៅដល់មេធាវីប្រឹក្សាផងដែរ សូមឲ្យសួរទៅកូនក្តីរបស់គាត់មើល មេធាវីតើកូនក្តីហ្នឹង យើងថាចាំបាច់ត្រូវសួរគាត់នៅក្នុងសវនាការអសាធារណៈឬក៏យ៉ាងណា?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

[១៤:៣៩:០៧]

**លោក ឌេល លីសាក់៖**

ខ្ញុំសូមជំទាស់ទៅនឹងគំនិតយោបល់របស់មេធាវីការពារក្ដីដែលស្នើសុំ ទៅជាស្នើសុំសាក្សី ថាតើចង់ឲ្យសួរក្នុងសវនាការសាធារណៈ ឬអត់។ យើងមានវិធានដែលកំណត់អំពីសវនាការអសាធារណៈ លើកលែងតែវាមានមូលហេតុច្បាស់លាស់បង្ហាញឲ្យឃើញថាត្រូវតែធ្វើសវនាការ ឬក៏ដំណើរការកិច្ចនីតិវិធីជាអសាធារណៈ នោះទើបធ្វើយ៉ាងដូច្នេះបាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្វង់ម៉ាក។

**ចៅក្រម ហ្វង់ម៉ាក ឡាវ៉ែន៖**

បាទ នេះជាសំណើទៅមេធាវី នួន ជា ខ្ញុំយល់ថាលោកបានកំណត់ទីតាំងភ្នំដិន នៅលើផែនទី។ ដូច្នេះតើលោកអាចដាក់ផែនទីនេះនៅក្នុងសំណុំរឿងបានទេ? <ប្រហែលយើងអាច>ភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងប្រតិចារឹកសវនាការ ដើម្បីឲ្យយើងយល់ច្បាស់ថាលោកកំពុងតែនិយាយអំពីអ្វី ហើយប្រហែលជាលោកអាចបង្ហាញផែនទីនេះជូនសាក្សីផង។ ខ្ញុំមិនដឹងថាតើអាចមានភ្នំដិនផ្សេងទៀតដែរឬក៏អត់នៅកម្ពុជានោះ។

**លោក វ៉ិចទ័រ កូប៉េ៖**

មិនថ្វីទេ លោកចៅក្រម។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

ជាការឆ្លើយតបសប្ដាហ៍មុននោះ សហព្រះរាជអាជ្ញារងបានបង្ហាញផែនទី បង្ហាញផ្លូវនៃប្រទេសកម្ពុជាហើយ គឺថាយើងអាចមើលឃើញភ្នំដិនហើយ។ ភ្នំដិននេះគឺថាគេស្គាល់ច្រើនល្បីណាស់ ពីព្រោះវានៅព្រំដែន <នៅតាកែវ ឬគិរីវង់។ ដូច្នេះខ្ញុំមិនច្បាស់ទេថា តើវានៅក្នុងភស្តុតាង ឬក៏វាត្រូវបានដាក់ចូលក្នុងហ្សាយឡេបហើយឬនៅ ប៉ុន្តែ>យើងមើលផែនទី យើងឃើញហើយ។

[១៤:៤១:១៧]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តាមដែលយើងដឹងនោះ គឺថាផែនទីបង្ហាញផ្លូវជាតិនៅកម្ពុជានេះ បានទទួលយកដាក់ក្នុងសំណុំរឿងហើយ។ <ខ្ញុំគិតថា មូលហេតុដែលចៅក្រមឡាវ៉ែនសួរនោះ ព្រោះមើលទៅលោកដូចជាកំពុងតែ

ផ្តល់សក្ខីកម្មទៅលើទីតាំងតំបន់នោះ> ហើយបើសិនណាជាយើងមានផែនទីនេះទទួលដាក់ក្នុងសំណុំរឿងហើយ យើងអាចយកមកសួរ អាចយកមកបង្ហាញបានហើយ។ <ដូច្នេះតាមការយល់របស់យើងគឺថា នេះគឺ> ភ្នំដិន<ដែលយើងអាចមើលឃើញនៅលើផែនទី>។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ខ្ញុំ<មិនបានពិនិត្យមើលនៅក្នុងផែនទីនេះទេ> ក៏ប៉ុន្តែនៅស្រុកខ្មែរនេះ គឺថាមានភ្នំដិនតែមួយទេ។

**ប្រធានអង្គជំនុំ៖**

ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី គិតចាប់ពីនេះតទៅ។

សូមអញ្ជើញសម្រាក!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤១ នាទី ដល់ម៉ោង ១៥:០២ នាទី)*

[១៥:០២:៥៤]

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយ!

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមកែតម្រូវអ្វីដែលខ្ញុំជម្រាបជូនអង្គជំនុំជម្រះ។ <>ខ្ញុំ<បានពិនិត្យមើល>ផែនទី<>៣<ខុសគ្នា កាលពីយប់មិញ។ ខ្ញុំគិតថា> ផែនទីបង្ហាញផ្លូវសម្រាប់ប្រទេសកម្ពុជាទាំងមូល គឺថាគ្រាន់តែមើលឃើញផ្លូវជាតិទេ ប៉ុន្តែមិនមើលឃើញភ្នំដិនទេ ក៏ប៉ុន្តែមានផែនទីបង្ហាញខេត្តតាកែវគឺ E3/10638 – E3/10638 ជាផែនទីបង្ហាញផ្លូវនៅខេត្តតាកែវទាំងមូលតែម្តង ហើយមានផ្លូវមួយភ្ជាប់ទៅភ្នំដិននោះ នៅព្រំដែនតែម្តង។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី នួន ជា បន្តសំណួរលើសាក្សីនេះ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក វិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី មុនពេលឈប់សម្រាកយើងបាននិយាយគ្នាអំពីការដឹកជញ្ជូនឯកសណ្ឋានកងទ័ពវៀតណាម។ តើលោកនឹកឃើញថាលោកបានឃើញជនជាតិវៀតណាមណាម្នាក់ដែរឬទេ នៅទីកន្លែងដែលគេលើកដាក់ឯកសណ្ឋានហ្នឹងចូលទៅក្នុងឡានធំហ្នឹង?

**2-TCW-1036៖**

**ឆ៖** អត់ទេ បង។

**ស៖** តើលោកមានស្តាប់ឮអ្នកណាម្នាក់និយាយភាសាវៀតណាមដែរឬទេ នៅពេលដែលគេលើកឯកសណ្ឋានហ្នឹង យកមកដាក់ចូលក្នុងឡានធំនោះ?

**ឆ៖** ប៉ុន្តែខ្ញុំនៅឆ្ងាយពីគេ ខ្ញុំអត់ដឹង អត់ឮផង នៅឆ្ងាយ ឃើញឡានមក។

[១៥:០៥:១៧]

**ស៖** បើខ្ញុំសាកល្បងព្យាយាមជួយរំឭកដល់ការចងចាំរបស់លោកបន្តិចមើល លោកប្រធាន ខ្ញុំយោងជាថ្មីម្តងទៀតទៅឯកសារប្រតិចារឹកនៃខ្សែភាពយន្តដែល រ៉ូប៊ឺត លឹមគិន គាត់ផលិតជាមួយមនុស្សម្នាក់ទៀតឈ្មោះ ទាត់។ "ខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់លាស់ថា ខ្ញុំនឹងនិយាយពីជនជាតិវៀតណាមម្នាក់ឈ្មោះ ហេស្វ ឬក៏ ហៃស្វ ចំពោះសក្ខីកម្មរបស់គាត់នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។ ទាត់ បដិសេធថា មិនបានស្គាល់គាត់នោះទេ ក៏ប៉ុន្តែនៅពេលដែលគាត់និយាយជាមួយ រ៉ូប៊ឺត លឹមគិន គាត់បានរៀបរាប់ឈ្មោះ ហៃស្វ នេះយ៉ាងលម្អិត។ នេះគឺឯកសារ E3/10665, អង់គ្លេស 01156805 ដល់06, ខ្មែរ 01168451 ដល់ 52។ លោកសាក្សី ហំ ឬក៏ ទាត់ នេះ បាននិយាយយ៉ាងច្រើនអំពីមិត្តភក្តិជិតដិតម្នាក់របស់ តាញឹម ឈ្មោះ ហៃស្វ គាត់បាននិយាយយ៉ាងលម្អិតថា តាហៃស្វ នេះជាអ្នកណា។ ឥឡូវនេះខ្ញុំសូមរៀបរាប់អំពីបុគ្គលនេះ ឲ្យលោកស្តាប់ ថាតើលោកចងចាំពីមនុស្សនេះ ដែរឬក៏អត់។ គាត់គឺជាជនជាតិវៀតណាម ចេះនិយាយភាសាខ្មែរ។ សំបុររបស់គាត់ហ្នឹងគឺថា សជាងអ្នកសម្លាស <បន្តិច> ហើយគាត់ខ្ពស់។ កម្ពស់ប្រហែលជា ១,៧០ម៉ែត្រ កាត់សក់ខ្លី។ តើលោកដែលឮគេនិយាយពីជនជាតិ វៀតណាមម្នាក់ឈ្មោះ ហេស្វ ឬក៏ ហៃស្វ នេះទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយ! សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ខេល លីសាក់៖**

សូមជំទាស់ក្នុងការប្រើប្រាស់នៃផ្នែក ផ្នែកមួយនៃប្រតិចារឹកនេះ។ នេះជាកិច្ចសម្ភាសន៍ជាធម្មតាដែលសម្ភាសដោយលោក លឹមគិន ដោយសារថាគាត់ហើយនិងលោក ថេត សម្បត្តិ អានចម្លើយសារភាពរបស់សាក្សី ហើយលើកយកឯកសារនេះមកសរសេរដដែលៗ។ បើយើងមើលទំព័រត្រង់នេះ គឺមេធាវីការពារក្តី យើងឃើញថា គេយកចម្លើយសារភាពមករៀបរាប់ ព័ត៌មានអំពីបុគ្គលម្នាក់នេះ។ អ៊ីចឹងនៅត្រង់កន្លែងនេះ គឺថាមានបញ្ហាហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

គឺថា មិនមានបញ្ហាអ្វីទេ។ តាមពិតទៅ គឺថា មានការនិយាយពីឈ្មោះ ហៃស្វូ។ ហៃស្វូ ជាជនជាតិវៀតណាម។ គាត់មិនដែលជាប់នៅស-២១ ទេ។ គាត់ជាកម្មាភិបាលកុម្មុយនីស្តវៀតណាមមកពីវៀតណាមដែលមានឋានន្តរសក្តិខ្ពស់។ ប៉ុន្តែ ទាត់ ឬក៏ ហំ នេះ បានផ្តល់ព័ត៌មានដែល ទាត់ ឬក៏ ហំ នេះ គាត់មានព័ត៌មានផ្ទាល់អំពី ហៃស្វូ។ គាត់ថា ហៃស្វូ នេះ រៀបការជាមួយនឹងស្ត្រីម្នាក់ដែលជាជន<ជាតិភាគតិច>គ្រឹក្រ។ ដូច្នេះ មិនមានការជាប់ពាក់ព័ន្ធអ្វីជាមួយនឹងចម្លើយសារភាពនោះទេ។ អ៊ីចឹង ខ្ញុំមិនដឹងសហព្រះរាជអាជ្ញាកំពុងនិយាយពីអ្វីទេ។

[១៥:០៩:០៥]

**លោក ខេល លីសាក់៖**

ឥឡូវ ខ្ញុំសូមបញ្ជាក់ឲ្យបានច្បាស់ <អំពីអ្វីដែលខ្ញុំកំពុងនិយាយនេះ។ នៅពេល>ចាប់<ផ្តើម>សួរអំពីបុគ្គលម្នាក់នេះ។ ខ្ញុំបានឃើញចម្លើយសារភាពរបស់គាត់ <ហើយខ្ញុំគិតថានេះគឺជាចម្លើយសារភាពរបស់> រស់ ញឹម ឬក៏នរណាម្នាក់ <ដែលលោកបានផ្តល់មកឲ្យ>ខ្ញុំ <ហើយ>ក៏ឃើញ ហៃស្វូ។ អ្វីដែលវាមិនច្បាស់នោះគឺថា តើព័ត៌មានណាខ្លះដែលគាត់បានមកពីចម្លើយសារភាព ហើយចម្លើយណាខ្លះដែលគាត់ដឹងដោយខ្លួនឯង ដែលវាអាចជាការសួរដដែលៗ ពាក់ព័ន្ធទៅនឹងលោក លឹមគិន។

**លោក វ៉ិចទ័រ កូប៉េ៖**

ករណីនេះមិនយ៉ាងដូច្នេះទេ។ គាត់បាននិយាយថា គាត់ស្គាល់ ហៃស្វូ នេះដោយផ្ទាល់ ហើយគាត់ថា ហៃស្វូ នេះជាមិត្តភក្តិជិតដិតរបស់ រស់ ញឹម <គាត់បានពណ៌នាពីមនុស្សម្នាក់នេះ>។ បញ្ហាតែមួយគត់ដែលថា <នរណាម្នាក់ត្រូវ>គេលើកឡើងនៅក្នុងចម្លើយសារភាព <មិនមែនមានន័យថា> គេ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មិនអាចសួរបាននេះទេ ដូចជា អឿន, កុយ ធួន, វន វេត។ អ្នកណាក៏ដោយគឺថា គេតែងតែលើកឈ្មោះមនុស្សទាំងនោះយកមកនិយាយនៅក្នុងចម្លើយសារភាព វាមិនមានន័យថា វាមិនឲ្យសួរអំពីបុគ្គលនោះទេ។ ដូច្នេះ ច្បាស់ហើយតាមរយៈប្រតិចារឹកហ្នឹង ហើយតាមរយៈកិច្ចសម្ភាសន៍ជាមួយ លឹមគិន ថា គាត់បានស្គាល់ ហៃសូ នេះដោយផ្ទាល់ ហើយអ្វីដែលខ្ញុំចង់ស្វែងរកឲ្យឃើញនោះ គឺខ្ញុំអានប្រតិចារឹកនៃកិច្ចសម្ភាសន៍នេះ ដើម្បីសួរទៅសាក្សីថា តើគាត់បានឃើញ ហៃសូ ដែរឬអត់ នៅពេលដែលគេប្រគល់ជូននូវឯកសណ្ឋានកងទ័ពនេះ?

[១៥:១០:៥០]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើការប្រើប្រាស់ឯកសារនេះ វាកម្រិត -- លោកប្រើតែត្រឹមប្រតិចារឹក ឬក៏សួរបន្ថែមលើសនេះទៅទៀត?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគ្រាន់តែចង់ដឹងថា គាត់ស្គាល់ ហៃសូ ឬក៏អត់ទេ។ បើគាត់ស្គាល់ ខ្ញុំមិនប្រើប្រតិចារឹកនេះទេ ពីព្រោះថា ពេលនោះគាត់អាចស្គាល់បុគ្គលនោះ ឬក៏ថាៗមានអ្នកណាម្នាក់អាចមានវត្តមាននៅពេលគេប្រគល់ឯកសណ្ឋាននេះ។ អ៊ីចឹងខ្ញុំអានប្រតិចារឹក គ្រាន់តែចង់ដឹងថា គាត់ស្គាល់ ហៃសូ ឬអត់ប៉ុណ្ណោះសិន។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:១១:៥៧]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី លោកអាចកំណត់អត្តសញ្ញាណបុគ្គលនោះតែប៉ុណ្ណោះ លើសពីនេះមិនអាចសួរបានទេ។ សូមអញ្ជើញ!

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកស្គាល់មនុស្សម្នាក់ឈ្មោះ ហៃសូ ដែលជាជនកុម្មុយនីស្តវៀតណាមជាមិត្តភក្តិជិតដិតរបស់ រស់ ញឹម ដូចដែលខ្ញុំបានរៀបរាប់មុននេះ លោកស្គាល់ទេ?

**2-TCW-1036៖**

**ឆ៖** អត់ផង មិនដែលឃើញផង។

01375116



**ស៖** មិនថ្វីទេលោកសាក្សី។ បាទ សំណួរមួយចុងក្រោយមុន សួរទៅដល់ការចាប់ខ្លួន និងការសួរចម្លើយនៅគុកមួយនៅតាកែវ មានភស្តុតាងបង្ហាញថាមនុស្សជាច្រើននៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជាបានចាត់ទុកថា វៀតណាម គឺជាសត្រូវស្នូរពូជ។ ហើយនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនេះ គឺថា យើងបានដឹងហើយមានសង្គ្រាមបន្តឡើងពីឆ្នាំ៧៥ ទៅដល់៧៩ រវាងកម្ពុជានឹងវៀតណាម តើលោកមានគិតថា វាជារឿងមួយចម្លែក ឬក៏មិនធម្មតាដែរឬទេ សម្រាប់តាញ៉ឹម ហើយនិងអ្នកដទៃទៀតធ្វើដំណើរទៅប្រមូលឯកសណ្ឋានកងទ័ពវៀតណាម មកពីវៀតណាមនោះ នៅពេលដែលកម្ពុជា និងវៀតណាមកំពុងតែមានជម្លោះជាមួយនឹងគ្នា?

[១៥:១៣:៥៤]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ! សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

ដំបូងខ្ញុំយល់ឃើញថា<គាត់កំពុងតែនិយាយខុស។> សាក្សីគាត់បាននិយាយហើយថា មិនមានការប្រយុទ្ធគ្នាទេ នៅពេលនោះ។ ទី២ គាត់សួរ ដើម្បីចង់បានសេចក្តីសន្និដ្ឋានជាគំនិតយោបល់ពីសាក្សីទៅវិញ មិនមែនសួរឈ្លេចរកអង្គហេតុទេ។ អ៊ីចឹង សូមសួរឲ្យបានច្បាស់លាស់។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមរៀបសំណួរឡើងវិញ។

**លោក វ៉ិចទ័រ កូប៉េ៖**

យើងដឹងហើយអង្គជំនុំជម្រះបញ្ជាក់ថា សង្គ្រាមកំពុងតែបន្តមាននាពេលនោះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើលោកដែលគិតថា វាមិនមែនជារឿងមួយធម្មតានោះទេ ក្នុងការធ្វើដំណើរទៅទទួលយកឯកសណ្ឋានកងទ័ពវៀតណាម គឺយកពីប្រទេសមួយដែលកម្ពុជាប្រជាធិបតេយ្យ គឺថាមានសង្គ្រាមជាមួយអ៊ីចឹង ហើយទៅជាទទួលយកឯកសណ្ឋានហ្នឹងមក។ លោកដែលគិតអ៊ីចឹងទេ?

[១៥:១៤:៥៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

នេះគឺជាសំណួរនាំមុខសាក្សីហើយ គឺថាគាត់ទៅជាបង្ហាញ -- តម្រុយទៅឲ្យសាក្សីគឺជាការនាំមុខហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំយល់ឃើញថាសំណួរនេះជាសំណួរមួយសមស្របហើយ។ លោកសាក្សីតើលោក<មិន>ភ្ញាក់ផ្អើល<ទេឬនូវអ្វីដែលកើតឡើងនោះ?>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

នេះគឺជា១គំនិតយោបល់ហើយ។ ឥឡូវលោកមេធាវីសួរបៀបនេះទៅ។ <គឺសួរថា "តើលោកចាត់ទុកថានេះជារឿងមិនធម្មតាទេឬ?">

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើលោកគិតថា វាមិនធម្មតាទាល់តែសោះឬក្នុងការដែលលោកធ្វើដំណើរនេះ ទៅទទួលយកឯកសណ្ឋានកងទ័ពពីវៀតណាមមក?

**2-TCW-1036៖**

**ឆ៖** ខ្ញុំអត់ដឹងដែរ អាហ្នឹងគេ គេយកមកឲ្យខ្ញុំដែរ ទៅដល់នោះគេអត់ដឹង គេម៉េច១អត់ដឹងទេ ខ្ញុំតាមគេទៅ។

**ស៖** បើខ្ញុំសាកល្បងសួរពីតាមរបៀបផ្សេង។ លោកសាក្សីតើត្រឹមត្រូវដែរឬទេ គឺថាក្រោយតាញឹម <ត្រូវបាន>ចាប់ខ្លួនហើយ លោកក៏ត្រូវបានចាប់ខ្លួន ហើយគេបញ្ជូនទៅបាត់ដំបងដើម្បីសួរចម្លើយមុនពេលគេបញ្ជូនលោកទៅ<គុកកកោះ>មែនទេ?

**ឆ៖** បាទ កោះ១១ មោង។

[១៥:១៧:០៦]

**ស៖** នៅឯគុក<កកោះ> តើអ្នកសួរចម្លើយគេសួរលោកអំពីអ្វី?

**ឆ៖** គេសួរហ្នឹងមិនដឹងសួរថា ខ្ញុំទៅបម្រើវាប៉ុន្មានឆ្នាំតាហ្នឹង? ខ្ញុំថាខ្ញុំមិនដឹងទេ ខ្ញុំអត់ដឹងអីផងការពារទៅ អត់ដឹងរឿងគាត់ចេះចុះ អត់ដឹង។

**ស៖** លោកមានចាំសំណួរដទៃទៀតទេ គេសួរលោកថាដូចម្ដេចដែរ? លោកសាក្សីលោកនៅចាំទេថាអ្នកសួរចម្លើយនោះ គេសួរលោកសំណួរអ្វីខ្លះទៀត ក្រៅពីលោកឆ្លើយអម្បាញ់មិញនេះ?

**ឆ៖** គេសួរថា ខ្សែយួនបានចាប់ ហើយវ៉ៃខ្ញុំឆក់សន្លប់ពីរដង បីដង។ មួយថ្ងៃ ពីរដង បីដង បាន វាយកទៅដាក់ខ្ញុំនៅកកោះវិញ។

**ស៖** ខ្ញុំសូមអាននូវចម្លើយរបស់លោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេតគឺឯកសារ E3/9581 សំណួរចម្លើយ៤១។ បាទ ខ្ញុំសូមចាប់ផ្តើមជាមួយនឹងសំណួរ-ចម្លើយ៤0សិន៖ “ខ្ញុំក៏ត្រូវបានគេសួរចម្លើយពីរដងក្នុងមួយថ្ងៃ។ សួរ៖ តើគេសួរចម្លើយលោកអ្វីខ្លះ? ឆ្លើយ៖ គេមានអ្នកសួរចម្លើយពីរនាក់ ខ្ញុំមិនដែលស្គាល់ទេ គេសួរខ្ញុំដែលៗ។ តើទៅយួនប៉ុន្មានដង? ហើយខ្ញុំឆ្លើយថាខ្ញុំមិនដែលបានទៅទេ។ រួច គេថា អ្អែងជានីរសាររបស់ តាញឹម អញ់មិនជឿអ្អែងទេ អ្អែងប្រាកដជាធ្លាប់ទៅយួន។” បញ្ចប់ការដកស្រង់។ ហើយបន្ទាប់មក គេក៏គេប្រើដំបងអគ្គិសនីនេះឆក់រហូតដល់ខ្ញុំសន្លប់។ លោកសាក្សីលោកនៅនឹកឃើញទេថាអ្នកសួរចម្លើយបានសួរលោកដដែលៗ អំពីការធ្វើដំណើររបស់លោកទៅវៀតណាមដើម្បីទៅដឹកជញ្ជូនឯកសណ្ឋានកងទ័ព?

[១៥:២០:១៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

មេធាវីកំពុងតែសួរឲ្យសាក្សីយល់ច្រឡំ ដកស្រង់ខុស។ <គេបាន>សួរ<គាត់អំពីការធ្វើដំណើរ>ទៅ<>វៀតណាម។ <នៅទីនេះមិនមាននិយាយអ្វីទាំងអស់អំពីឯកសណ្ឋានយោធា ដូច្នេះគាត់មិនគួរបញ្ចូលចំណុចនេះទៅក្នុងសំណួររបស់គាត់>ទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** មិនថ្វីទេ ខ្ញុំសូមរៀបចំសំណួរឡើងវិញ។ តើគេសួរសំណួរនេះដដែលៗប៉ុន្មានដង ពីព្រោះគេសួរថាតើអ្អែងមានទៅវៀតណាម<ប៉ុន្មានដង?>។ អ៊ីចឹងគេសួរញឹកញាប់យ៉ាងណា ប៉ុនណាដែរ?

**2-TCW-1036៖**

**ឆ៖** ខ្ញុំមិនដែលទៅទេវៀតណាម ខ្ញុំនៅតែក្រៅហ្នឹង។ មិនដែលឃើញមុខយួនផង ដល់មកសួរអ៊ីចឹងហ្នឹង មិនដែលឃើញ។

**ស៖** តើគេចង់សួរយ៉ាងម៉េច ហើយគេមានពន្យល់ដល់លោកដែរឬទេ គេចង់បានអ្វីនៅពេលគេសួរ តើអ្អែងទៅយួនប៉ុន្មានដង?

01375119



**ឆ៖** គេអត់សួរផង គេសួរតែម្ដង វាគិតៗតែវៃ វៃឆក់ៗ ខ្ញុំលែងដឹងខ្លួនហើយ យកដាក់កកោះនោះ។

**ស៖** នៅក្នុងចម្លើយដែលខ្ញុំទើបអានឲ្យលោកស្ដាប់ <លោក>ថាអ្នកស៊ើបអង្កេតបាន -- អ្នកសួរចម្លើយនេះ គេសួរថាអ្នកឯងគឺជានីរសាររបស់ តាញ៉ឹម ហើយលោកពិតជាធ្លាប់បានទៅវៀតណាម។ តើគេមានអ្នកសួរចម្លើយលោកហ្នឹងមានប្រាប់លោកថាធ្វើម៉េចបានជាគេដឹងថាលោកទៅវៀតណាមជាមួយ តាញ៉ឹម? ហើយហេតុអ្វីបានជាគេដឹងថាលោកហ្នឹង គឺជានីរសាររបស់ តាញ៉ឹម?

**ឆ៖** ខ្ញុំអត់ដឹងផងអាហ្នឹង បែប ខ្ញុំមិនដែលថាទេ។ ខ្ញុំក្រោយឯណោះ មានអាគេ*(ឮមិនច្បាស់)*ជាប់ៗទៅជាប់។

**ស៖** តើគេមានសួរលោកអំពីឯកសណ្ឋានវៀតណាមពណ៌ខៀវហ្នឹងទេ គេមានសួរពីចំណុចនេះទេ?

**ឆ៖** អត់ហ្នឹង។

**ស៖** ដូច្នេះ សំណួរដែលគេសួរ គេសួរតែថាហេតុអ្វីបានជាអ្អែងទៅវៀតណាមជាមួយ តាញ៉ឹម គេសួរតែសំណួរហ្នឹងទេឬ?

**ឆ៖** អត់សួរផងអាហ្នឹង។ សួរតែម្ដងៗហ្នឹង។

**ស៖** បើខ្ញុំយល់យ៉ាងដូច្នេះត្រឹមត្រូវទេថា គេសួរចម្លើយលោកពីរថ្ងៃ ហើយលោកត្រូវបានគេវាយដំមកឆក់នឹងខ្សែភ្លើង។ អ៊ីចឹងសួរលោកដល់ទៅពីរថ្ងៃ ធ្វើទារុណកម្មលោកផង ឆក់នឹងខ្សែភ្លើងផង ហើយអ្នកសួរចម្លើយសួរលោកតែមួយសំណួរហ្នឹងទេអី? បាទ សូមលោកព្យាយាមឆ្លើយទៅនឹងសំណួរខ្ញុំម្ដងទៀតមើល។

**ឆ៖** បាទ តែមួយសំណួរហ្នឹង ថាតែខ្ញុំខាងយួន ខ្ញុំមិនដឹងទេ មិនដឹងវាយ៉ាងម៉េចខ្ញុំអត់ដឹង ខ្ញុំទៅជាប់នឹងគាត់ មិនបានទៅឯណា ខ្ញុំនៅតែការពារឯផ្ទះគាត់ឯណោះ ខ្ញុំ ហៅទៅមិនទៅផង។

**ស៖** ប៉ុន្តែលោកទើបតែឆ្លើយមុនថាលោកទៅជាមួយ តាញ៉ឹម ទៅដឹកទៅជញ្ជូនយកឯកសណ្ឋានកងទ័ពវៀតណាមហ្នឹង គឺទៅជាមួយ តាញ៉ឹម ពិតអ៊ីចឹងទេ?

[១៥:២៥:០៣]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ! សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

មេធាវីការពារក្តីមិនគួរដកស្រង់ខុសទេ។ គាត់ថាគាត់ទៅភ្នំ<ពេញ> មិនមានការបញ្ជាក់ថាគាត់ទៅវៀតណាមត្រង់ចំណុចណាមួយនោះទេ<>។

**លោក វ៉ិចទ័រ កូប៉េ៖**

គឺគាត់ទៅព្រំដែនវៀតណាម ទៅដឹកជញ្ជូនឯកសណ្ឋានកងទ័ពពីភ្នំដិនមក។ ប៉ុន្តែលោកប្រធាន ខ្ញុំនៅសល់តែ១៥នាទី ឬ២០នាទី ទៀតទេ អ៊ីចឹង ខ្ញុំបន្តទៅប្រធានបទមួយទៀត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី គឺជាកងការពាររបស់ តាញឹម។ លោកជាអ្នកបើកបរជូនគាត់។ តើលោកធ្លាប់ដែលឮ តាញឹម និយាយនៅក្នុងឡាន ឬនៅខាងក្រៅនៅក្នុងវគ្គនយោបាយណាមួយដែរទេ លោកដែលឮ តាញឹម និយាយទេ?

2-TCW-1036៖

**ឆ៖** ប៉ុនខ្ញុំមិនដែលទៅជាប់គាត់ប៉ុន្មានទេបង គេអ្នកទី១ បានគេជាប់។ តែខ្ញុំផ្លូវឆ្ងាយ ខ្ញុំជិះឡានផ្សេងពីគាត់។

**ស៖** ខ្ញុំយល់ហើយ ក៏ប៉ុន្តែតើលោកធ្លាប់ឮសំឡេងគាត់ ធ្លាប់ឮគាត់និយាយ ឬក៏ធ្លាប់ឮសមមិត្តលោកហ្នឹង និយាយអំពីអ្វីដែល តាញឹម ធ្លាប់និយាយនៅក្នុងវគ្គនយោបាយ ឬក៏វគ្គរៀនសូត្រណាមួយដែរទេ?

**ឆ៖** អត់បង គាត់មិនដែលប្រាប់អីផង មិនដែលឮគាត់និយាយផង។

**ស៖** តើលោកធ្លាប់ឮ តាញឹម និយាយថាគាត់ព្យាយាមចាប់ផ្តើមធ្វើការបះបោរ ងើបតស៊ូប្រឆាំងជាមួយនឹង ប៉ុល ពត ដោយគាត់រួមគ្នាជាមួយនឹង សោ ភឹម ប្រឆាំងជាមួយនឹង ប៉ុល ពត ដែរឬទេ?

**ឆ៖** អត់ អត់ដែលឮផង។

[១៥:២៧:៣៩]

**ស៖** លោកសាក្សី បុគ្គលដដែល គឺឈ្មោះ ហំ ដែលលើកឡើងខាងដើម ឬក៏ ទាត់ នេះ ដែលខ្ញុំលើកឡើងខាងដើមនេះ។ គឺបាននិយាយអំពីការលាក់ទុកអាវុធសម្រាប់ធ្វើការបះបោរ។ ឥឡូវ ខ្ញុំយកចម្លើយរបស់គាត់ ដែលគាត់ឆ្លើយទៅនឹងអ្នកថតភាពយន្តឈ្មោះ លឹមគិន។ នេះ គឺឯកសារ E3/10665, ERN ជាភាសាអង់គ្លេស 01156801, ខ្មែរ 01168442។ ហើយខាងក្រោមបន្តិច ហំ ឬក៏ ទាត់ បាន

ឆ្លើយជាមួយនឹងអ្នកថតខ្សែភាពយន្តនេះ ថា រស់ ញឹម បានប្រាប់គាត់ថា គាត់ហ្នឹង គឺថា -- រស់ ញឹម គាត់លែងនៅជាមួយបក្សប៉ុល ពត ទៀតហើយ គឺគាត់ប្រមូលកម្លាំងដើម្បីប្រឆាំងជាមួយនឹងប៉ុល ពត គឺគាត់រួមដៃគ្នាជាមួយនឹង សោ ភឹម។ ហើយ រស់ ញឹម ហ្នឹង ចាប់ផ្តើមបង្កើតបក្សផ្ទាល់ខ្លួនរបស់គាត់នៅពេលនោះ ហើយ ហំ ហ្នឹង គឺថាបានអមដំណើរ រស់ ញឹម ទៅចូលរួមការកូនស្រីរបស់ សោ ភឹម នៅក្នុងខែសីហា ១៩៧៥។ តើលោកធ្លាប់ឮ តាញឹម រួមដៃគ្នាជាមួយនឹង សោ ភឹម ងើបបះបោរប្រឆាំងនឹង ប៉ុល ពត ដោយបង្កើតបក្សផ្ទាល់ខ្លួនដែរឬទេ?

**ឆ៖** អត់ឮគាត់និយាយប្រាប់ផងបង។

[១៥:២៩:៤៧]

**ស៖** ខ្ញុំសាកល្បងសួរតាមរបៀបផ្សេង បាទ ដោយងាកចេញអំពីការសួរអំពី តាញឹម។ ឥឡូវ ខ្ញុំសូមយកចម្លើយរបស់កម្មាភិបាលថ្នាក់ទាបមួយឆ្លើយជូនអ្នកស៊ើបអង្កេតនៃសហចៅក្រមស៊ើប។ នេះគឺឯកសារ E3/9579 សំណួរចម្លើយលេខ១៣។ គាត់បាននិយាយអំពីការចោទប្រកាន់ថា ខាងផ្នែកពាយ័ព្យហ្នឹង គឺជាប់ពាក់ព័ន្ធជាមួយខ្មែរវៀតមិញ និងប្រធានគណៈកម្មាធិការភូមិភាគបូព៌ាគឺ សោ ភឹម។ នេះអ្វីដែលគាត់បានឆ្លើយ សូមដកស្រង់ "ភូមិភាគទាំងពីរនេះ គឺភូមិភាគបូព៌ា និងភូមិភាគពាយ័ព្យបានងើបប្រឆាំងបះបោរជាមួយ ប៉ុល ពត។ តាមការកត់សម្គាល់របស់ខ្ញុំ ខ្មែរក្រហម មានបីឬក៏បួនក្រុមឯណោះ។ ក្រុមទី១ ក្រុមវៀតមិញ, ក្រុមទី២ គឺក្រុមជាតិនិយម, ក្រុមទី៣ គឺក្រុមខ្មែរក្រហមសីហនុ និងក្រុមទី៤ គឺក្រុមខ្មែរក្រហមមកពីចិន រួមមាន ប៉ុល ពត។" ដូចដែលខ្ញុំបានបញ្ជាក់ហើយ ថានេះគឺជាចម្លើយរបស់កម្មាភិបាលជាន់ទាប ដែលទទួលខាងផ្នែកកងដឹកជញ្ជូន។ តើខ្លួនលោកផ្ទាល់នេះ លោកដែលបានកត់សម្គាល់ ឬក៏បានឮពីរឿងនេះដែរទេ?

**ឆ៖** អត់ផង។

**ស៖** ខ្ញុំបាននិយាយវែងឆ្ងាយមកហើយអំពី លឹមគិន នេះជាអ្នកថតខ្សែភាពយន្តជនជាតិអង់គ្លេស សហការីជាតិរបស់គាត់គឺឈ្មោះ ថេត សម្បត្តិ។ ហើយថ្មីៗនេះ កិច្ចសម្ភាសន៍ដែល លឹមគិន បានឆ្លើយទៅជាមួយនឹងអ្នកកាសែត ឈ្មោះ ចច វ៉ាយ មកពីកាសែត ខេមបូឌាដេលី គាត់បាននិយាយអំពីសង្គ្រាមស៊ីវិលស្ងាត់ៗ បន្តមាន។ ហើយលោកជាកងការពាររបស់ តាញឹម តើលោកមានដែលកត់សម្គាល់ថាមានសង្គ្រាមស៊ីវិលស្ងាត់ៗកើតមានឡើងទេនៅពេលនោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយ។ សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

យើងមិនមានឯកសារយោង E3 មេធាវីមិនបានបង្ហាញទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

នេះគឺជាអត្ថបទខេមបូឌាដេលី ដែលចេញផ្សាយថ្មីៗគឺឯកសារ <E416.1.2 ហើយ ERN ជាភាសាអង់គ្លេសគឺ 01298489។>

**អ្នកបកប្រែ៖**

សូមអធ្យាស្រ័យលោកប្រធាន តាមអត់ទាន់ ERN ញាប់ពេក។

**ប្រធានអង្គជំនុំ៖**

សូមៗលោកមេធាវីម្ដងទៀត លេខ ERN អ្នកបកប្រែស្ដាប់អត់ទាន់ទេ។

[១៥:៣៣:២០]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ERN អង់គ្លេស 01298489 គឺ E3/416.1.2។ ដូច្នេះ លោកសាក្សី<តើមានសង្គ្រាមសម្ងាត់>--

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើឯកសារនេះ បានទទួលយកហើយឬនៅ?

**លោក វ៉ិចទ័រ កូប៉េ៖**

មិនទាន់បានទទួលនៅឡើយទេ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អ៊ីចឹងលោកមិនអាចប្រើប្រាស់បានទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ម៉េច មិនអាចប្រើបាន?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ដោយសារថា អត់ទាន់បានទទួលយក។

**លោក វ៉ិចទ័រ កូប៉េ៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

<យ៉ាងណាក៏ដោយ ខ្ញុំចង់ប្រើវា។ វាជា -->

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

យោងទៅតាមវិធានផ្ទៃក្នុងគឺថា លោកមិនអាចសួរទេ បើឯកសារនោះ មិនទាន់ទទួលយកដោយអង្គជំនុំជម្រះនោះ។

**សួរដោយលោក វិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំសួរតាមរបៀបនេះ លោកសាក្សី តើលោកមានបានកត់សម្គាល់ថា មានសង្គ្រាមស៊ីវិលសម្ងាត់រវាងភូមិភាគពាយ័ព្យនិងបូព៌ា ប្រឆាំងគ្នាជាមួយនឹងខាងក្រុម ប៉ុល ពត ហ្នឹងដែរទេ?

**ឆ៖** អត់ផងបង។

**ស៖** លោកមិនដឹង ឬក៏លោកមិនធ្លាប់ដែលបានឮ? តើពាក្យថា "អត់" មួយម៉ាត់ហ្នឹងលោកចង់និយាយថាម៉េច?

**ឆ៖** ថាមិនដែលឮគាត់និយាយផង។

[១៥:៣៥:០០]

**ស៖** ខ្ញុំយល់ហើយចំណុចនេះ ក៏ប៉ុន្តែខ្ញុំចង់សួរលោកថា នៅពេលនោះ លោកមានបានកត់សម្គាល់ថា នៅភូមិភាគពាយ័ព្យនោះ មានទំនាស់ផ្ទៃក្នុងកើតឡើងដែរឬទេ?

**ឆ៖** អត់ បើខ្ញុំមិនដែលឮថាផ្ទុះអីផង ឈ្លោះគ្នាអីផង ដឹងគាត់ម៉េចៗ ខ្ញុំមិនដឹងទេ។

**ស៖** ខ្ញុំព្យាយាមសាកល្បងសួរតាមរបៀបផ្សេង។ លោកសាក្សី លោកដែលបានកត់សម្គាល់ថាមានការលាក់ទុក អង្ករ ត្រី ប្រេង សាំង ឯកសណ្ឋានជាដើម។ល។ ដើម្បីអាចឲ្យប្រើប្រាស់សម្រាប់ការបះបោរប្រឆាំងនឹង ប៉ុល ពត លោកដឹងទេ?

**ឆ៖** អត់ផង។

**ស៖** មានកម្មាភិបាលមកពីភូមិភាគពាយ័ព្យ និយាយថា រស់ ញឹម បានបញ្ជាទៅកូនចៅរបស់គាត់ ក្នុងការចាប់ផ្តើមសង្គ្រាមចិត្តសាស្ត្រ ដោយធ្វើការចាប់ខ្លួនតាមអំពើចិត្ត ចាប់ខ្លួនតាមផ្លូវច្បាប់ដើម្បីធ្វើឲ្យមានការបំភិតបំភ័យនៅភូមភាគពាយ័ព្យហ្នឹង លោកដែលកត់សម្គាល់ឃើញ ដឹងអំពីរឿងនេះទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ!

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

[១៥:៣៦:៤០]

**លោក ឌេល លីសាក់៖**

បើមេធាវីការពារក្ដីសួរតទល់ជាមួយនឹងសាក្សីរូបនេះ គឺត្រូវបង្ហាញឯកសារមក ដើម្បីចង់ដឹងថា តើរាល់អ្វីដែលយកមកសួរមានប្រភពមកពីណា?

**លោក វ៉ិចទ័រ កូប៉េះ៖**

ពិតហើយ នេះគឺជាកិច្ចសម្ភាសន៍មួយផ្សេងទៀត ដែលអ្នកថតខ្សែភាពយន្តនេះ បានសម្ភាសជាមួយនឹងកម្មាភិបាលភូមិភាគពាយ័ព្យ គឺ F2/43/3/6.2 ERN អង់គ្លេស 01151685។ សាក្សីរូបនេះគឺជា -- សាក្សីទី៣ ដែលគាត់និយាយអំពីការដឹកជញ្ជូន ត្រី សាច់ ប្រេង <អង្រឹង> អាវុធ ឧបករណ៍របស់របរ ផ្សេងៗទៀត យកទៅលាក់ទុក ដើម្បីធ្វើការបះបោរ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

[១៥:៣៧:៤៣]

**លោក ឌេល លីសាក់៖**

ខ្ញុំជឿជាក់ថា នេះគឺជាប្រតិចារឹកមួយដែលតុលាការបានច្រានចោលហើយនៅពេលសម្រេចទៅតាមសំណើសុំរបស់ នួន ជា ដែលអនុលោមទៅតាមវិធាន៨៧(៤)។ អ៊ីចឹងយើងឃើញហើយថា មេធាវីការពារក្ដីកំពុងតែអានពីឯកសារមួយដែលអង្គជំនុំជម្រះបានច្រានចោលរួចទៅហើយ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រេចជំទាស់នឹងសំណួរនេះ។ សូមលោកបន្តសំណួរផ្សេងទៀត។

**លោក វ៉ិចទ័រ កូប៉េះ៖**

ជាការពិតហើយ ខ្ញុំអានចេញពីឯកសារដែលអង្គជំនុំជម្រះហាមឃាត់ ច្រានចោលហើយ។ បាទ ខ្ញុំសូមធ្វើការកត់សម្គាល់ គឺថាអង្គជំនុំជម្រះ គឺថាមិនចង់ស្ដាប់ចំណុចដែលសំខាន់ទេ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ ការលើកឡើងរបស់មេធាវីនេះ គឺហួសហេតុពេកហើយ។

**លោក វ៉ិចទ័រ កូប៉េះ៖**

មិនហួសហេតុអីទេ លោកចៅក្រម ឡាវែន៍ គឺថា លោកអត់ចង់ស្ដាប់ព័ត៌មានសំខាន់ៗដែល

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មេធាវីចង់សួរទេ។ សាធារណជនស្ដាប់ហ្នឹង គឺថាដឹងអំពីរឿងនេះហើយ។

**ប្រធានអង្គជំនុំ៖**

សូមលោកសួរសំណួរទៅសាក្សី!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណ ចំពោះការកាត់ផ្ដាច់មេក្រូរបស់ខ្ញុំ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើលោកធ្លាប់ឮ -- លោកធ្លាប់បានដឹងថា ចាន់ ចក្រី មានវត្តមាន -- វន វ៉េត និង ចាន់ ចក្រី មានវត្តមាននៅពេលដែល តាញឹម ប្រជុំ ហើយឡើងនិយាយនោះទេ?

**2-TCW-1036៖**

**ឆ៖** អត់ផងបង។

[១៥:៣៩:៤៨]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន សម្រាប់ប្រតិចារឹក គឺថា<ការដែល> វន វ៉េត <មិន>មានវត្តមាននៅក្នុងអង្គប្រជុំមួយដែល តាញឹម និយាយអំពីការបះបោរ<នោះ ក៏>យើងអាចរកឃើញដែរនៅក្នុងឯកសារសម្ភាស លឹមគិន ដែរ។ ប៉ុន្តែមិនទាន់ទទួលបានយកមកធ្វើជាឯកសារទេ។ ខ្ញុំអស់សំណួរហើយ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា មានសំណួរលើសាក្សីនេះ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** នេះគឺជាឧទាហរណ៍មួយដ៏ល្អដែល លឹមគិន បានយកចម្លើយសារភាពពីស-២១ យកមកប្រើប្រាស់ក្នុងកិច្ចសម្ភាសន៍របស់គាត់។ លោកសាក្សី បាទ ខ្ញុំសួរសំណួរមួយចំនួនក្នុងនាមឲ្យការិយាល័យសហព្រះរាជអាជ្ញា ខ្ញុំសូមសួរសំណួរអំពីជីវប្រវត្តិរបស់លោកមួយចំនួនសិន។ លោកថាលោកចូលរួមបដិវត្តន៍នៅក្នុងឆ្នាំ៧២ នៅពេលនោះតើលោកមានអាយុប៉ុន្មានឆ្នាំ?

01375126



2-TCW-1036៖

ឆ៖ ប្រហែលប្រាំបី ប្រាំបួនហ្នឹង ប្រាំបីហើយ។ ប្រហែល ប្រាំពីរដណ្ដប់ ប្រាំបីដណ្ដប់ហ្នឹង។

ស៖ យោងទៅតាមកិច្ចសម្ភាសន៍របស់លោក លោកកើតនៅថ្ងៃទី១០ ខែវិច្ឆិកា ១៩៦០ មានន័យថាលោកអាយុ១២ឆ្នាំហើយនៅពេលនោះ។ តើឆ្នាំ១៩៦០នេះ វាពិតជាឆ្នាំកំណើតលោកពិតប្រាកដទេ?

ឆ៖ ខ្ញុំមិនសូវដឹងដែរហ្នឹងឆ្នាំខ្ញុំ។

[១៥:៤២:១៧]

ស៖ មិនមែនតែលោកទេដែលមានបញ្ហាជាមួយនឹងថ្ងៃខែឆ្នាំកំណើតនេះ នៅប្រទេសកម្ពុជានោះ។ បាទ ខ្ញុំបន្តទៅមុខទៀតចុះ។ នៅក្នុងចម្លើយលេខ២ ដែលលោកឆ្លើយជាមួយនឹងកិច្ចសម្ភាសន៍របស់សហចៅក្រមស៊ើបអង្កេតគឺ E3/9581 លោកបានឆ្លើយថា -- បាទខ្ញុំសូមអានចម្លើយឲ្យលោកស្ដាប់៖ "ខ្ញុំចូលរួមជាមួយនឹងបដិវត្តន៍ខ្មែរក្រហមនៅឆ្នាំ៧២ ខ្ញុំចូលរួមចលនាបដិវត្តន៍នេះដោយស្ម័គ្រចិត្តតែម្ដង។ ដំបូងគេឲ្យខ្ញុំធ្វើការនៅខាងផ្នែកសិល្បៈ ហើយក្រោយមកគេចាត់តាំងឲ្យខ្ញុំធ្វើជានីរសាររបស់ តាញឹម ហើយគាត់ចាត់តាំងឲ្យខ្ញុំដើរចែកសំបុត្រទៅឲ្យកងទ័ពនៅភ្នំធិបតី <គាស់>ក្រឡ និងគោក<ក្រោម>។ ខ្ញុំធ្វើនីរសាររបស់គាត់បានតែពីរខែទេ ដោយសារតែការងារវាយ៉ាប់ពេក ទើបខ្ញុំស្ម័គ្រចិត្តចូលធ្វើជាយោធាក្នុងឆ្នាំ១៩៧៤។" ខ្ញុំសូមសួរសំណួរពាក់ព័ន្ធទៅនឹងចម្លើយរបស់លោកនេះ នៅក្នុងអំឡុងពេលពីរខែ គឺ<ក្នុងអំឡុងពេល>ឆ្នាំ<៧៣ ឬ>ឆ្នាំ៧៤ ដែលលោកធ្វើជានីរសារឲ្យ តាញឹម តើនៅពេលហ្នឹង តាញឹម ស្នាក់នៅកន្លែងណា ឈរជើងនៅកន្លែងណាពេលដែលលោកធ្វើជានីរសារឲ្យគាត់ពីរខែហ្នឹង?

ឆ៖ គាត់ឈរកន្លែងគេហៅស្រុកតាសាញ់យើងហ្នឹង។ ប៉ុនកន្លែងគាត់មិនទៀង គ្រប់តែកន្លែង។

ស៖ ខ្ញុំសួរលោកតាមរបៀបនេះវិញ លោកបានបញ្ជាក់ទីកន្លែងដែលលោកដើរចែកសំបុត្រដែល តាញឹម ចាត់តាំងឲ្យៗលោកដើរចែកហ្នឹង។ អ៊ីចឹងក្នុងរយៈពេលពីរខែនេះ លោកទទួលសំបុត្រពី តាញឹម ហ្នឹងនៅកន្លែងណា? <រយៈពេលពីរខែហ្នឹង លោកធ្វើការនៅឯណា?>

ឆ៖ នៅស្ទឹងតូច ភូមិស្ទឹងតូច ព្រៃ ត្បូងវាយចាប។

ស៖ ចុះកន្លែងហ្នឹងលោកដឹងទេ ស្ថិតនៅក្នុងស្រុកអ្វីដែរ?

[១៥:៤៥:០០]

ឆ៖ អាហ្នឹងព្រៃបង ដូចថាប្រជាជនគេរំដោះគេនៅហ្នឹង ជើងព្រៃភ្នំ។

ស៖ នៅក្នុងចម្លើយលេខ២ដដែលនេះ លោកបានឆ្លើយថា ក្រោយពីលោកធ្វើជានីរសារអស់

រយៈពេលពីរខែ លោកក៏ស្ម័គ្រចិត្តចូលធ្វើជាយោធាក្នុងឆ្នាំ៧៤។ សូមដកស្រង់លោកគឺថា “គេបានឲ្យខ្ញុំធ្វើជាអ្នកស៊ើបការណ៍ពីបន្ទាយទាហាន លន់ នល់” បញ្ចប់ការដកស្រង់។ តើបន្ទាយទាហាន លន់ នល់ហ្នឹងនៅកន្លែងណាដែរនៅពេលដែលគេឲ្យលោកធ្វើជាអ្នកស៊ើបការណ៍ពីបន្ទាយទាហាន លន់នល់ នោះ?

**ឆ៖** បន្ទាយយើង បន្ទាយរូង បាណន់ គាស់ក្រឡ បីមុខសញ្ញាបង។

**ស៖** ក្នុងអំឡុងពេលដែលលោកធ្វើជាយោធានោះ តើលោកស្ថិតនៅក្នុងកងណាដែរ? តើលោកគឺស្ថិតនៅក្នុងជាកងទ័ពចំណុះឲ្យភូមិភាគពាយ័ព្យ ឬក៏យ៉ាងណា?

**ឆ៖** គេហៅពួកតំបន់នោះៗ សុទ្ធតំបន់។ ប៉ុនចំណុះដូចមិនចំណុះទេបង យើងត្រូវតែគ្នា វៃជាមួយតែគ្នាទាំងអស់ហ្នឹង។

**ស៖** ដូច្នេះ លោកគឺជាកងទ័ពតំបន់។ តើលោកជាកងទ័ពតំបន់លេខប៉ុន្មាន?

**ឆ៖** អត់ដឹងលេខផងបង។

**ស៖** នៅពេលនោះ តើអ្នកណាជាមេបញ្ជាការរបស់លោក? តើអ្នកណាជាអ្នកចាត់តាំងឲ្យលោកទៅស៊ើបការណ៍ពីបន្ទាយទាហាន លន់ នល់ ហ្នឹង?

**ឆ៖** ឈ្មោះ តាឆែម ឈ្មោះ ឆែម។

[១៥:៤៧:៥២]

**ស៖** ឥឡូវខ្ញុំចូលទៅសួរលោកអំពីអំឡុងពេលចន្លោះពីឆ្នាំ១៧ មេសា ៧៥ រហូតដល់ពេលតាញ៉ែម ឲ្យលោកធ្វើជាកងការពាររបស់គាត់។ នៅក្នុងចម្លើយលេខ៣ នៃកិច្ចសម្ភាសន៍ដដែល គឺ E3/9581 គឺថាលោករស់នៅកង្កួត ចន្លោះពី<១៧ មេសា> ឆ្នាំ៧៥ ដល់៧៦។ តើលោកអាចបញ្ជាក់ជូនតុលាការបានទេ ចន្លោះពេលហ្នឹង លោកធ្វើអ្វី? ហើយលោកស្ថិតនៅក្នុងកងណាដែរ?

**ឆ៖** មានកងតំបន់ដែរ ប៉ុនៗកាលមួយហ៊ឹកហ្នឹងវាបុកដល់គ្នា បានរំដោះហើយ។

**ស៖** ដូច្នេះ លោកបន្តធ្វើជាកងទ័ពតំបន់ដដែល។ ក្នុងនាមលោកជាកងទ័ពតំបន់ លោកមានភារកិច្ចធ្វើអ្វីដែរចន្លោះពីថ្ងៃ១៧ មេសា ៧៥ រហូតដល់ពេលគេចាត់តាំងឲ្យលោកធ្វើជាកងការពាររបស់តាញ៉ែម ក្នុងឆ្នាំ១៩៧៦?

**ឆ៖** ធ្វើកូនចៅគេហ្នឹង។

**ស៖** តើលោកនៅចាំទេថានៅឆ្នាំ១៩៧៦ ហ្នឹងគឺនៅខែណាដែរ លោកចាំថាបើគិតជាឆ្នាំខ្មែរ ឬក៏ជាឆ្នាំសាកលអ៊ីចឹងហ្នឹងណ៎ា លោកដឹងថាវានៅក្នុងឆ្នាំណាដែរ ដែលគេចាត់តាំងលោកឲ្យធ្វើការជាកង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ការពាររបស់ រស់ ញឹម?

**ឆ៖** អត់ដឹងទេបង មិនដឹង មិនបានរាប់ បានអី។

**ស៖** ឥឡូវ ខ្ញុំសួរអំពីអំឡុងពេលដែលលោកធ្វើកងការពារឲ្យ តាញឹម។ ហើយលោកធ្វើការនៅទីតាំងមួយនោះ ឈ្មោះអំពិលប្រហោង ជិតទីរួមខេត្តបាត់ដំបង។ តើលោកស្គាល់ភូមិមួយ ប្រហែលជាស្ថិតនៅចម្ងាយ មួយ ឬក៏២គីឡូម៉ែត្រ ទិសខាងត្បូងទីរួមខេត្តបាត់ដំបង ឈ្មោះថា វត្តគរ។ លោកស្គាល់ទេ?

**ឆ៖** វត្តគរ ស្គាល់។

**ស៖** តើលោកអាចជម្រាបជូនតុលាការបានទេ តើពីអំពិលប្រហោងទៅដល់វត្តគរហ្នឹង មានចម្ងាយប៉ុន្មានពីគ្នា?

[១៥:៥១:៣៨]

**ឆ៖** មិនដឹងប៉ុន្មានទេ ខ្ញុំមិនសូវនេះដែរ មិនដែលវាស់អីផង។ មើលដូចសន្ទឹមដែរពីហ្នឹងទៅ។ ជិតមាត់ស្ទឹងឯណោះ។

**ស៖** តើវត្តគរហ្នឹង នៅជិតនឹងទីរួមខេត្តបាត់ដំបងហ្នឹង មែនទែនឬ?

**ឆ៖** ជិតដែរបង។ ផ្លូវទៅបាណន់ហ្នឹង។

**ស៖** នៅក្នុងរបបនោះ តើលោកបានដឹងថា នួន ជា អនុលេខាបក្សកុម្មុយនីស្តកម្ពុជាហ្នឹង លោកមានដឹងទេ មានដឹងថាលោក នួន ជា ដែលជាអនុលេខាបក្សហ្នឹង គាត់មកពី<វត្ត>គរហ្នឹងឯង មកពីបាត់ដំបង?

**ឆ៖** ខ្ញុំអត់ដឹងទេបង។

**ស៖** តើលោកធ្លាប់ឮ តាញឹម និយាយអំពីឈ្មោះ នួន ជា ដែរឬទេ?

**ឆ៖** គាត់មិនដែលនិយាយពួកខ្ញុំផងបង។ ខ្ញុំមិនដែលទៅកន្លែងគាត់ទេ នៅក្រៅផ្ទះគាត់ផ្សេងៗ បើមានការណ៍គាត់ហៅទៅ។

**ស៖** ខ្ញុំសូមសួរលោកអំពីចំណុចមួយដែលនីរសាររបស់ នួន ជា និងអ្នកបើកបររបស់ នួន ជា ក៏ដូចជាកងការពារបានផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការយើងនេះ នៅថ្ងៃទី១៨ មេសា ឆ្នាំ២០១២។ លោកប្រធាន នេះគឺឯកសារ E1/63.1 គឺប្រតិចារឹកចុះថ្ងៃទី១៨ មេសា ឆ្នាំ២០១២ នៅម៉ោង ១៥:២២ ដល់ម៉ោង ១៥:២៦។ នេះគឺជាអ្វីដែលអ្នកបើកបរ និង កងការពាររបស់ នួន ជា បានឆ្លើយ។ "សួរ៖

លោកក៏បាននិយាយផងដែរថា នួន ជា បានធ្វើដំណើរទៅបាត់ដំបង តើគាត់ទៅជួបជាមួយអ្នកណា នៅពេលដែលគាត់ទៅបាត់ដំបង? ឆ្លើយ៖ គាត់ជួបជាមួយ តាញឹម ដែលជាមេភូមិភាគនោះ។ សួរ៖ តើ នួន ជា ទៅបាត់ដំបងញឹកញាប់ប៉ុនណាដែរ? ឆ្លើយ៖ មិនជាញឹកញាប់ទេ ប្រហែលជាមួយដងក្នុងរយៈពេលបីទៅបួនខែ។ សួរ៖ តើនួន ជា ហ្នឹង បានជួបជាមួយនឹង តាញឹម នៅកន្លែងណាដែរ? ឆ្លើយ៖ នៅពេលនោះ ពួកគាត់ជួបនៅក្នុងវត្តមួយ គឺខ្ញុំនឹកឈ្មោះវត្តនោះមិនឃើញទេ។ សួរ៖ តើវត្តនោះនៅជិតទីរួមខេត្តបាត់ដំបងមែនទេ? ឆ្លើយ៖ បាទ វត្តនោះនៅជិតខេត្តបាត់ដំបង។” បញ្ចប់ការដកស្រង់។ សំណួររបស់ខ្ញុំលោកសាក្សី អ្នកបើកបររបស់ នួន ជា បានឆ្លើយថា នួន ជា បានជួប តាញឹម -- អាចជួប តាញឹម នៅក្នុងវត្តមួយនៅជិតទីរួមខេត្តបាត់ដំបង តើលោកស្គាល់ឈ្មោះវត្តដែល តាញឹម យកធ្វើជាទីកន្លែងដើម្បីជួបជាមួយ នួន ជា ដែរឬទេ?

[១៥:៥៥:៣១]

**ឆ៖** វត្តនោះមានតែវត្តគរហ្នឹង ប៉ុន្តែខ្ញុំមិនដឹងគាត់ធ្វើស្អីមិនដឹង។ វត្តដឹងវត្ត វត្តគរ ផ្លូវទៅបាណន់ផ្សារលើយើង។ ប៉ុនម៉េចអត់ដឹងទេ។

**ស៖** វត្តដែលស្ថិតនៅក្នុងភូមិកំណើតរបស់ នួន ជា ហ្នឹង គឺវត្តគរហ្នឹង តើវត្តនេះគេមានបានប្រើប្រាស់ជាអ្វីដែរទេ នៅពេលដែលលោកធ្វើការជាមួយ តាញឹម នោះ?

**ឆ៖** ខ្ញុំមិនសូវដឹងដែរបង។

**ស៖** តើលោកដឹងទេ វត្តមួយធំណាស់ វត្តហ្នឹង នៅកណ្តាលទីរួមខេត្តបាត់ដំបង នៅជិតស្ទឹង គេហៅថា វត្តកណ្តាល។ តើលោកស្គាល់ឈ្មោះវត្តនេះទេ? -- វត្តកណ្តោរ -- វត្តកណ្តុរ។

**ឆ៖** អត់។

**ស៖** ប្រហែលជាខ្ញុំអានឈ្មោះវត្តនេះមិនច្បាស់ទៅក៏មិនដឹង។ តើលោកធ្លាប់ស្គាល់វត្តកណ្តោរទេ វត្តនេះធំណាស់នៅជិតមាត់ស្ទឹង គឺនៅក្នុងទីរួមខេត្តបាត់ដំបងនោះតែម្តង?

**ប្រធានអង្គជំនុំ៖**

លោកសាក្សី វត្តនេះ គឺឈ្មោះហៅ វត្តកណ្តាល។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកសាក្សី មានស្គាល់វត្តនេះទេ វត្តកណ្តាល?

**ឆ៖** អត់ផង ខ្ញុំមិនដែលដើរផង ទីក្រុង។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំហៀបនឹងចូលទៅប្រធានបទថ្មីមួយទៀតហើយ ប៉ុន្តែមើលម៉ោងទៅដល់ពេលត្រូវឈប់សម្រាកហើយ។

[១៥:៥៨:១០]

**ប្រធានអង្គជំនុំ៖**

អរគុណលោកព្រះរាជអាជ្ញា។ ឥឡូវដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការនីតិវិធីសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ ហើយសវនាការនឹងលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ទី២២ ខែកញ្ញា ឆ្នាំ២០១៦ ដែលចាប់ផ្តើមពីម៉ោង ប្រាំបួនព្រឹកទៅ។

សវនាការនៅថ្ងៃស្អែក អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី 2-TCW-1036 បន្តបញ្ចប់ ហើយនិងចាប់ផ្តើមស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-1064 ពាក់ព័ន្ធនឹងអង្គហេតុបទបញ្ញានៃការរៀបអាពាហ៍ពិពាហ៍។ សូមភាគីជ្រាបនិងអញ្ជើញចូលរួមតាមពេលវេលាកំណត់។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់ចូលរួមសវនាការវិញនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

អញ្ជើញសម្រាក៕

*(សវនាការផ្អាកនៅម៉ោង ១៥:៥៩ នាទី)*